# យុវវ័យនិយាយប្រាប់ពី ថ្ងៃបុណ្យសង្សារនៅទីក្រុងភ្នំពេញឆ្នាំ២០០៨
## (ការសិក្សាបែបគុណភាពវិស័យមួយ)













ដោយៈ លោក គុង សុប្រាជ្ញ អនុបណ្ឌិតផ្នែកសុខភាពសាធារណៈ
អ្នកសិក្សាស្រាវជ្រាវឯករាជ្យ

ភ្នំពេញ ខែមករា ឆ្នាំ២០០៩

# មូលន័យសង្ខេប


ការសិក្សានេះស្វែងរកហេតុផលពិតជាក់ស្តែងថ្មីមួយ ដែលទាក់ទងទៅនឹងសេចក្តីស្នេហា និងទំនាក់ទំនងផ្លូវភេទ ក្នុងចំណោមគូសង្សារមួយចំនួននៅក្នុងថ្ងៃបុណ្យសង្សារ និងដើម្បីយល់ដឹងឱ្យច្បាស់ពីទស្សនវិស័យរបស់យុវវ័យចំពោះឥរិយាបថ របស់ឪពុកម្តាយពួកគេនៅថ្ងៃបុណ្យសង្សារនេះ។ យុវវ័យ១៦នាក់នៅក្នុងទីក្រុងភ្នំពេញ ដែលមានអាយុ១៥-២៤ឆ្នាំ ក្នុងនោះមានប្រុស១១នាក់ និងស្រី៥នាក់ បានផ្តល់បទសំភាសន៍យ៉ាងស៊ីជម្រៅជាមួយនឹងក្រុមមិត្តស្រាវជ្រាវពីមិត្ត ទាក់ទងទៅនឹងអ្វីដែលពួកគេបានប្រព្រឹត្តជាមួយគូសង្សាររបស់ពួកគេនៅថ្ងៃបុណ្យសង្សារកន្លងទៅ។ បទសំភាសន៍ទាំងនោះត្រូវបានធ្វើការវិភាគដោយផ្អែកទៅតាមគោលបំនងនីមួយៗ។

តាមរយៈការសិក្សានេះបង្ហាញឱ្យឃើញថា គូស្នេហ៍យុវវ័យមិនទាន់យល់ច្បាស់អំពីដើមកំណើតថ្ងៃបុណ្យសង្សារនៅឡើយទេ ដោយថ្ងៃបុណ្យនោះនិយមប្រារព្ធបំផុតនៅក្នុងចំណោមយុវវ័យកូនអ្នកធូរធារមួយចំនួននៅក្នុងទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែពួកគេគ្រាន់តែដឹងថា ថ្ងៃបុណ្យសង្សារបានមកពីការចំលងនៃវប្បធម៌បរទេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា ចំនួនយុវវ័យដែលផ្តល់ការសំភាសន៍ច្រើនជាងពាក់កណ្តាលសប្បាយចិត្តនឹងការ មានទំនាក់ទំនងផ្លូវភេទនៅថ្ងៃបុណ្យសង្សារ ហើយមួយចំនួនបានបាត់បង់ភាពបរិសុទ្ធ។ ទោះបីជានៅក្នុងបទសំភាសន៍ភាគច្រើននិយាយថា ពួកគេបានប្រើប្រាស់ស្រោមអនាម័យ ដែលអាចបញ្ជាក់ថាពួកគេមានការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជក៏ដោយក៏នៅមានករណីបង្ខំខ្លះទៀត ដែលត្រូវបានលើកឡើងនៅក្នុងនោះផងដែរ។ ករណីនេះជាទូទៅបណ្តាលមកពីភាពខ្វះការយកចិត្តទុកដាក់របស់ឪពុកម្តាយ និងអាណាព្យាបាលអំពីសកម្មភាពផ្លូវភេទរបស់កូន និងខ្វះទំនាក់ទំនងនៅក្នុងក្រុមគ្រួសារ ព្រមទាំងការនិយាយដោយបើកចំហអំពីបញ្ហានេះ។

មានឥរិយាបថនៃការផ្លាស់ប្តូរចិត្តមិនប្រើប្រាស់ស្រោមអនាម័យ ដោយសារការចង់បង្ហាញពីភាពជឿជាក់ និងស្មោះត្រង់ចំពោះគូស្នេហ៍។ ការយល់ដឹងអំពីសិទ្ធិនៃការមានទំនាក់ទំនងផ្លូវភេទនៅមានកំរិត បើផ្អែកទៅលើបទសំភាសន៍មួយចំនួន ដោយអ្នកខ្លះបានលើកឡើងថា ពួកគេបានដាក់សំពាធ និងខ្លះទៀតទទួលរងនូវសំពាធនៅក្នុងការរួមភេទនៅថ្ងៃបុណ្យសង្សារ។

ការយកចិត្តទុកដាក់ទៅលើបញ្ហាផ្លូវភេទគួរតែត្រូវបានលើកឡើង ចំណែកឯកម្មវិធីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងមេរោគអេដស៍ (SRH/HIV) ក្នុងចំណោមយុវវ័យគួរតែ ត្រូវបានកំណត់ដោយធ្វើអន្តរាគមន៍នៅមុន និងនៅថ្ងៃបុណ្យសង្សារនោះតែម្តង ដោយផ្អែកទៅលើការសិក្សាស្រាវជ្រាវនេះ។

# មាតិកា

**ទំព័រ**


មូលន័យសង្ខេប ……………………………………………………………………......i

មាតិកា ………………………………………………………………………….........ii

បញ្ជីពាក្យបំប្រួញ និងសទ្ទានុក្រមនៃពាក្យខ្មែរ ..……………………………………………iv

សេចក្ដីថ្លែងអំណរគុណ ……………………………………………………….................vi

I. សេចក្ដីផ្ដើម ……………………………………………………………….........................១

១.១. សាវតាអំពីការសិក្សាស្រាវជ្រាវ ……...………………………......................................១

១.២. ចំណុចនៃបញ្ហា ……………………………………………………..…………….....២

១.៣. គោលបំណងនៃការសិក្សា ………………………………..……………....៣

១.៤. សេចក្ដីសំខាន់នៃការសិក្សា ……………………………………………….៤

១.៥. ព្រំដែន និងកំរិតនៃការសិក្សា ……………………………..……………៤

១.៦. អត្ថន័យនៃពាក្យគន្លឹះ ………………………………………........................៦

II. សង្ខេបនៃការសិក្សាមុនៗអំពីឥរិយាបថនៃទំនាក់ទំនងផ្លូវភេទនៅប្រទេសកម្ពុជា ….......…………….៧

III. វិធីសាស្រ្ត …………………………………………………………………………១២

៣.១. វិធីសាស្រ្តបែបគុណភាពវិស័យនៃការសិក្សារបស់មិត្តស្រាវជ្រាវពីមិត្ត …………………………១២

៣.២. ការបណ្ដុះបណ្ដាលពីការសិក្សាស្រាវជ្រាវរបស់មិត្តស្រាវជ្រាវពីមិត្ត ………………………………១២

៣.៣. ការប្រមូលទិន្នន័យ ……………………………………………………………………១៣

៣.៤. ការវិភាគទិន្នន័យ …………….…………………………………………………… ១៣

៣.៥. របាយការណ៍ ………………………………………………………….................១៤

IV. លទ្ធផល …………………………………………………………………...……...១៤

៤.១. សកម្មភាព សេចក្ដីស្នេហា និងទំនាក់ទំនងផ្លូវភេទរបស់យុវវ័យនៅថ្ងៃបុណ្យសង្សារ ………………..១៤

៤.១.១. អំពីថ្ងៃបុណ្យសង្សារ ……………………………………………………….....១៤

៤.១.២. ពេលព្រឹកនៅថ្ងៃបុណ្យសង្សារ …….........…………………………………១៦

៤.១.៣. ពេលរសៀលនៅថ្ងៃបុណ្យសង្សារ ….............……………………………………..១៦

៤.១.៤.ពេលល្ងាចនៅថ្ងៃបុណ្យសង្សារ …..……………………………………………..២០

៤.១.៥.ពេលយប់នៅថ្ងៃបុណ្យសង្សារ ………………………………………………..២១

៤.១.៦.ការគ្មានទំនាក់ទំនងផ្លូវភេទ និងការរួមភេទដោយប្រើស្រោមអនាម័យជាមួយដៃគូនៅថ្ងៃបុណ្យសង្សារ ...២៥
៤.១.៧.ទស្សនវិស័យរបស់យុវវ័យអំពីឥរិយាបថឪពុកម្ដាយចំពោះថ្ងៃបុណ្យសង្សារ…………………………២៧
V. ការពិភាក្សា ……………………………………………………………………...២៩
VI. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ …………………………….……….……………………៣១
VII. ឯកសារយោង ………………………………………………………………...……៣៤
សេចក្ដីបញ្ជាក់បន្ថែម ……………………………………………………………………….ix
សេចក្ដីបន្ថែមទី១: ការស្នើសុំការយល់ព្រម និងការឆ្លើយសំនួរពាក់កណ្ដាលរចនាសម្ព័ន្ធ ….…………………..ix
សេចក្ដីបន្ថែមទី២: ការសិក្សាវិភាគលើករណីនីមួយៗ ……………………………………………………x

# បញ្ជីពាក្យបំព្រួញ និងសទ្ទានុក្រមនៃពាក្យខ្មែរ

## បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| AIDS: | Acquired Immune Deficiency Syndrome |
| BSS: | Behavioral Sentinel Survey |
| CDHS: | Cambodian Demographic Health Survey |
| EU: | European Unions |
| FHI: | Family Health International |
| FSW: | Female Sex Worker |
| GAD/C: | Gender and Development for Cambodia |
| GDP: | Gross Domestic Product |
| HIV: | Human Immunodeficiency Virus |
| HSS: | HIV Sero-surveillance Survey |
| KYA: | Khmer Youth Association |
| MOEYS | Ministry of Education, Youth and Sports |
| NCHADS: | National Center for HIV/AIDS, Dermatology, and STDs. |
| NGO: | Non-Government Organization |
| PE: | Peer Ethnographic |
| PER: | Peer Ethnographic Researcher |
| PS: | Playing Safe Project |
| PSI: | Population Services International |
| RHAC: | Reproductive Health Association of Cambodia |
| RHIYA: | Reproductive Health Initiative for Youth in Asia. |
| SRH: | Sexual and Reproductive Health |
| STD: | Sexually transmitted disease |
| STI: | Sexually transmitted infection |
| SW: | Sex Worker |
| TASK: | Trotrug Ning Akpiwat Sokhapeap Neak Kre Kror (Support and develop the poor’s health) |
| UNESCO: | United Nations Educational, Scientific and Cultural Organization |
| UNFPA: | United Nation Population Fund |
| UNICEF: | United Nation Children’s Fund |
| WAC: | Womyn’s Agenda for Change |
| WHO: | World Health Organization |
| YCC: | Youth Council of Cambodia |

## ***សទ្ទានុក្រមនៃពាក្យខ្មែរ***

***បាក់ខែង:*** ចម្ងាយប្រហែល១០គីឡូម៉ែត្រពីភ្នំពេញតាមផ្លូវជាតិលេខ៦A ។

***បូក:*** បូកតាមន័យធម្មតា ឬគណិតវិទ្យា គឺជាការបន្ថែម ។ សំរាប់ពាក្យរបស់ក្រុមស្មាវសំដៅទៅលើ:

១- បូកជាទូទៅកើតឡើងបន្ទាប់ពីយុវជនម្នាក់ ឬ២នាក់ទៅចរចារពីតំលៃជាមួយស្ត្រីរកស៊ីផ្លូវភេទ ឬការចូលលុយគ្នាដើម្បីរៀបចំរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទម្នាក់នោះ ។

២- បន្ទាប់មកទៀត យុវជនទាំងនោះយកស្ត្រីរកស៊ីផ្លូវភេទម្នាក់នោះទៅសណ្ឋាគារ ឬផ្ទះសំណាក់ដែលមានមិត្តភក្តិមួយចំនួននៅក្នុងបន្ទប់រួចហើយ និងកំពុងរង់ចាំរួមភេទ (ឬដែលនឹងមកដល់) ។

៣- ពេលនោះ យុវជនចាប់ផ្តើមបង្ខំស្ត្រីរកស៊ីផ្លូវភេទនោះ ដើម្បីរួមភេទម្តងម្នាក់ៗ ហើយខ្លះពីរទៅបីដងក្នុងមួយយប់នោះ ។ ជារឿយៗ ពួកយុវជនទាំងនោះតែងតែប្រើអំពើហឹង្សាទៅលើស្ត្រីរកស៊ីផ្លូវភេទនោះ ។

៤- ពួកគេស្ទើរតែទាំងអស់បាននិយាយថា នោះមិនមែនជាអំពើចាប់រំលោភសេពសន្ថវៈនោះទេ ពីព្រោះពួកគេបានបង់លុយរួចទៅហើយ ។[៩]

**គៀនស្វាយ:** មានចម្ងាយប្រហែល១៥គីឡូម៉ែត្រពីភ្នំពេញតាមផ្លូវជាតិលេខ១ ។

**ខ្មែរ:** ជនជាតិខ្មែរ និងភាសាខ្មែរ ។

**ខ្ទើយ:** បុរសដែលមានលក្ខណៈជានារី បែបម្សិកម៉្សក់ ។

**ម្ហូបដែលគេ:** ភាសាសាមញ្ញសំដៅទៅលើម្ហូបសំណល់ដែលគេបានបរិភោគរួចហើយ ។ ប៉ុន្តែន័យគ្រាមភាសាវិញ គឺជាពាក្យដែលយុវជនប្រើដើម្បីនិយាយចំអកទៅលើយុវនារីណាម្នាក់ ដែលបានបាត់បង់ភាពបរិសុទ្ធរបស់ខ្លួន ហើយត្រូវបានគេបោះបង់ចោល ។

**ញី:** (ពាក្យប្រើសំរាប់សត្វ មានន័យថាភេទស្រី) និងបុរសដែលមានលក្ខណៈជានារី បែបម្សិកម៉្សក់ ។

**ព្រែកលាប:** ចម្ងាយប្រហែល៥គីឡូម៉ែត្រពីភ្នំពេញតាមផ្លូវជាតិលេខ៦A ។

**តែគុជ:** ហាងចិនដែលមានលក់តែកាហ្វេ ។

**ផ្សារថ្មី:** (ផ្សារធំថ្មី) ឈ្មោះផ្សារមួយដែលនៅត្រង់ចំណុចកណ្តាលនៃទីក្រុងភ្នំពេញ ។

**វត្តភ្នំ:** ឈ្មោះកូនភ្នំមួយនៅក្នុងក្រុងភ្នំពេញ ។

---

[៩] Wilkinson, D.J., and Fletcher, G. (2002). *Sweetheart Relationship in Cambodia: Love, Sex & Condoms in the time of HIV,* Phnom Penh: PSI.
Bearup, L.S. (2003). *Paupers and Princelings : Youth Attitudes Toward Gangs, Violence, Rape, Drugs, and Theft.* Phnom Penh: GAD/C.
Soprach, T. (2004). *GANG RAPE: The Perspective of Moto-Taxi Drivers across Cambodia.* Phnom Penh: Playing Safe Project, CARE Cambodia, EU/UNFPA.

# សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះត្រូវបានរៀបរៀងឡើងដោយលោក តុង សុប្រាជ្ញ ជាទីប្រឹក្សាឯករាជ្យ ដែលបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យកម្ពុជានៅឆ្នាំ២០០៨ ផ្នែកសុខភាពសាធារណៈ។ លោកទទួលបានបទពិសោធន៍ការងារ១០ឆ្នាំ ក្នុងនោះមានបទពិសោធន៍ការងារ៥ឆ្នាំជាមួយយុវវ័យទៅលើបញ្ហាយេនឌ័រ និងបញ្ហាទាក់ទងផ្សេងៗទៀត បទពិសោធន៍ការងាររយៈពេល២ឆ្នាំជាមួយនឹងអង្គការ GAD/C និង៣ឆ្នាំជាមួយនឹងអង្គការ CARE អំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជយុវវ័យ។ លោកបានចូលរួមការសិក្សាស្រាវជ្រាវ និងការសិក្សាឯករាជ្យដោយខ្លួនឯងលើផ្នែកឥរិយាបថរបស់យុវវ័យក្នុងកំឡុងពេលបំរើការងារសំរាប់អង្គការទាំងនោះ។

- **Primary researcher (2003):** *Paupers and Princelings: Youth Attitudes Toward Gangs, Violence, Rape, Drugs, and Theft.* Phnom Penh: GAD/C.
- **Author (2004):** *GANG RAPE: The Perspective of Moto-Taxi Drivers across Cambodia.* Phnom Penh: Playing Safe Project, CARE Cambodia, EU/UNFPA.
- **Paper Co-author (2005):** *Youth Gang Rape in Phnom Penh.* SEX WITHOUT CONSENT: Young People in Developing countries. London/New York: Zed Book. pp. 158-168.
- **Coordination and Analysis (2006):** *Experiences and Changes in Sex, Relationships and RH Among Young Urban Men,* Phnom Penh: PS/CARE/KYA/EU/UNFPA.
- **Author (2008):** *The Impact of Premarital Sex Among Young People in Cambodia.* Phnom Penh: University of Cambodia.

ការសិក្សាអំពីថ្ងៃបុណ្យសង្សារនេះត្រូវបានរៀបចំឡើងដោយអ្នកស្រាវជ្រាវ និងមានការប្រឹក្សាណែនាំពីលោក David Wilkinson។ កាលពីមុន អ្នកស្រាវជ្រាវខ្លួនឯងផ្ទាល់បានគិតថានឹងរៀបចំការសិក្សានេះឡើង ដើម្បីជាផ្នែកមួយនៃការធ្វើនិក្ខេបបទថ្នាក់អនុបណ្ឌិត ប៉ុន្តែអាស្រ័យដោយពេលវេលាមិនអំណោយផល ទើបធ្វើឱ្យការសិក្សានេះមិនអាចធ្វើទៅឱ្យបានទាន់ពេលវេលា។ គាត់បានពិភាក្សាជាមួយអ្នកស្រាវជ្រាវ និងសាស្ត្រចារ្យមួយចំនួន ដែលបានជួយផ្តល់យោបល់ និងការណែនាំផ្សេងៗ។

នៅទីបំផុត អ្នកស្រាវជ្រាវបានសំរេចចិត្តបញ្ចប់របាយការណ៍នៃការសិក្សានេះ ក្រោមការចូលរួមពីក្រុមយុវវ័យអ្នកស្ម័គ្រចិត្ត ដែលជាអតីតមិត្តអប់រំមិត្តក្នុងឆ្នាំ២០០៣-២០០៦នៃគម្រោង Playing Safe នៃអង្គការ CARE/KYA/EU/UNFPA នៅភ្នំពេញ។ ចំណែកក្រុមមិត្តស្រាវជ្រាវពីមិត្តសំរាប់ការសិក្សានេះវិញ បានទទួលការផ្តល់បច្ចេកទេសពី

អ្នកស្រាវជ្រាវ។ ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវក៏បានទទួលផ្នែកបច្ចេកទេស ពីអ្នកស្រាវជ្រាវមួយចំនួន និងមិត្តភក្តិអំពីការផ្តល់យោបល់ និងព័ត៌មានត្រឡប់ និងការកែសម្រួលរបាយការណ៍អត្ថបទ ជាភាសាអង់គ្លេស។

សំរាប់ការសិក្សាលើថ្ងៃបុណ្យសង្សារនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ធនធានផ្ទាល់ខ្លួន មានដូចជាការចំណាយលើថវិកា សំភារៈ និងពេលវេលាជាដើម។

ជាបឋម ខ្ញុំសូមសម្តែងការថ្លែងអំណរគុណចំពោះមិត្តស្ម័គ្រចិត្តទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីចូលរួមប្រតិបត្តិ និងធ្វើការសំភាសន៏យ៉ាងស៊ីជម្រៅទាក់ទងទៅនឹងការសិក្សានេះ។

| ល.រ | ឈ្មោះ | ភេទ | អាយុ | តួនាទី | សកលវិទ្យាល័យ / អង្គការ |
|---|---|---|---|---|---|
| ១. | សារី រតនា | ស្រី | ២០ | និស្សិត | សាកលវិទ្យាល័យអន្តរជាតិភ្នំពេញ |
| ២. | ឯម ស្រីម៉ុច | ស្រី | ២៣ | និស្សិត | សាកលវិទ្យាល័យបៀរប្រាយ |
| ៣. | ង៉ែត ពុទ្ធិ | ប្រុស | ២២ | និស្សិត | សាកលវិទ្យាល័យបញ្ញាសាស្ត្រ |
| ៤. | ភោគ ភិរម្យ | ប្រុស | ២៤ | និស្សិត | វិទ្យាស្ថានជាតិអប់រំ |
| ៥. | ឡុង ម៉ារីន | ប្រុស | ២៥ | និស្សិត | វិទ្យាស្ថានជាតិភាសាបរទេស |

ជាបន្តទៀតនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះបណ្តាអ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់ ដែលបានជួយផ្តល់នូវគំនិតមតិល្អៗ ក៏ដូចជាយោបល់ និងមតិរិះគន់ក្នុងន័យស្ថាបនានៅមុន និងក្រោយពេលធ្វើការរៀបចំសរសេររបាយការណ៍ និងធ្វើឱ្យការសិក្សានេះកាន់តែប្រសើរឡើង និងពង្រឹងសមត្ថភាពនៃអ្នកស្រាវជ្រាវក្នុងស្រុក និងអ្នកផ្តល់យោបល់មានដូចជា លោក David Wilkinson, អ្នកស្រី Sharon Wilkinson, កញ្ញា Heidi Hoefinger និងលោកស្រីបណ្ឌិត Melissa Farley។ កញ្ញា ព្រាប ចរិយា បានរួមចំណែកជួយក្នុងការកែប្រែសម្រួលទិន្នន័យដើមជាភាសាអង់គ្លេសរបស់ខ្ញុំ និងកញ្ញា សុខុម បញ្ញារតន៍ ជាអ្នកបកប្រែសម្រួលជាភាសាខ្មែរ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណលោកស្រី Fleur Smith ដែលបានជួយកែសម្រួលអត្ថបទការសិក្សាស្រាវជ្រាវនេះ។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងការដឹងគុណចំពោះអ្នកម្តាយរបស់ខ្ញុំបាទ អ្នកស្រី ស៊ីវ ឃីម ជាអតីតគ្រូបង្រៀនបឋមសិក្សាម្នាក់ ដែលបានចូលនិវត្តន៍កាលពីឆ្នាំ២០០៨ និងជាអ្នកដែលអនុញ្ញាតិឱ្យខ្ញុំបាទបានធ្វើការសិក្សាស្រាវជ្រាវនេះនៅពេលទំនេរ ។ គាត់តែងតែជាអ្នកមានមោទភាពលើខ្ញុំបាទ ជាពិសេសតែងតែបារម្ភ និងយកចិត្តទុកដាក់ថែរក្សាសុខភាពក៏ដូចជាសុវត្ថិភាពរបស់ខ្ញុំបាទជាដើម ។

ខ្ញុំបាទរង់ចាំទទួលមតិរិះគន់កែលំអគ្រប់បែបយ៉ាង!

លោក តុង សុប្រាជ្ញ អនុបណ្ឌិត សុខភាពសាធារណៈ
Email: soprach76@gmail.com

Blog web: www.soprach76.blogspot.com

ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**I. សេចក្តីផ្តើម**

## ១.១. សាវតារអំពីការសិក្សាស្រាវជ្រាវ

សង្គមសេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរពីរបបសង្គមនិយមមកជារបបមូលធននិយមនៅក្នុងឆ្នាំ១៩៩០។[២] រយៈពេលច្រើនជាង១ទសវត្សរ៍កន្លះ ប្រទេសកម្ពុជាបានទទួលនូវអត្រាខ្ពស់នៃការកើនឡើងផ្នែកសេដ្ឋកិច្ច និងការកើនឡើងខ្ពស់ចំពោះស្តង់ដានៃការរស់នៅរបស់ប្រជាជាតិ បើប្រៀបធៀបការអង្កេតគ្រួសារថ្នាក់ជាតិជាលើកដំបូង កាលពីឆ្នាំ១៩៩៣/៩៤ ទៅនឹងការធ្វើស្ថិតិថ្មីៗនៅក្នុងឆ្នាំ២០០៤។[៣] ស្ថិតិផលិតផលក្នុងស្រុកសរុប (GDP) កើនឡើងជាមធ្យម៨,៤ភាគរយជារៀងរាល់ឆ្នាំ គិតតាំងពីឆ្នាំ១៩៩៤រហូតមកដល់ឆ្នាំ២០០៦។[៤] បើផ្អែកតាមរបាយការណ៍អន្តរជំរឿនកាលពីឆ្នាំ២០០៤ បានបញ្ជាក់ថា អត្រាចំនួនខ្ពស់ជាងគេគឺក្រុមប្រជាជនដែល មានអាយុពី១០ទៅ១៩ឆ្នាំ (២៦.៤ភាគរយ)[៥] ហើយគឺ ជាក្រុម ដែលអ្នកវិភាគស្រាវជ្រាវជ្រើសរើសយកមកសិក្សានៅទីនេះ ហើយនៅពេលនេះពួកគេមានអាយុប្រហែលជា ១៤ទៅ២៣ឆ្នាំ។ ប្រជាជនដែលស្ថិតក្នុងអាយុនេះកំពុងតែទទួលយកបទពិសោធន៍នៃផ្លាស់ប្តូរយ៉ាងលឿនទាំងផ្នែករូបរាង កាយ និងអារម្មណ៍ ហើយមានបុគ្គលក្នុងកម្រិតអាយុនេះជាច្រើន កំពុងតែចូលរួមនិងមានសកម្មភាពប្រឈមមុខយ៉ាងខ្លាំងក្នុងទំនាក់ទំនងផ្លូវភេទ។ ស្ថិតនៅក្នុងចំណុចនេះក៏បានកំណត់ចែងយ៉ាងត្រឹមត្រូវតាមច្បាប់អំពីកុមារ និងមនុស្សពេញវ័យ ដោយស្ត្រីអាចរៀបការបានស្របច្បាប់នៅអាយុ១៨ឆ្នាំ ចំណែកឯបុរសរៀបការបាននៅអាយុ២០ឆ្នាំ។[៦] ចំពោះការសិក្សាលក្ខណៈជាតិក្នុងពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញថា បើគិតជាមធ្យមភាគបុរសរៀបការនៅក្នុងអាយុស្ទង់២២.១ឆ្នាំ ហើយចាប់ផ្តើមមានទំនាក់ទំនងផ្លូវភេទមុនរៀបការនៅអាយុស្ទង់២១.៥ឆ្នាំ ចំណែកឯស្ត្រីវិញ ជាទូទៅចាប់ផ្តើមរួមភេទនៅលើកដំបូងនៅអាយុស្ទង់២០.៤ឆ្នាំជាមធ្យមដូចអាយុនៅពេលរៀបការ។[៧]

ក្នុងនោះក៏នៅមានមតិយោបល់ជាច្រើនត្រូវបានលើកឡើងជុំវិញដើមកំណើតនៃថ្ងៃបុណ្យសង្សារ។ អ្នកជំនាញខ្លះបានលើកឡើងថា ថ្ងៃបុណ្យសង្សារមានដើមកំណើតមកពីលោក St. Valentine ជនជាតិរ៉ូម៉ាំងម្នាក់បានបាត់បង់ជីវិត ដោយសារ

---

[2] Tarr, C.M. (1996b). *People in Cambodia don't talk about sex, they simply do it: A study of the Social and Contextual Factors Affecting Risk-Related Sexual Behavior among Young Cambodians*. Phnom Penh: University of Fine Arts. p. 68.

[3] World Bank. (2007). *Cambodian Sharing Growth: Equity and Development Report 2007*. Phnom Penh. p. ii

[4] *Ibid.* p. 1.

[5] NIS. (2004). *Cambodian Inter-censual Population Survey 2004*, General Report, Phnom Penh: MOP. p. 13

[6] ក្រឹត្យក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា (ឆ្នាំ១៩៨៩) *ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ មាត្រាទី៥ ជំពូក២* ត្រូវបានដកស្រង់ចេញពីសៀវភៅកម្រង ឯកសារច្បាប់ បោះពុម្ពលើកទី ៣ (ឆ្នាំ២០០១) នៃការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ធ្វើនៅភ្នំពេញ។ ទំព័រទី ៦៤៤។

Degree of State Councils of Cambodian State (1989). *Marital Law, Article 5, Chapter 2.* Cited by 3rd edition Legal Document Braid. (2001), United Nations Cambodia Office of the High Commissioner for Human Rights. Phnom Penh. p. 644.

[7] National Institute of Public Health and National Institute of Statistics. (2006). *Cambodia Demographic and Health Survey (CDHS) 2005*. Phnom Penh, Cambodia. p. 101.

ការប្រឆាំងដាច់ខាតមិនលះបង់គ្រីស្តសាសនា។ គាត់ទទួលមរណភាពនៅថ្ងៃទី១៤ ខែកុម្ភៈ ២៦៩ឆ្នាំ គ្រីស្តករាជ ហើយថ្ងៃនោះត្រូវបានគេឧទ្ទិសបូជាសំរាប់សេចក្តីស្រលាញ់។ មិនយូរប៉ុន្មាន ថ្ងៃទី១៤កុម្ភៈបានក្លាយទៅជាថ្ងៃដែលមនុស្សទូទៅនាំគ្នាផ្ញើសារនៃសេចក្តីស្រលាញ់ឱ្យគ្នាទៅវិញទៅមក ហើយ St. Valentine បានក្លាយទៅជានិមិត្តរូបនៃសេចក្តីស្រលាញ់សំរាប់គូស្នេហ៍គ្រប់រូប ហើយថ្ងៃនោះត្រូវបានគេកំណត់ដើម្បីផ្ញើពាក្យកាព្យ និងកាដូ មានដូចជា ផ្កាជាដើម។[8] ថ្ងៃ St. Valentine's Day បច្ចុប្បន្នបានក្លាយទៅជាថ្ងៃបុណ្យសង្សារ និងជាថ្ងៃដែលមនុស្សគ្រប់រូបបង្ហាញសេចក្តីស្រលាញ់ទៅកាន់មិត្តភក្តិ និងអ្នកជាទីស្រលាញ់។[9]

ថ្ងៃបុណ្យសង្សារត្រូវបានគេទទួលស្គាល់ទូទាំងពិភពលោក។ ចំណែកឯថ្ងៃបុណ្យសង្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញទើបតែត្រូវបានគេធ្វើឡើង ជាពិសេសពេញនិយមយ៉ាងខ្លាំងក្នុងចំណោមយុវវ័យ ដែលពួកគេតែងតែជូនផ្កា កាដូ និងកាតជូនពរឱ្យគ្នាទៅវិញទៅមក ព្រមទាំងចំណាយពេលដើរកំសាន្តជាមួយនឹងគូស្នេហ៍ និងមិត្តភក្តិនៅទីក្រុងនានា។[10] ជាទូទៅ គេសង្កេតឃើញថា យុវជននៅប្រទេសកម្ពុជាមានឱកាសក្នុងការដើរកំសាន្តជាក្រុម និងមានទំនាក់ទំនងនឹងសង្គមខាងក្រៅច្រើនជាងយុវនារី ដែលត្រូវនៅតែក្នុងផ្ទះដើម្បីបំពេញកិច្ចការងារនៅផ្ទះ។ យុវនារីមានឱកាសភាគច្រើនចេញទៅខាងក្រៅតែនៅពេលមានពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងពិធីបុណ្យអុំទូកជាដើមតែប៉ុណ្ណោះ។[11] ដោយសារតែទំនោរទៅរកការកែប្រែថ្មីនៃសង្គមបែបសម្ភារនិយម ធ្វើឱ្យយុវវ័យនៅប្រទេសកម្ពុជាកំពុងឈ្លក់វង្វេងជាមួយនឹងភាពជឿនលឿនក្នុងទីក្រុង និងសេរីភាពក្នុងការមានទំនាក់ទំនងផ្លូវភេទកាន់តែខ្លាំងជាមុន។[12]

## ១.២. ចំណុចនៃបញ្ហា

ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថា បានទទួលជោគជ័យនៅក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍។ វាត្រូវបានគេធ្វើការប៉ាន់ស្មានថា អត្រាប្រេវ៉ាឡង់ក្នុងចំណោមមនុស្សពេញវ័យ ដែលមានអាយុចាប់ពី១៥ទៅ៤៩ឆ្នាំមានអត្រាចុះទាបពី១.៣ភាគរយក្នុងឆ្នាំ២០០៣ ទៅ០.៩ភាគរយក្នុងឆ្នាំ២០០៦។[13] កម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ភាគរយកំពុងដើរតួយ៉ាងសំខាន់នៅក្នុងការចូលរួមកាត់បន្ថយប្រេវ៉ាឡង់នៃមេរោគអេដស៍។ បុរសជាច្រើនទៀតដែលស្ថិតនៅក្នុងក្រុមសង់ទីទីល បានបញ្ជាក់ថាការប្រើប្រាស់ស្រោមអនាម័យនៅពេលរួមភេទជាមួយដៃគូមានការកើនឡើង

[8] Retrieved February 12, 2008 from http://www.pictureframes.co.uk/pages/saint_valentine.htm
[9] Retrieved February 12, 2008 from http://www.history.com/content/valentine/history-of-valentine-s-day
[10] "…Meeting with a few young men, in the front of Preah Monivong high school in town of Battambong province, who are buying flowers for their girl who are classmates to express their love. At the evening, there were a traffic jams along the Sankae river because young people bought flowers on the streets." Kranhong. (2008, Feb. 15). This Valentine's Day There Were Not A Group of Students Who Sold Flower To Support Orphanages. *Reak Smey Kampchea*, p. 2b.
[11] Wallquist, L. (2002). *Youth in Cambodia: Organizations, Activities and Policies.* Phnom Penh: Forum Syd. p. 10.
[12] Fordham, G. (2003). *Adolescent Reproductive Health in Cambodia: Status Policies, Programmes and Issues.* Phnom Penh: POLICY Project. p. 3. Retrived December 23, 2008 from http://www.policyproject.com/pubs/countryreports/ARH_Cambodia.pdf
[13] NCHADS. (2007, June 28). *Press release: Government announces official HIV prevalence rate.* Retrieved November 2, 2007 from http://www.nchads.org/pressrelease/28-06-07%20en.pdf

ជាងឆ្នាំមុន បើផ្អែកទៅលើការអង្កេតស្ទាបស្ទង់នៃ Behavioral Sentinel Survey ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ស្រោមអនាម័យជាមួយនឹងដៃគូស្នេហានៅតែស្ថិតនៅក្នុងអត្រាទាបនៅឡើយ ។[14] ប្រេវ៉ាឡង់នៃជម្ងឺឆ្លងតាមភេទស្ថិតនៅក្នុងអត្រាដដែលដូចគ្នាទៅនឹងឆ្នាំ២០០១ បើទោះបីជាមានការព្យាយាមក្នុងការបង្កើនសេវាកម្មការពារព្យាបាល និងបង្ការមេរោគឆ្លងតាមភេទសំរាប់ស្ត្រីរកស៊ីផ្លូវភេទយ៉ាងណាក៏ដោយ ។[15] ការសិក្សាស្រាវជ្រាវរបស់លោកស្រី Tarr បានសង្កត់ធ្ងន់ដោយស្នើឡើងថាយើងច្រានចោលបរិបទផ្សេងៗដែលមនុស្សពេញវ័យ មានទាំងនារីវ័យក្មេង និងស្ត្រីនៅលីវសុទ្ធតែមានទាក់ទងនឹងការប្រព្រឹត្តទំនាក់ទំនងផ្លូវភេទ ។[16] ឱកាសថ្មីៗ និងការផ្តល់សេរីភាពកាន់តែខ្លាំងដល់យុវវ័យ បង្ហាញឱ្យឃើញពីលទ្ធផលនៃការផ្លាស់ប្តូរបទដ្ឋានសង្គមផងដែរ ដោយយុវជនភាគច្រើនងាកមករកដៃគូសង្សារ ជាជាងការគ្រាន់តែចំនាយប្រាក់ដើម្បីរួមភេទ ។[17] ករណីពន្លូតកូនដោយគ្មានសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជានៅតែជាមូលហេតុចំបងជុំវិញករណីនៃអត្រាមរណរបស់ស្ត្រីមាតា( ២០-២៩ភាគរយ) ។[18] ការសិក្សាបែបគុណភាពវិស័យមួយ ដែលបានរៀបចំឡើងដោយសាកលវិទ្យាល័យ Assumption នៃទីក្រុងបាងកកបានលើកឡើងថា ចំនួនមួយភាគប្រាំនៃក្មេងជំទង់នឹងមានការរួមភេទនៅថ្ងៃបុណ្យសង្សារ ។[19] ការពិភាក្សាជាក្រុមជុំវិញបញ្ហានៃការរួមភេទក្នុងចំនោមយុវវ័យនៅថ្ងៃបុណ្យសង្សារក្នុងទីក្រុងភ្នំពេញដែលត្រូវបានរៀបចំឡើងសមាគមអង្គការអភិវឌ្ឍន៍សុខភាពប្រជាជន (PHD) បានលើកឡើងជាសំណួរអំពីគ្រោះថ្នាក់នៃការមានសកម្មភាពផ្លូវភេទរបស់យុវវ័យនៅថ្ងៃបុណ្យសង្សារ និងផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមាន ។[20] ទោះបីជាយ៉ាងណាក៏ដោយក៏មិនទាន់មានការសិក្សាស្រាវជ្រាវណាមួយ ដែលអាចបញ្ជាក់ឱ្យបានច្បាស់លាស់ជុំវិញបញ្ហានេះនៅឡើយទេ ។ ដូច្នេះ ការសិក្សាថ្មីមួយនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ជាចម្លើយចំពោះសំណួរដែលចោទសួរថា:

*តើយុវវ័យបានប្រព្រឹត្តការរួមភេទនៅថ្ងៃបុណ្យសង្សារក្នុងទីក្រុងភ្នំពេញដែរឬទេ?*

## ១.៣. គោលបំណងនៃការសិក្សា

គន្លឹះនៃគោលបំណងនៃការសិក្សាគឺ:

---

14 NCHADS. (2003). *Behavioral Sentinel Survey (BSS) V:SEXUAL BEHAVIOR AMONG URBAN SENTINEL GROUPS, CAMBODIA 2001*. Phnom Penh: MOH. p. 45.
Retrieved February 12, 2008 from http://www.nchads.org/Publication/BSS/BSS2001.PDF

15 NCHADS. (2008). *2005 Cambodian STI Prevalence Survey: Integrated Biological and Behavioral Survey*. Phnom Penh: MoH. p. 44
Retrieved February 12, 2008 from http://www.nchads.org/Publication/SSS/SSS%202005.pdf

16 Tarr, C.M. (1996b). *Op. cit.*, p. 2

17 Wilkinson, D.J. and Fletcher, G. (2002). *Sweetheart Relationship in Cambodia: Love, Sex & Condoms in the time of HIV*, Phnom Penh: PSI. p.1

18 WHO. (2004). *Unsafe abortion: Global and Regional Estimated of the Incidence of Unsafe Abortion and Associated Mortality in 2000*. Geneva. Cited by MoH. (2006). National Strategic for Reproductive and Sexual Health in Cambodia (2006-2010). Phnom Penh. p. 7-8

19 Ann. (2008, Feb. 11). One fifth of teenagers will have sex on Saint Valentine's day in Bang Kok. *Nation*, Retrieved February 12, 2008 from
http://www.asiaone.com/News/Education/Story/A1Story20080211-49118.html

20 Chansy, C. (2008, Feb. 15). Panel Tells Youths To Use Valentine's Day Caution. *Cambodia Daily*, p. 20.

- ដើម្បីស្រាវជ្រាវពីហេតុផលពិតជាក់ស្តែង ទាក់ទិនទៅនឹងសេចក្តីស្នេហា និងទំនាក់ទំនងផ្លូវភេទក្នុងចំណោមយុវវ័យនៅថ្ងៃបុណ្យសង្សារ។
- ដើម្បីយល់ឱ្យច្បាស់ពីទស្សនវិស័យយុវវ័យចំពោះឥរិយាឪពុកម្តាយរបស់ពួកគេទៅលើថ្ងៃបុណ្យសង្សារ។

## ១.៤. សេចក្តីសំខាន់នៃការសិក្សា

ការសិក្សាបែបគុណភាពវិស័យនេះត្រូវបានបញ្ចប់សព្វគ្រប់ ដោយបានធ្វើបទសំភាសន៍ជាមួយក្រុមយុវវ័យមួយចំនួនបាននិយាយបើកចំហអំពីទំនាក់ទំនងផ្លូវភេទរបស់ពួកគេនៅថ្ងៃបុណ្យសង្សារកាលពីឆ្នាំ២០០៨កន្លងទៅ។ សេចក្តីសម្រេច និងអនុសាសន៍ទាំងឡាយត្រូវបានផ្តល់ទៅឱ្យអ្នកដែលមានតួនាទីសំខាន់ៗ មានដូចជា អាជ្ញាធរក្នុងតំបន់ ប្រព័ន្ធផ្សព្វផ្សាយ ឪពុកម្តាយ ឬអាណាព្យាបាល និងអ្នករៀបចំកម្មវិធីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជជាដើម ដែលអាចជួយធ្វើអន្តរាគមន៍ឱ្យបានទូលំទូលាយនៅថ្ងៃបុណ្យសង្សារ និងបណ្តាយុវវ័យទាំងឡាយ។ នេះក៏ជាការណែនាំមួយសំរាប់អ្នកធ្វើការស្រាវជ្រាវទាំងអស់ក្នុងការរៀបចំការសិក្សាបែបគុណវិស័យឱ្យបានកាន់តែលំអិតថែមទៀតទៅលើឥរិយាបថនៃទំនាក់ទំនងផ្លូវភេទរបស់យុវវ័យបច្ចុប្បន្ន។ សេចក្តីសម្រេចលទ្ធផលទាំងនេះនឹងបង្ហាញដល់យុវវ័យទាំងអស់ ក៏ដូចជាធ្វើឱ្យពួកគេវិនិច្ឆ័យ និងយល់ច្បាស់អំពីឥរិយាបថក្នុងការរួមភេទសម្ព័ន្ធរបស់ពួកគេ។

## ១.៥. ព្រំដែន និងកំរិតនៃការសិក្សា

***បញ្ហានៃពេលវេលា:***

គំនិតនៃការសិក្សាស្រាវជ្រាវមួយនេះត្រូវបានជម្រុញឡើងដោយសារអត្ថបទចុះផ្សាយមួយកាលពីថ្ងៃទី១១ខែកុម្ភៈឆ្នាំ២០០៨ ដែលជាអត្ថបទសិក្សាបែបបរិមាណវិស័យស្តីអំពីឥរិយាបថនៃទំនាក់ទំនងផ្លូវភេទនៅថ្ងៃបុណ្យសង្សារត្រូវបានរៀបចំដោយសាកលវិទ្យាល័យAssumtionទីក្រុងបាងកក។ ការសិក្សានេះទាក់ទិនទៅនឹងចំណាប់អារម្មណ៍របស់អ្នកធ្វើការស្រាវជ្រាវផ្ទាល់ ព្រមជាមួយនឹងប្រធានបទដែលគាត់បានធ្លាប់បានសិក្សាពីមុនមក។ អ្នកស្រាវជ្រាវបានរំលឹកឡើងវិញនូវការសិក្សាមុនៗមានទាំងវិធីសាស្ត្រនិងការរៀបចំជាសំណួរ ព្រមទាំងការលំបាកក្នុងការចំនាយពេលវេលាជ្រើសរើសមិត្តស្រាវជ្រាវពីមិត្ត ក៏ដូចជាអ្នកស្ម័គ្រចិត្ត ដែលធ្លាប់ជាអតីតមិត្តអប់រំមិត្តសំរាប់គម្រោង ប្រព្រឹត្តដោយសុវត្ថិភាព(PS)។ របាយការណ៍នេះត្រូវបានចំណាយពេលដើម្បីរៀបចំចងក្រងឡើងដោយផ្អែកទៅលើសមត្ថភាពរបស់អ្នកស្រាវជ្រាវ ដើម្បីសម្រួលពេលវេលាអាស្រ័យទៅនឹងការងារផ្ទាល់ខ្លួន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គាត់បានព្យាយាមប្រឹងប្រែងបញ្ចប់ការសិក្សាស្រាវជ្រាវនេះនៅមុនថ្ងៃបុណ្យសង្សារ។

### *បញ្ហាផ្នែកហិរញ្ញវត្ថុ:*

ការសិក្សានេះរៀបចំឡើងដោយប្រើថវិការបស់អ្នកស្រាវជ្រាវផ្ទាល់ខ្លួនក្នុងនាមជាទីប្រឹក្សាឯករាជ្យម្នាក់។ ដូច្នេះ ថវិកាមានកំណត់ ដោយម្យ៉ាងទៀតគាត់មិនអាចមានលទ្ធភាពទទួលយកអ្នកជំនាញវិជ្ជាជីវៈ ឬអ្នកស្រាវជ្រាវជំនាញណាមួយ ដើម្បីធ្វើជាមិត្តស្រាវជ្រាវពីមិត្តសំរាប់ការសិក្សានេះបាននោះទេ។

### *សំណួរពាក់កណ្តាលរចនាសម្ព័ន្ធត្រូវបានរៀបចំឡើងជាមួយនឹងសំណើសុំការយល់ព្រម*

តាមរយៈសំណួរពាក់កណ្តារចនាសម្ព័ន្ធនេះ អ្នកស្រាវជ្រាវស្វែងរកគំនិតផ្សេងៗបានយ៉ាងទូលំទូលាយ និងបញ្ជាក់យ៉ាងក្បោះក្បាយអំពីកម្មវត្ថុនៃការសិក្សា។ ជាមួយនឹងសំណើដើម្បីសុំការយល់ព្រមត្រូវបានធ្វើឡើងដោយផ្ទាល់ ហើយរាល់បទសំភាសន៍ទាំងអស់នឹងត្រូវបានលាក់ទុកជាការសម្ងាត់។

### *ការហាត់រៀនអំពីការធ្វើការសិក្សាស្រាវជ្រាវពីមិត្ត*

ពុំមានការបណ្តុះបណ្តាលជាចាំបាច់ណាមួយដែលត្រូវបានធ្វើឡើងនោះទេ គ្រាន់តែអ្នកស្រាវជ្រាវអាចវិភាគបានថាពួកគេអាចមានសមត្ថភាពបំពេញការសិក្សាស្រាវជ្រាវនេះបាន ស្របពេលដែលពួកគេក៏ធ្លាប់ជាអតីតអ្នកស្ម័គ្រចិត្ត និងមិត្តអប់រំមិត្តលើបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់គម្រោងប្រព្រឹត្តដោយសុវត្ថិភាពពីមុនមក ដែលជាដៃគូរបស់អង្គការ CARE International និង KYA។ មិត្តអ្នកស្រាវជ្រាវពីមិត្តទាំងអស់ទទួលបានការហាត់រៀនពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យពីមិត្តភក្តិរបស់គេ និងសរសេរជារបាយការណ៍សំរាប់គម្រោងសិក្សានេះ ហើយពួកគេភាគច្រើនសុទ្ធតែទទួលការហាត់រៀនពីមិត្តស្រាវជ្រាវពីមិត្ត និងការផ្លាស់ប្តូរគួរឱ្យកត់សំគាល់យ៉ាងខ្លាំង។

### *មិត្តអ្នកស្រាវជ្រាវពីមិត្តចែករំលែក និងរៀនពីមេរៀនទាំងនោះបន្ទាប់ពីការប្រមូលទិន្នន័យ*

ក្នុងកំឡុងពេលសិក្សាស្រាវជ្រាវអំពីថ្ងៃបុណ្យសង្សារនោះ អ្នកស្រាវជ្រាវផ្ទាល់ស្ថិតនៅក្លឹប Casa ហើយបានជួបជាមួយនឹងយុវជនម្នាក់ដែលកំពុងនៅជាមួយនឹងមិត្តស្រីរបស់គេ។ យុវជនរូបនោះរីករាយនឹងផ្តល់លេខទូរស័ព្ទសំរាប់ទំនាក់ទំនងជាមួយនឹងអ្នកស្រាវជ្រាវអំពីការធ្វើកិច្ចសន្ទនាស៊ីជម្រៅនៅពីរថ្ងៃបន្ទាប់មក។

កិច្ចសន្ទនាចំនួន២ត្រូវបានលុបចោលក្នុងចំណោមកិច្ចសំភាសន៍ទាំង១៨ ស្របពេលដែលមិត្តអ្នកស្រាវជ្រាវពីមិត្តម្នាក់បានអនុញ្ញាតិឱ្យបងស្រីរបស់ខ្លួនជួយក្នុងការធ្វើកិច្ចសន្ទនាបែបស៊ីជម្រៅនេះជាមួយនឹងអ្នកផ្តល់កិច្ចសំភាសន៍។ ដូច្នេះ ចំនួនសរុបនៃបទសំភាសន៍ទាំងអស់មាន១៦។ ប៉ុន្តែមិត្តអ្នកស្រាវជ្រាវពីមិត្តខ្លះធ្វើកិច្ចសន្ទនានេះតាមរយៈទូរស័ព្ទ។ មិត្តអ្នកស្រាវជ្រាវពីមិត្តភេទប្រុសម្នាក់បាននិយាយឱ្យដឹងថា មានការលំបាកខ្លាំងនៅក្នុងការណាត់ជួបជាមួយនឹងអ្នកផ្តល់បទសំភាសន៍។ ចំណែកមិត្តអ្នកស្រាវជ្រាវពីមិត្តភេទស្រីម្នាក់ទៀតវិញបាននិយាយប្រាប់ថា វាមានការលំបាកនៅក្នុងការសួរអំពីបទពិសោធន៍ ក៏ដូចជាទំនាក់ទំនងផ្លូវភេទរបស់នារីណាម្នាក់ណាស់ ពីព្រោះយើងត្រូវចំណាយពេលនិយាយបញ្ចុះបញ្ចូល

ដើម្បីឱ្យពួកគេមានភាពជឿជាក់ជាមុនសិន ប្រសិនបើយើងមិនដែលស្គាល់គ្នាពីមុនមកនោះ។ នាងក៏បានបន្ថែមទៀតថា វាមានការងាយស្រួលច្រើនសំរាប់បុរស ពីព្រោះពួកគេមានឥរិយាបថដូចគ្នា។ ចំណែកអ្នកធ្វើសំភាសន៍ក៏បាននិយាយឱ្យដឹងថាត្រូវការពេលវេលាច្រើនដើម្បីប្រមូលព័ត៌មានដែលត្រូវការ។

***ការបកប្រែ***

ដោយសារតែភាសាអង់គ្លេសជាភាសាទីពីររបស់អ្នកស្រាវជ្រាវ ដូច្នេះគាត់បានព្យាយាមបកប្រែរាល់ទិន្នន័យ ដែលទទួលបាននោះពីភាសាខ្មែរទៅជាភាសាអង់គ្លេស។ ការបកប្រែរវាងភាសាខ្មែរ និងអង់គ្លេស មានការលំបាកក្នុងការកំណត់ន័យ និងការប្រើពាក្យមិនពិតប្រាកដ ហើយអាចងាយនឹងមានការបាត់បង់អត្ថន័យខ្លះ។ ដើម្បីចៀសវាងបញ្ហាខុសឆ្គង អ្នកស្រាវជ្រាវព្យាយាមចំនាយពេលជាមួយនឹងអ្នកដែលប្រើភាសាអង់គ្លេសពីកំណើត ដើម្បីធ្វើការកែសម្រួល។

## ១.៦. អត្ថន័យនៃពាក្យគន្លឹះ

***សង្សារ:*** បើកំណត់តាមអត្ថន័យដើមវិញ ប្រើចំពោះស្ត្រីណាម្នាក់ដែលបានភ្ជាប់ពាក្យរួចហើយ។ សំរាប់ភាសានិយាយជាទូទៅវិញ សំដៅទៅលើស្ត្រីណាម្នាក់ដែលមានទំនាក់ទំនងស្នេហាជាមួយបុរសណាម្នាក់រួចមកហើយ។ ប៉ុន្តែបច្ចុប្បន្ននេះ ពាក្យនេះត្រូវបានគេសំដៅទៅលើទំនាក់ទំនងផ្លូវភេទ ហើយមានតែ២៥ភាគរយប៉ុណ្ណោះដែលអាចឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍។ *[និស្សិតប្រុស]* [២១]

***សង្សារ:*** ពាក្យនេះត្រូវបានគេប្រើប្រាស់នៅពេលអ្នកណាម្នាក់មានសេចក្តីស្នេហាចំពោះគ្នាទៅវិញទៅមក។ សំរាប់ការនិយាយជាទូទៅវិញ នៅពេលការប្រើពាក្យនេះ មានន័យថា គេទាំងពីរអាចនឹងឈានទៅដល់អាពាហ៍ពិពាហ៍ ឬមិនអាច។ *[និស្សិតស្រី]* [២២]

***សង្សារ:*** សំរាប់គូស្នេហ៍/មិត្តប្រុស/មិត្តស្រី[២៣]

**អត្ថន័យនៃពាក្យ "*ភាពទុកចិត្ត*" ឬ "*ភាពជឿជាក់*":** បកស្រាយអំពីលក្ខណៈនៃទំនាក់ទំនងជាមួយនឹងគូស្នេហ៍។ "ក្នុងនោះរួមមាន ភាពស្មោះត្រង់ ជួបគ្នាតាមរយៈក្រុមគ្រួសារ ឬមិត្តភក្តិ ឋានៈក្នុងសង្គម ការងារ ហិរញ្ញវត្ថុ រូបរាង លក្ខណៈសម្បត្តិ និងភាពបរិសុទ្ធ។ សំខាន់ណាស់ដែលត្រូវកត់

[21] Wilkinson, D.J. and Fletcher, *Op cit.*, p. 9.
[22] *Ibid*. p. 10
[23] The researcher decides to use all these words are the same meaning for this study.

ចំណាំថាយុវវ័យឱ្យតំលៃគូស្នេហ៍របស់ខ្លួនគួបផ្សំជាមួយនឹងលក្ខណៈអត្តចរិត ដើម្បីបង្កើនភាពទុកចិត្តរវាងគូស្នេហ៍។ ទោះបីជាយុវវ័យប្រើលក្ខណៈវិនិច្ឆ័យជាច្រើនដើម្បីធ្វើការវិនិច្ឆ័យទៅលើភាពជឿទុកចិត្តក៏ដោយ ក៏ពួកគេហាក់ដូចជាមើលរំលងទៅលើលក្ខណៈវិនិច្ឆ័យមួយចំនួនទៀតដែលជួយធ្វើឱ្យពួកគេអាចកាត់បន្ថយគ្រោះថ្នាក់ជម្ងឺឆ្លងតាមភេទ និងមេរោគអេដស៍ ។"[២៤]

**អត្ថន័យនៃពាក្យ"ការមានទំនងទំនងផ្លូវភេទដោយគ្មានការយល់ព្រម":** ក្នុងនោះមានសកម្មភាពព្យាយាមប៉ុនប៉ងរំលោភ ការប៉ះពាល់ស្ទាបអង្អែលដោយគ្មានការយល់ព្រម ការរំលោភបំពានដូចជាការប្រើពាក្យសំដី ការបង្ខំឱ្យមើលវីដេអូអាសអាភាស ការចាប់រំលោភទាំងកំរោល ការបង្ខំឱ្យរួមភេទ ...។ល។[២៥]

## II. សង្ខេបនៃការសិក្សាមុនៗអំពីឥរិយាបថនៃទំនាក់ទំនងផ្លូវភេទនៅប្រទេសកម្ពុជា

វប្បធម៌របស់ប្រទេសលោកខាងលិចសន្មត់សមភាពរវាងការរួមភេទ និងសិទ្ធិស្មើគ្នាក្នុងការជ្រើសរើសដៃគូស្នេហាក្នុងទំនាក់ទំនងនៃការរួមភេទមុនពេលរៀបការ។ វប្បធម៌របស់ប្រទេសលោកខាងលិចត្រូវបានគេទទួលស្គាល់ថាមានលក្ខណៈ បុគ្គល និងឯករាជ្យ ហើយទាំងបុរស និងស្ត្រីនឹងត្រូវទទួលបានឱកាសស្មើគ្នាក្នុងការធ្វើអ្វីទៅតាមដែលគេចង់ធ្វើ។ ក្នុងនោះក៏មានអ្នកកាន់សាសនាគ្រីស្តខ្លះរក្សាភាពបរិសុទ្ធរហូតដល់ពួកគេរៀបការហើយ មិនតែប៉ុណ្ណោះពួកគេក៏នឹងរក្សាភក្តីភាពចំពោះស្វាមីភរិយារបស់គេទៀតផង។[២៦] នៅសហរដ្ឋអាមេរិក អាត្រានៃស្ត្រីមានផ្ទៃពោះដែលមានវ័យក្មេងធ្លាក់ចុះទាបចាប់តាំងពីឆ្នាំ១៩៩១ ប៉ុន្តែនៅតែរក្សាកំរិតខ្ពស់បើប្រៀបធៀបទៅនឹងជាតិសាសន៍ដែលខ្លាំងផ្នែកឧស្សាហកម្មដទៃទៀត។ ក្មេងស្រីដែលមានអាយុចាប់ពី១៥ទៅ១៩ឆ្នាំជិត១លាននាក់ដែលមានផ្ទៃពោះជារៀងរាល់ឆ្នាំ ឬមានប្រហែល២០ភាគរយនៃស្ត្រីវ័យក្មេងស្ថិតក្នុងក្រុមអាយុនេះដែលសកម្មក្នុងការរួមភេទ។ ភាគច្រើននៃស្ត្រីមានផ្ទៃពោះទាំងនោះ សុទ្ធតែមិនបានគ្រោងទុកទាំងអស់ ហើយអ្នកម្តាយវ័យក្មេងទាំងអស់នោះត្រូវផ្អាកការរៀនសូត្រ និងត្រូវការកិច្ចសង្គ្រោះជាសាធារណៈ ព្រមទាំងរស់នៅក្នុងភាពក្រីក្រ។[២៧]

---

[24] Longfield, K., Klein,M. and Berman, J. (2002). *Working Paper No. 51: Criteria for trust and how trust affects sexual decision-making among youth*, Washington, DC: PSI Research Division, p. 5. Retrieved December 24, 2008 from http://www.psi.org/research/wp/WP51.pdf

[25] Jejeebhoy, J.S. and Bott, S. (2003). *South & East Asia: Non-consensual sexual experiences of young people: A review of the evidence from developing countries*, No.16. New Delhi: Population Council. pp. v-3.

[26] Soprach, T. (2008). *The Impact of Premarital Sex Among Young People in Cambodia*. Phnom Penh: University of Cambodia. p. 8.

[27] Stern, A. (2008, November 3). Study Links Teen Pregnancy To Sexy TV Shows in US. *Reuters*. Retrieved December 10, 2008 from http://www.reuters.com/article/newsOne/idUSTRE4A20HL20081103

ការស្ទាបស្ទង់ស្រាវជ្រាវដែលត្រូវបានធ្វើឡើងដោយសាកលវិទ្យាល័យ Assumption អំពីឥរិយាបថនៃការមានទំនាក់ទំនងផ្លូវភេទរបស់ក្មេងជំទង់ប្រហែលជា២,៣៨៤ នាក់ក្នុងទីក្រុងបាងកកឆ្នាំ២០០៨ បានបង្ហាញឱ្យឃើញថា ក្មេងជំទង់ចំនួន១ភាគ៥ដែលមានទំនាក់ទំនងផ្លូវភេទ ហើយប្រហែល១៥,៤ភាគរយធ្លាប់មានបទពិសោធន៍ក្នុងការរួមភេទ។ នៅក្នុងនោះ ចំនួន៥៨,៨ភាគរយបាននិយាយថា ពេលខ្លះពួកគេក៏មានការរួមភេទបែបសុវត្ថិភាពផងដែរ ខណៈពេលដែលចំនួន ២១,១ភាគរយទៀតមិនធ្លាប់ប្រើប្រាស់ស្រោមអនាម័យនោះទេ។[២៨]

អង្គការសុខភាពពិភពលោក WHO បានបង្ហាញពីលទ្ធផលថ្មីទៀត ចំពោះការប៉ាន់ប្រមាណនៅឆ្នាំ២០០៣ ក្នុងចំណោមស្ត្រី អាយុ១៥ទៅ៤៤ឆ្នាំមានចំនួនដល់ទៅ៤២លាននាក់បានពន្លូតកូន ហើយចំនួន៤៨ភាគរយនៃស្ត្រីក្នុងពិភពលោកសុទ្ធតែមានការរំលូតកូនដោយគ្មានសុវត្ថិភាព និងចំនួនច្រើនជាង៩៧ភាគរយនៃករណីរំលូតកូនដែលគ្មានសុវត្ថិភាពទាំងអស់មាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[២៩] ករណីរំលូតកូនគ្មានសុវត្ថិភាពទាំងអស់មានទាក់ទងនឹងការកើនឡើងនៃអត្រាមរណមាតាក្នុងចំណោមស្ត្រីដែលមានអាយុពី១៥-៤៩ឆ្នាំ នៅក្នុងប្រទេសកម្ពុជាមានចំនួនដល់៤៧២នាក់ស្លាប់ ក្នុងចំណោមទារកកើតរស់១០០,០០០នាក់។[៣០] អង្គការសុខភាពពិភពលោកបានធ្វើការស្ទាបស្ទង់អត្រាមរណមាតា ដោយការរំលូតកូនក្នុងប្រទេសកម្ពុជា គឺមានចំនួន១៣០នាក់ក្នុងចំណោមទារកកើតរស់១០០,០០០នាក់។ ចំនួន៤៥ភាគរយនៃករណីរំលូតត្រូវបានប្រព្រឹត្តនៅផ្ទះ។[៣១] បញ្ហានេះត្រូវបានលើកឡើងដោយគូស្នេហ៍ដែលធ្លាប់មានបទពិសោធន៍ដោយរួមភេទមុនពេលរៀបការដែលបានធ្វើឱ្យនារីជាគូសង្សារមានផ្ទៃពោះ និងបានធ្វើការរំលូតកូនដោយវិធីអសុវត្ថិភាព ដែលជាលទ្ធផលវិញនោះគឺគេបានបញ្ជាក់ថា "នៅថ្ងៃរៀបអាពាហ៍ពិពាហ៍របស់ខ្ញុំ គូដណ្តឹងរបស់ខ្ញុំបានស្លាប់។" នេះជាគ្រោះថ្នាក់នៃការរំលូតកូនដែលគ្មានសុវត្ថិភាព។[៣២]

ករណីមួយរបស់យុវនារីម្នាក់ ដែលបាននិយាយអំពីបទពិសោធន៍មួយរបស់នាងនៃការរួមភេទដោយគ្មានការព្រមព្រៀងគ្នាជាមួយនឹងសង្សារ ដោយសារតែភាពជឿទុកចិត្ត ប៉ុន្តែនៅទីបំផុត*សង្សារ*នាងបោះបង់នាងចោល។ យុវនារីអាយុ១៧ឆ្នាំនេះបានបកស្រាយអំពីការរួមភេទរបស់នាងជាលើកដំបូងកាលពីនាងមានអាយុ១៥ឆ្នាំថាៈ

*"ខ្ញុំដឹងថាសង្សាររបស់ខ្ញុំមិនស្មោះត្រង់នឹងខ្ញុំនោះទេ គឺគេគ្រាន់តែចង់គេងជាមួយខ្ញុំដើម្បីការសប្បាយប៉ុណ្ណោះ.. ពីដំបូង ឥខ្ញុំបដិសេធមិនគេងជាមួយគេទេ ប៉ុន្តែពេលនោះគេប្រើកំលាំងបាយ។*

[28] Ann. (2008, Feb. 11). *Op cit*.
[29] Sedgh, G. et al (2007, October 13). Induced Abortion: Estimated Rates and Trends Worldwide. *Lancet*, Vol. 370, p. 1338
[30] CDHS 2005, *Op. cit.*, p. 120.
[31] *Ibid.* p. 76.
[32] Cambodian Midwives' Association. (1999). Cited by Gender Watch No. 4 (2001). "My wedding day … the day my fiancée died". Phnom Penh: GAD/C. p. 2

*និយាយទៅគេរំលោភខ្ញុំតែម្តង.. គេដោះសំលៀកបំពាក់ខ្ញុំចេញ ហើយព្យាយាមស៊កបញ្ចូលប្រដាប់ភេទរបស់គេ ធ្វើឱ្យខ្ញុំចេញឈាម និងនៅតែឈឺខ្លាំងនៅប៉ុន្មានថ្ងៃក្រោយមកទៀត ។ មិនយូរប៉ុន្មាន គេក៏បោះបង់ចោលខ្ញុំ ។ "*[៣៣]

យោលទៅតាមកត្តាវប្បធម៌សង្គម ប្រសិនបើ*សង្សារ* របស់នាងទៅនិយាយប្រាប់ដល់មិត្តភក្តិ ឬអ្នកដទៃអំពីការរួមភេទ បន្ទាប់ពីគេបោះបង់នាងចោលនោះ នាងនឹងត្រូវបានគេនិយាយថា "ម្ហូបដែលគេ" ។ ពាក្យនេះមានន័យថាម្ហូបដែលគេទទួលទានសល់ និងន័យមួយទៀតគឺសំដៅទៅលើនារីដែលធ្លាប់មានការរួមភេទជាមួយបុរសណាម្នាក់ ហើយជាទូទៅនឹងគ្មានអ្នកណាចង់រៀបការជាមួយនាងឡើយ ។ នៅក្នុងការសិក្សាស្រាវជ្រាវរបស់កញ្ញា Heidi Hoefinger (2008) សំរាប់ថ្នាក់បណ្ឌិត គាត់បានរំលែកអត្ថបទមួយដែលគាត់បានឱ្យចំណងជើងថា "Self-Harming Amoung the Broken-Hearth in Cambodia" ដែលគាត់បានរកឃើញថា នារីវ័យក្មេងមួយចំនួនដែលធ្លាប់មានទំនាក់ទំនងផ្លូវភេទជាមួយនឹងមិត្តប្រុសរបស់គេ មិនថាជាជនជាតិខ្មែរ ឬជនជាតិបរទេសឡើយ បានខូចចិត្ត ធ្វើទុក្ខខ្លួនឯង ហើយថែមទាំងព្យាយាមធ្វើអត្តឃាត ដោយការអារដៃខ្លួនឯង ឬការលេបថ្នាំផ្សេងៗ បន្ទាប់ពីត្រូវមិត្តប្រុសរបស់ខ្លួនបោកប្រាស់ ឬបោះបង់ចោលទៅរកនារីផ្សេងទៀតជាដើម ។ អ្នកស្រីបានបញ្ជាក់ទៀតថា តិរិយាដែលកើតមានបែបនេះទាក់ទងទៅនឹងកត្តាជាច្រើន មានដូចជា ការខូចចិត្ត ការឈឺចាប់ដែលទទួលបានពីការបោះបង់ចោល ការភ័យខ្លាចចំពោះសន្តិសុខរបស់ខ្លួននៅថ្ងៃអនាគត ភាពអស់សង្ឃឹម ការកើតមានគំនុំចង់ធ្វើឱ្យសង្សារខ្លួនឈឺចាប់វិញ ឬអាចមកពីករណីជាច្រើនទៀត ដូចជា ការបាត់បង់ភាពបរិសុទ្ធរបស់ខ្លួន ។[៣៤]

នៅមានការសិក្សាមួយទៀតទាក់ទិនទៅនឹងករណី "*បូក* " ដែលមិនត្រឹមតែកើតមានចំពោះអ្នករកស៊ីផ្លូវភេទតែប៉ុណ្ណោះទេ ប៉ុន្តែក៏កើតមានចំពោះសិស្សសាលាផងដែរ ។ សិស្សវិទ្យាល័យអាយុ២០ឆ្នាំម្នាក់បាននិយាយឱ្យដឹងថា:

*"សំរាប់ខ្ញុំនិងមិត្តភក្តិខ្ញុំក៏ធ្លាប់មានការរួមភេទបូកជាមួយនឹងសិស្សសាលាផងដែរ ។ ខ្ញុំគ្រាន់តែរួមភេទជាមួយនាងដូចជាសង្សារបានប្រហែល២ទៅ៣ដង ខ្ញុំក៏ហៅមិត្តភក្តិឱ្យមករួមភេទបូកជាមួយនាងតែម្តង ។ បន្ទាប់មកទៀត ខ្ញុំក៏ទៅចោលនាង ។"*[៣៥]

ករណី "*បូក*" បានពេញនិយមនិងក្លាយទៅជារឿងធម្មតាមួយសំរាប់យុវជនជំនាន់ក្រោយ ។ ករណីនេះក៏ធ្លាប់បានលើកឡើងនៅឆ្នាំ២០០២ ក្នុងការសិក្សារបស់មិត្តស្រាវជ្រាវពីមិត្ត និងការពិភាក្សាដែលសង្កត់ធ្ងន់ទៅលើករណីនេះក្នុង

---

[33] Tarr, C.M. (1996d). *Study of Contextual Factor Affecting Risk-Related to sexuaBehavior among Young Cambodia.* Phnom Penh: University of Phnom Penh. p. 185.

[34] Hoefinger, H. (2008). *Self-Harming Among the Broken-Hearted in Cambodia.* Unpublished manuscript. Goldsmiths, University of London, UK. Correspondence: h.hoefinger@gold.ac.uk

[35] Bearup, L. S. (2003). *Paupers and Princelings: Youth Attitudes Toward Gangs, Violence,* Rape, Drugs, and Theft. Phnom Penh: GAD/C. p. 91.

ចំណោមនិស្សិតមហាវិទ្យាល័យទាំងអស់។ ពួកគេនិយាយថា "បូក គឺជារឿងធម្មតាសំរាប់ពួកគេ។"[៣៦] បន្ថែមលើសពីនេះ ស្ត្រីរក ស៊ីផ្លូវភេទជាច្រើនដែលទទួលរងការរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈបូកបែបនេះ។ បើផ្អែកតាមក្មេងស្រីអាយុ១៧ឆ្នាំ ដែលជា រស់នៅទីជនបទ ប៉ុន្តែបានក្លាយជានារីរកស៊ីផ្លូវភេទ បាននិយាយថាៈ

> *"ខ្ញុំធ្លាប់ទទួលរងការចាប់រំលោភដោយបូកនេះជាច្រើនដងមកហើយ គឺប្រហែលជា២០ដង... បុរសទាំងនោះបានជេរ វាយដំច្រំធាក់ខ្ញុំ។ ពួកគេនិយាយថា ពួកគេបានឱ្យលុយខ្ញុំពេញថ្លៃ ដូច្នេះពួកគេចង់ធ្វើអ្វីក៏បានដែរ។"*[៣៧]

ថ្មីៗនេះ អង្គការ PSI និង FHI ធ្វើការសិក្សាលើករណីនៃពាក្យថា *"តោះយើងទៅដើរលេង!"* ដែលបុរសភាគច្រើនប្រើដើម្បីបញ្ចុះបញ្ចូលគូសង្សារ រួមទាំងគូសង្សារដែលបំរើការងារផ្នែកកំសាន្តដែលមិនមែនជាស្ត្រីពេស្យាចារ ដោយគិតថាមានសុវត្ថិភាព ឬយ៉ាងហោចណាស់មានសុវត្ថិភាពជាង។ បុរសមួយចំនួនចាប់ផ្តើមគិតថា គូសង្សារដែលជានារីលក់ស្រាបៀរ ឬនារីបំរើការ ងារនៅកន្លែងខារ៉ាអូខេ មិនមានសុវត្ថិភាពប៉ុន្មានឡើយ ហើយងាកមកគិតថា ស្រីក្មេងបរិសុទ្ធសិស្សសាលា និងស្រីក្មេងដែលមកពីទីជនបទមានសុវត្ថិភាពជាង។ ដូច្នេះបុរសដែលស្វែងរកការសប្បាយផ្លូវកាមចាប់ផ្តើមស្វែងរកដៃគូសង្សារណាម្នាក់ដែលផ្តល់សុវត្ថិភាពខ្ពស់ដល់គេ ដោយមិនចាំបាច់ប្រើស្រោមអនាម័យពេលរួមភេទ។ ហើយពួកគេក៏នឹងបន្តស្វែងស្រីក្មេងបរិសុទ្ធយ៉ាងដូច្នេះតទៅទៀត។[៣៨]

ការសិក្សាបែបគុណភាពវិស័យមុនៗដែលទាក់ទិនទៅនឹងការរួមភេទមុនពេលរៀបការក្នុងចំណោមយុវវ័យមានអាយុចន្លោះ១៥ទៅ២៤ឆ្នាំ (ដោយក្នុងនោះមានចំនួន១៨៤៦នាក់បានយល់ព្រមឆ្លើយនឹងសំនួរទាក់ទងទៅនឹងឥរិយាបទរួមភេទ)។ ការសិក្សានោះបានបង្ហាញឱ្យឃើញថា ចំនួន៣៤,៣ភាគរយធ្លាប់មានបទពិសោធន៍រួមភេទ ខណៈពេលដែល២៨,៥ភាគរយនៃបុរសនៅលីវធ្លាប់មានការរួមភេទ ប្រៀបធៀបទៅនឹងស្ត្រីនៅលីវចំនួន១,0ភាគរយ។ ការសិក្សានេះក៏បានបង្ហាញឱ្យដឹងផងដែរថាចំនួន១២,២ភាគរយនៃក្រុមមនុស្សនោះស្គាល់អត្ថន័យនៃពាក្យ *បូក* ដែលក្នុងនោះមានយុវវ័យរស់នៅក្នុងទីក្រុងស្គាល់ការរួមភេទបូកនេះ(៣0,0ភាគរយ)ច្រើនជាងយុវវ័យនៅទីជនបទ(៥,៧ភាគរយ)។[៣៩] មានការស្ទាបស្ទង់មួយជាលក្ខណៈជាតិអំពីឥរិយាបថយុវវ័យកម្ពុជាង (ពីអាយុ១១-១៨ឆ្នាំ និង n = ៩,៣៨៨) បង្ហាញថាយុវវ័យចំនួន១៤៨នាក់ធ្លាប់រួមភេទ ក្នុងនោះចំនួន៣២,៤ភាគរយមិនធ្លាប់ប្រើស្រោមអនាម័យ និង១ភាគ៣ធ្លាប់រួមភេទបូក។[៤0]

---

[36] Wilkinson, D. J and Fletcher, G, Op. cit., p. 30.

[37] Doyle, K. and Samean, Y. (2003, April 19-20). Youth of Today: Gang Rape Has Become the Sport of the Young Generation. *Cambodia Daily*, p. 1.

[38] Smith, R. (2007). *Let's Go for a Walk: Sexual Decision-Making among Clients of Female Entertainment Service Workers in Phnom Penh*. Phnom Penh: PSI & FHI, p. 26.

[39] Ramage, I. (2004). *Cambodia Baseline Survey*. Phnom Penh: RHIYA Project, EU/UNFPA. pp. 70-78.

[40] Sunran, K. (2004). *Cambodia National: Youth Risk (11-18 years) Behaviour Survey*. Phnom Penh: MoEYS, UNICEF & UNESCO. pp. 5-7.

បុរសអាចស្វែងរកការសប្បាយផ្លូវភេទ ដោយមិនចាំបាច់មានឋានៈមុខមាត់ក្នុងសង្គមឡើយ ខណៈដែលស្ត្រីវិញ ក៏ត្រូវបានគេគិតថាអាចស្វែងរកការសប្បាយផ្លូវភេទបានផងដែរ ប៉ុន្តែពួកគេពុំមានឱកាសដើម្បីចេញទៅខាងក្រៅ និងមិនអាចស្វែងរកសេវាកម្មផ្លូវភេទបានឡើយ។ ចំពោះការស្ទាបស្ទង់ទៅលើបុរសអ្នករត់ម៉ូតូឌុបវិញ[៤១] មានចំនួនដល់ទៅ៧២,៦ភាគរយដែលធ្លាប់បានលឺអំពីការរួមភេទបូក ហើយក៏បានដឹងផងដែរថា ភាគច្រើនជាក្មេងស្ទាវដែលមានការរួមភេទបូកបែបនេះ។ ការសិក្សានេះបានធ្វើការសំភាសន៏ជាមួយនឹងបុរសអ្នករត់ម៉ូតូឌុបចំនួន១៩២នាក់ ដែលធ្វើការនៅពេលយប់នៅមុខបារខារ៉ាអូខេ ផ្ទះបន និងនៅពេលព្រឹកនៅមុខសណ្ឋាគារ ផ្ទះសំនាក់ ក្នុង២០ខេត្ត និង៤ក្រុងផ្សេងទៀតក្រៅពីទីក្រុងភ្នំពេញ។ បន្ថែមលើសពីនេះទៀត ការសិក្សាលើយុវវ័យនៅក្នុងក្រុងភ្នំពេញមួយទៀតបានបង្ហាញថា ចំនួននិស្សិតប្រុសដល់ទៅ៦០ភាគរយបានស្គាល់គ្នាជាមួយអ្នកដែលរួមភេទបូក។[៤២] ឪពុកម្តាយរបស់យុវវ័យកម្ពុជាជាច្រើនដែលមានបំណងចង់រក្សានូវតំលៃវប្បធម៌ខ្មែរបានបង្ហាញពីអារម្មណ៏សោកស្តាយថា យុវវ័យកម្ពុជាបច្ចុប្បន្នពុំបានយកចិត្តទុកដាក់ទៅនឹងតំលៃវប្បធម៌ខ្មែរនោះឡើយ។ បុរសអាយុ៦៧ឆ្នាំ ដែលមានមុខរបរជាអ្នកធ្វើស្រែចំការបានបង្ហាញពីចំណាប់អារម្មណ៏ថា:

> *"បច្ចុប្បន្ន ក្មេងៗពុំមានការគោរពចំពោះលោកគ្រូអ្នកគ្រូ និងព្រះសង្ឃឡើយ... ប៉ុន្តែសំរាប់បញ្ហាដែលទាក់ទិនទៅនឹងចំណេះដឹងផ្នែកផ្លូវភេទ ជាពិសេសសកម្មភាពផ្លូវភេទ យុវវ័យយើងរៀនពីគ្នាបានលឿនណាស់។ ប្រសិនបើកូនប្រុសរបស់ខ្ញុំណាម្នាក់ទាក់ទងជាមួយនារីដែលមានផ្ទៃពោះមុនពេលរៀបការនោះ ខ្ញុំនឹងកាត់កាលចោល ហើយប្រសិនបើវានៅតែរឹងទទឹងរៀបការជាមួយក្មេងស្រីនោះទៀត យល់ល្អខ្ញុំ ត្រូវតែកាត់កាលវាចោល។"* [៤៣]

កាលពីពេលថ្មីៗនេះ គម្រោង RHIYA បានបញ្ចប់ការសិក្សាបែបគុណភាពវិស័យមួយ ដែលក្នុងនោះមានការស្រង់មតិទស្សនៈរបស់ឪពុកម្តាយរបស់យុវវ័យជំនាន់ក្រោយអំពីការរួមភេទមុនពេលរៀបការ។ បុរសម្នាក់អាយុ៤៨ឆ្នាំរស់នៅទីក្រុងភ្នំពេញបាននិយាយឱ្យដឹងថា:

> *"ឪពុកម្តាយទាំងអស់នឹងមិនអនុញ្ញាតិឱ្យកូនស្រីរបស់ខ្លួនមានការណាត់ជួបគ្នាមុនពេលរៀបការនោះទេ។ ទោះបីជាវាមិនសមហេតុផលប្រសិនបើនិយាយទៅលើសិទ្ធិស្មើគ្នាក៏ដោយ។ ស្ត្រីក៏ត្រូវការមានទំនាក់ទំនងនៃការរួមភេទដូចគ្នានឹងបុរសផងដែរ។ បើនិយាយអំពីប្រពៃណីខ្មែរវិញ វាមិនត្រឹមត្រូវឡើយ ប៉ុន្តែក្នុងសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី គួរតែធ្វើឱ្យមានការផ្តល់ជាចំណេះដឹងអំពីបញ្ហានេះ*

---

[41] Soprach, T. (2004). *GANG RAPE: The Perspective of Moto-Taxi Drivers across Cambodia.* Phnom Penh: Playing Safe Project, CARE Cambodia, EU/UNFPA. p. 19.
[42] Bearup, L. S., *Op. cit.*, p. 30.
[43] Tarr, C. M. (1996b), *Op. cit.*, p. 69.

*ដល់ស្ត្រីដើម្បីការពារខ្លួន ប្រសិនបើពួកគេចង់មានទំនាក់ទំនងផ្លូវភេទ ដូចជាការប្រើស្រោមអនាម័យ និងការពារកុំឱ្យមានផ្ទៃពោះ ជាដើម ។"*[៤៤]

## III. វិធីសាស្ត្រ

### ៣.១. វិធីសាស្ត្របែបគុណភាពវិស័យនៃការសិក្សារបស់មិត្តស្រាវជ្រាវពីមិត្ត

ការសិក្សាបែបគុណភាពវិស័យនេះផ្តោតទៅលើគូស្នេហ៍ក្នុងអាយុរវាង១៥-២៤ឆ្នាំក្នុងទីក្រុងភ្នំពេញ ដែលមានការរួមភេទមុនពេលរៀបការ និងចេញដើរកំសាន្តនៅថ្ងៃបុណ្យសង្សារ ។ ការសិក្សាមិត្តស្រាវជ្រាវពីមិត្តនេះធ្វើទៅតាមវិធីសាស្ត្រប្រកបដោយភាពជោគជ័យពីរនៃការសិក្សាមិត្តស្រាវជ្រាវពីមិត្ត PSI ចំពោះឥរិយាបថនៃការរួមភេទក្នុងចំនោមនិស្សិតប្រុស និងស្ត្រីរកស៊ីផ្លូវភេទ[៤៥] ព្រមទាំងយុវវ័យស្ថិតក្នុងគ្រួសារធូរធារក្នុងទីក្រុងភ្នំពេញ ។[៤៦]

ការងារបែបសិក្សាស្រាវជ្រាវដែលព្យាយាមបកស្រាយទៅលើក្រុមមនុស្សដែលមានវ័យស្មើគ្នា ។ ការសិក្សានេះផ្តោតទៅលើចំណុចសំខាន់នៃក្រុមវប្បធម៌ដែលត្រូវបានប្រមូលចងក្រងជាការប្រមូលផ្តុំមួយដ៏ធំចាប់ផ្តើមតាំងពីឆ្នាំ១៩៣០ ក្រោមចំណងជើងថា Human Relations Areas Files ។[៤៧] មិត្តស្រាវជ្រាវពីមិត្តត្រូវរៀនពីសមាជិកក្នុងក្រុមនៃសង្គម ឬបណ្តាញនៃសង្គមដើម្បីក្លាយទៅជាមិត្តស្រាវជ្រាវពីមិត្តសំរាប់ការស្រាវជ្រាវ(PERs) (Hawkins & Price 2000c, 2000b) ។ មិត្តស្រាវជ្រាវពីមិត្តសំដៅទៅលើមនុស្សដែលជាសមាជិកក្នុងសង្គមជាមួយគ្នា ហើយមានបណ្តាញទំនាក់ទំនងដូចគ្នា មានដូចជា មិត្តភក្តិ មិត្តធ្វើការជាមួយគ្នា មិត្តរួមសាលា មនុស្សមានវ័យស្របាលគ្នា ញាតិសន្តាន ឬអ្នកជិតខាង ។ ពួកគេទាំងនោះបានបង្កើតជាទំនាក់ទំនងមួយរួចហើយមុនពេលនឹងជ្រើសរើសសំរាប់ការសាកសួរ ។ វិធីសាស្ត្រផ្អែកលើការសិក្សាអំពីការធ្វើទំនាក់ទំនងជាមួយមនុស្សម្នាក់ ដែលត្រូវបង្កើតឱ្យមានការជឿទុកចិត្តជាមុនសិនរវាងសហគមន៍ និងមិត្តស្រាវជ្រាវពីមិត្ត ។[៤៨] មិត្តស្រាវជ្រាវពីមិត្តប្រតិបត្តិការសន្ទនាជាលក្ខណៈបុគ្គលជាមួយនឹងការបញ្ជាក់ប្រាប់អំពីអត្តសញ្ញាណខ្លះៗពីក្រុមមិត្តក្នុងបណ្តាញរបស់គេ ។

### ៣.២. ការបណ្តុះបណ្តាលពីការសិក្សាស្រាវជ្រាវរបស់មិត្តស្រាវជ្រាវពីមិត្តអប់រំមិត្ត

អ្នកស្រាវជ្រាវពីមិត្តទាំងអស់គឺជាក្រុមអ្នកស្ម័គ្រចិត្ត ដែលធ្លាប់ជាអតីតអ្នកហ្វឹកហាត់ និងជាមិត្តអប់រំមិត្តសំរាប់គម្រោងប្រព្រឹត្តដោយសុវត្ថិភាព ដែលជាដៃគូជាមួយនឹង CARE International និង KYA ។ ពួកគេត្រូវបានផ្តល់ការ

---

44 Vuthy, B. (2006). *RHIYA Cambodia Endline Qualitative Survey*. Phnom Penh: EU/UNFPA. p. 47

45 Wilkinson, D. J and Fletcher, G, *Op. cit.*, pp. 4-5.

46 Hayden, R. (2006). *Young Men Like Us: Experiences and Changes in Sex, Relationships and Reproductive Health among Young, Urban Cambodian Men*. Phnom Penh: Peer Ethnographic Research on Urban Male Sexual Behaviour. Playing Safe Project, CARE Cambodia, KYA, EU/UNFPA. p. 16.

47 Baker, L.T. (1994). *Doing Social Research*. California State University, San Marcos: McGraw-Hill, Inc. p. 237

48 Wilkinson, D. J and Fletcher, G, *Op. cit.*, pp. 4-5.

ហាត់រៀនយល់ដឹងអំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព ហើយធ្លាប់មានបទពិសោធន៍លើបញ្ហានេះជាមួយនឹងក្រុមមិត្តភក្តិរបស់គេ។ ទោះបីជាយ៉ាងណាក៏អ្នកស្រាវជ្រាវព្យាយាមចំនាយពេលយ៉ាងហោចណាស់បីម៉ោងជាមួយនឹងមិត្តអ្នកស្រាវជ្រាវពីមិត្តម្នាក់ៗក្នុងការពន្យល់ពីគោលបំណងនៃការសិក្សានេះដើម្បីឆ្លើយទៅសំនួរ និងបង្កើតឱ្យមានការយល់កាន់តែច្បាស់ចំពោះអ្នកផ្តល់បទសំភាសន៏ និងធ្វើតេស្តសាកល្បងជាមុនសំរាប់សំនួរនៃការស្រាវជ្រាវនេះ*(សូមមើលសេចក្តីបន្ថែមលេខ១)*។

## ៣.៣. ការប្រមូលទិន្នន័យ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជាពីរដំណាក់កាលៈ ការសង្កេតស្វែងយល់ និងការចុះធ្វើសំភាសន៏ ក្នុងនោះមានទាំងការកត់អាកប្បកិរិយាអ្នកផ្តល់បទសំភាសន៏។

### *- ការសង្កេតស្វែងយល់*

សមាជិកអ្នកស្រាវជ្រាវពីមិត្តទាំងអស់ និងអ្នកស្រាវជ្រាវត្រូវបានអនុញ្ញាតិឱ្យធ្វើការស្វែងយលថាតើមិត្តភក្តិដែលជាអ្នកផ្តល់បទសំភាសន៏ និងគូសង្សាររបស់គេចាប់ផ្តើមនៅជាមួយគ្នាដោយរបៀបណា ព្រមទាំងសកម្មភាពយុវ័យផ្សេងទៀតនៅទីក្រុងភ្នំពេញនៅថ្ងៃបុណ្យសង្សារទី១៤ខែកុម្ភៈឆ្នាំ២០០៨។ បន្ទាប់មក អ្នកផ្តល់បទសំភាសន៏នឹងត្រូវបានមិត្តស្រាវជ្រាវពីមិត្តសុំលេខទូរស័ព្ទដើម្បីទំនាក់ទំនង ឬធ្វើការណាត់ជួបសំរាប់ការសំភាសន៏មួយសប្តាហ៏ក្រោយមក ក្រោយថ្ងៃបុណ្យនោះ។

### *- ការប្រតិបត្តិនៃការធ្វើបទសំភាសន៍*

រយៈពេលមួយសប្តាហ៍បន្ទាប់ពីថ្ងៃបុណ្យសង្សារ មិត្តអ្នកស្រាវជ្រាវពីមិត្តទាំងអស់ត្រូវធ្វើការណាត់ជួបជាមួយនឹងអ្នកផ្តល់បទសំភាសន៏ និងគូសង្សាររបស់គេ ដើម្បីធ្វើកិច្ចសន្ទនាបែបស៊ីជម្រៅអំពីអ្វីដែលពួកគេបានប្រព្រឹត្តនៅថ្ងៃបុណ្យសង្សារកន្លងទៅ។ មិត្តស្រាវជ្រាវពីមិត្តម្នាក់ៗត្រូវបានធ្វើការសំភាសន៏សាកល្បងជាមួយនឹងអ្នកស្រាវជ្រាវ ដើម្បីផ្តល់ការពន្យល់ និងវិចារណ៏ខ្លះៗលើព័ត៌មាន ស្របពេលដែលអ្នកស្រាវជ្រាវផ្តល់ជាយោបល់ខ្លះៗជាបន្ថែមដោយទូរស័ព្ទទៅមិត្តអ្នកស្រាវជ្រាវពីមិត្តទាំងអស់។ អ្នកធ្វើកិច្ចសំភាសន៏ត្រូវធ្វើកិច្ចសន្ទនាជាមួយនឹងអ្នកផ្តល់សំភាសន៏ដែលមានភេទដូចគ្នា។

## ៣.៤. ការវិភាគទិន្នន័យ

ទិន្នន័យទាំង១៦ករណីដែលប្រមូលបាន(ប្រុស១១ និងស្រី៥) ត្រូវបានវិភាគ និងរៀបចំជាឯកសារ។ អ្នកស្រាវជ្រាវបកប្រែ និងវិភាគទិន្នន័យដែលប្រមូលបានដោយមានភ្ជាប់ជាមួយនឹងឯកសារយោង ទៅនឹងគោលបំណងនៃការសិក្សានេះ។

### ៣.៥. វេចាយការណ៍

លទ្ធផលនៃរបាយការណ៍នេះត្រូវបានផ្តោតសំខាន់ទៅលើសកម្មភាពរបស់យុវវ័យ សេចក្តីស្នេហា និងទំនាក់ទំនងផ្លូវភេទរបស់ពួកគេនៅក្នុងថ្ងៃបុណ្យសង្សារ។ ឈ្មោះអ្នកផ្តល់បទសំភាសន៍ជារហស្សនាម ឬឈ្មោះដែលគេស្រលាញ់ក្រៅពីឈ្មោះពិតប្រាកដ និងទីកន្លែងដែលមិត្តអ្នកស្រាវជ្រាវពីមិត្តបានជួប ឬបានឃើញអ្នកផ្តល់បទសំភាសន៍។ ការសិក្សានេះរក្សាសិទ្ធនៅក្នុងការប្រើឈ្មោះរហស្សនាម ឬឈ្មោះដែលស្រលាញ់ និងទីកន្លែង ដើម្បីចៀសវាងការភ័ន្តច្រលំនៅពេលពាក្យសម្តីរបស់ពួកគេត្រូវបានដកស្រង់។

## IV. លទ្ធផល

### ៤.១. សកម្មភាព សេចក្តីស្នេហា និងទំនាក់ទំនងផ្លូវភេទរបស់យុវវ័យនៅថ្ងៃបុណ្យសង្សារ

### ៤.១.១. អំពីថ្ងៃបុណ្យសង្សារ

កាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ថ្ងៃបុណ្យសង្សារត្រូវបានប្រារព្ធឡើងក្នុងចំណោមយុវវ័យនៅក្នុងទីក្រុងមួយចំនួន ជាពិសេសនៅទីក្រុងភ្នំពេញ តាមរយៈសកម្មភាពជាច្រើនបែប។ យុវវ័យមិនសូវជាយល់ច្បាស់អំពីប្រវត្តិនៃថ្ងៃបុណ្យសង្សារនោះទេ ប៉ុន្តែពួកគេគ្រាន់តែដឹងថា សារសំខាន់នៃថ្ងៃនោះគឺជាថ្ងៃពិសេសសំរាប់សេចក្តីស្រលាញ់។

> *"ថ្ងៃបុណ្យសង្សារ សំរាប់យុវវ័យសំដៅទៅលើថ្ងៃបង្ហាញពីសេចក្តីស្រឡាញ់ទៅកាន់សង្សាររបស់ខ្លួន ឬជាថ្ងៃនៃក្តីស្រលាញ់។ យុវវ័យផ្សេងទៀតក៏ដូចជាខ្ញុំផងដែរ ដោយពួកយើងមិនសូវជាដឹងច្បាស់អំពីថ្ងៃនោះទេ ព្រោះថ្ងៃនោះមិនមែនជាថ្ងៃបុណ្យជាតិរបស់យើងផង ដូច្នេះមិនសូវមាននរណាខ្វល់ពីរឿងនេះទេ។ ប៉ុន្តែ ខ្ញុំគិតថាវាក៏សប្បាយម្យ៉ាងដែរ ដោយយើងអាចបញ្ជាក់ពីក្តីស្រលាញ់ដែលយើងមាន។" **[ណាក់ អាយុ២២ ឆ្នាំ ភេទប្រុស ជានិស្សិត, តែគុជ Kiss ]***

> *"ខ្ញុំនិងមិត្តភក្តិ ក៏ដូចជាយុវវ័យដទៃទៀតចូលរួមប្រារព្ធថ្ងៃបុណសង្សារនេះ ក៏ព្រោះតែយល់ថាវាជាថ្ងៃសប្បាយមួយ និងជាថ្ងៃដែលពេញនិយមសំរាប់យុវវ័យ។" **[តូ អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, សួនច្បារមាត់ទន្លេ]***

> *"ខ្ញុំយល់ឃើញថាថ្ងៃបុណ្យសង្សារ ជាថ្ងៃដែលត្រូវបានបង្កើតឡើងសំរាប់មនុស្សជាទីស្រលាញ់ ដូចជាឪពុកម្តាយ បងប្អូន យាយតា មិត្តភក្តិ និងគូសង្សារ ប៉ុន្តែសំរាប់ប៉ាម៉ាក់ និងយាយតា គាត់មិនរវល់រឿងថ្ងៃនៃសេចក្តីស្រលាញ់អីនោះទេ ពីព្រោះគាត់យល់ថាវាគ្មានសារសំខាន់អ្វីនោះទេ។*

*មានតែយុវវ័យ ប៉ុណ្ណោះដែលចាប់អារម្មណ៍ ជាពិសេសសំរាប់អ្នកដែលមានសង្សារ។ "* ***[អាលី អាយុ២៣ឆ្នាំ ភេទស្រី ជានិស្សិត, នៅផ្ទះជួលមិត្តភក្តិម្សៅទួលទំពូង]***

អ្នកផ្តល់បទសំភាសន៍ខ្លះបាននិយាយថា ពួកគេមិនសូវដឹងអំពីថ្ងៃនៃសេចក្តីស្រលាញ់នោះប៉ុន្មានទេ ហើយពួកគេគ្រាន់តែធ្វើតាមមិត្តភក្តិរបស់គេដើម្បីការសប្បាយតែប៉ុណ្ណោះ:

*"កាលពីថ្ងៃបុណ្យសង្សារកន្លងមកថ្មីៗនេះ ខ្ញុំនិងសង្សារក៏មិនខុសពីយុវវ័យផ្សេងៗដែរ។ ខ្ញុំគិតថាសំរាប់ថ្ងៃនោះ ពួកយើងគ្រាន់តែធ្វើតាមគ្នាតែប៉ុណ្ណោះ។"* ***[ប្រុស អាយុ២៤ឆ្នាំ ភេទប្រុស ជាបុគ្គលិកក្រុមហ៊ុន, ផ្សារទំនើបសូរិយា]***

ខណៈនេះដែរ មានយុវវ័យជាច្រើននាក់ដែលនាំគ្នាធ្វើតាមគ្នាក្នុងថ្ងៃបុណ្យសង្សារនោះ ហើយបានធ្វើតាមគ្នាអំពីថ្ងៃនោះតាមរយៈវប្បធម៌ បរទេស វីដេអូ ប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន អ៊ីនធឺរណេត និងសំលៀកបំពាក់សិចស៊ីជាដើម។ យុវជននិងយុវនារីគ្រាន់តែដឹងថា:

*"តាមការយល់ដឹងរបស់ខ្ញុំ ថ្ងៃបុណ្យសង្សារជាថ្ងៃពិសេសមួយអាចឱ្យយើងបង្ហាញនូវសេចក្តីស្រលាញ់របស់យើង ដូចជាយុវវ័យដទៃទៀតផងដែរ។ ខ្ញុំក៏តែងតែឃើញគេធ្វើឡើងជារៀងរាល់ឆ្នាំ ហើយបើតាមខ្ញុំដឹងដូចជាតាំងពីឆ្នាំ២០០០មកម្ល៉េះ ពីព្រោះខ្ញុំបានមើលខ្សែភាពយន្តភាគថៃ និងរឿងហុងកុង។ ដូច្នេះ វាបានសាយភាយទូទាំងប្រទេសខ្មែរ ធ្វើឱ្យយុវវ័យជាច្រើនជ្រួលច្របល់គ្រប់គ្នា និងថែមទាំងធ្វើឱ្យអ្នកលក់ផ្កាឆ្លៀតឱកាសលក់ផ្កាបានក្នុងតំលៃខ្ពស់ទៀតផង គឺផ្កាកូលាបមួយទងគេអាចលក់បានក្នុងតំលៃដល់ទៅ៣ដុល្លារឯណោះ។"* ***[សំ អាយុ២៤ឆ្នាំ ភេទប្រុស ជាអ្នករកស៊ី, វត្តភ្នំ]***

*" តាមយោបល់ខ្ញុំ នៅថ្ងៃនោះយុវវ័យភាគច្រើនធ្វើតាមគ្នាទៅវិញទៅមក និងតាមការហូរចូលពីវប្បធម៌បរទេស មានដូចជាភាពយន្ត ទស្សនាវដ្តី កាសែត សំលៀកបំពាក់ជាដើម។ "* ***[រ៉ាស៊ី អាយុ១៩ឆ្នាំ ភេទស្រី ជាសិស្សវិទ្យាល័យ, សួនច្បារមាត់ទន្លេ]***

*" សំរាប់ខ្ញុំវិញមិនបានដឹងច្បាស់អំពីថ្ងៃនោះដែរ គ្រាន់តែដឹងថាជាថ្ងៃសង្សារ ហើយឃើញគេជូនផ្កាឱ្យសង្សារគេរៀងៗខ្លួន ដូច្នេះខ្ញុំក៏ធ្វើតាមពួកគេតែម្តងទៅ។ "* ***[ញ៉ាញ់ អាយុ២៣ឆ្នាំ ភេទប្រុស កំពុងរកការងារធ្វើ, សួនច្បារមាត់ទន្លេ]***

### ៤.១.២. ពេលព្រឹកនៅថ្ងៃបុណ្យសង្សារ

នៅពេលព្រឹកក្នុងថ្ងៃបុណ្យសង្សារ ជាទូទៅយុវវ័យភាគច្រើនតែងតែនិយមនាំគ្នាទិញផ្កា ឬកាដូផ្សេងៗសំរាប់ជូនសង្សាររបស់គេជាងពេលផ្សេងៗ ។ យុវនារីម្នាក់និយាយពីសកម្មភាពនៅព្រឹកថ្ងៃបុណ្យសង្សាររបស់ខ្លួនថា:

> *"ខ្ញុំនិងសង្សារតែងតែចេញទៅដើរលេងជាមួយគ្នាជានិច្ច ។ នៅថ្ងៃបុណ្យនៃសេចក្ដីស្រលាញ់កន្លងទៅថ្មីៗនេះ គាត់បានជូនផ្កាកុលាបពណ៌ក្រហមមួយទងមកខ្ញុំ ព្រមទាំងថើបខ្ញុំទៀតផង ។ "* ***[អាលី អាយុ២៣ឆ្នាំ ភេទស្រី និស្សិត, ផ្ទះជួលមិត្តភក្ដិនៅម៉ូទូលទំពូង]***

យុវជនម្នាក់ព្យាយាមសុំសង្សាររបស់គេរួមភេទ ដោយការទិញកាដូ និងផ្កាឱ្យនាង បានលើកឡើងថា:

> *"នៅថ្ងៃបុណ្យសង្សារ ខ្ញុំនិងនាងបាននាំគ្នាទៅមើលកុននៅផ្សារទំនើបសូរិយា និងទៅញ៉ាំ Pizza ហើយបានទិញកាបូបមួយឱ្យនាង ចំណែកនាងបានទិញអាវឱ្យខ្ញុំមួយវិញ ចំពោះផ្កា ខ្ញុំបានជូននាងតាំងពីព្រឹក ។ នៅថ្ងៃនោះ ខ្ញុំពិតជាចង់គេងជាមួយនាង មិនថាពេលនោះទេ គឺរាល់ពេលខ្ញុំនៅជាមួយនាង ខ្ញុំតែងតែមានចំនង់ជានិច្ច ប៉ុន្តែនាងបង្ហាញកាយវិការមកវិញថា ដាច់ខាតគឺទេ ទោះបីជាខ្ញុំព្យាយាមប៉ះនាងពីខាងក្រៅយ៉ាងណាក៏ដោយ ទោះបីជាពេលនៅក្នុងបន្ទប់ខារ៉ាអូខេដែលជិតងងឹត ងាយស្រួល មិនភ័យខ្លាចគេឃើញគេលឺនោះក៏ដោយ ។ ខ្ញុំបានចូលរួមនៅក្នុងថ្ងៃបុណ្យសង្សារ ដោយសារខ្ញុំគិតថា ជាថ្ងៃសប្បាយរីករាយមួយ និងពោរពេញដោយភាពរ៉ូមែនទិកដូចជាពួកបរទេស ។ "* ***[មេត្រី អាយុ ២២ឆ្នាំ ភេទប្រុស និស្សិត និងបុគ្គលិកក្រុមហ៊ុន, រោងភាពយន្តស៊ីណេម៉ាសូរិយា]***

ការជូនផ្កា ឬកាដូគឺជាការចាប់ផ្ដើមបង្កើតនូវសេចក្ដីស្រលាញ់ និងទំនាក់ទំនងផ្លូវភេទ ក្នុងចំណោមយុវវ័យនៅក្នុងថ្ងៃបុណ្យសង្សារ ។

### ៤.១.៣. ពេលរសៀលនៅថ្ងៃបុណ្យសង្សារ

នៅពេលរសៀល គូស្នេហ៍យុវវ័យជាច្រើនបានប្រព្រឹត្តសកម្មភាពខុសៗគ្នា ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅពេលរសៀលដែលជាពេលក្ដៅបន្តិចនោះ ពួកគេចូលចិត្តស្វែងរកទីកន្លែងកំសាន្តដូចជា ក្លឹប ហាងតែគុជ រោងភាពយន្ត ក្លឹបខារ៉ាអូខេ ផ្ទះសំណាក់ជាដើម ។ អ្នកខ្លះបានលើកឡើងអំពីទំនាក់ទំនងរបស់គេដូចតទៅ:

*"នៅថ្ងៃបុណ្យសង្សារនោះ ខ្ញុំបានទៅទទួលសង្សារខ្ញុំនៅម៉ោង១រសៀលដើម្បីដើរលេងបន្ត។ នៅមុនពេលទៅទទួលនាង ខ្ញុំបានទិញផ្កាកុលាប១បាច់តំលៃ១២ដុល្លារជូននាង។ នាងពិតជាសប្បាយចិត្តខ្លាំងណាស់នៅពេលនាងទទួលយកផ្កាពីខ្ញុំ។ ខ្ញុំមើលទៅគូស្នេហ៍ដទៃទៀតក៏ដូចជាខ្ញុំដែរ។ ខ្ញុំនិងនាងបាននាំ គ្នាទៅតែគុជ Kiss ដើម្បីញុំាអីរហូតដល់ម៉ោង៦ល្ងាច។"* ***[ណាក់ អាយុ២២ឆ្នាំ ភេទប្រុស និស្សិត, តែគុជ Kiss ]***

*" នៅថ្ងៃនោះ នាងបានមកយកខ្ញុំនៅម៉ោង១រសៀល ដើម្បីជិះម៉ូតូដើរលេងបន្តិច ហើយទៅរាំនៅ CASA Club រហូតដល់ម៉ោង៤រសៀល ទើបបន្តទៅញុំាអីនៅម៉ង់ដូជិត Hong Kong Center ។ "* ***[តូច អាយុ២៣ឆ្នាំ ភេទប្រុស បុគ្គលិកកាស៊ីណូ, Casa Club ពេលរសៀល]***

*"នៅថ្ងៃបុណ្យសង្សារថ្មីៗនេះ ខ្ញុំនិងគាត់បានចំណាយពេលនៅជាមួយគ្នា ឯផ្ទះជួលរបស់មិត្តភក្តិដែលជាអ្នកស្រុកជាមួយគ្នានៅម្តុំទួលទំពូង។"* ***[អាលី អាយុ២៣ឆ្នាំ ភេទស្រី និស្សិត, ផ្ទះជួលរបស់មិត្តភក្តិនៅម្តុំទួលទំពូង]***

ទោះបីជាយ៉ាងណាក៏ការមានទំនាក់ទំនងផ្លូវភេទអាចកើតមានគ្រប់ពេលវេលា។ យ៉ាងហោចណាស់ពាក់កណ្តាលនៃយុវវ័យដែលមានគូសង្សារបានរួមភេទនៅថ្ងៃបុណ្យសង្សារនោះបានផ្តល់ការសំភាសន៏សំរាប់ការសិក្សានេះថាពួកគេបានរួមភេទនៅពេលរសៀលក្នុងថ្ងៃបុណ្យសង្សារ។ យុវជនម្នាក់បានបកស្រាយថា:

*" នៅថ្ងៃបុណ្យសង្សារ ឬថ្ងៃបុណ្យនៃសេចក្តីស្រលាញ់ ខ្ញុំបានទិញផ្កាមួយបាច់ជូននាងដើម្បីរំលឹកចំណងសេចក្តីស្នេហារបស់យើងទាំងពីរ ហើយប្រាប់នាងថា នាងជានារីម្នាក់គត់នៅក្នុងបេះដូងខ្ញុំ។ បន្ទាប់មកយើងនាំគ្នាទៅកៀនស្វាយ សំរាកក្នុងខ្ទមជិតមាត់ទឹក ហើយបានញុំាអាហារថ្ងៃត្រង់ជាមួយគ្នាយ៉ាងឆ្ងាញ់ ក្រោយមកក៏បានរួមភេទជាមួយគ្នានៅទីនោះតែម្តង។ នាងយល់ព្រមជាមួយខ្ញុំដោយសារតែយើងធ្លាប់រួមភេទជាមួយគ្នាតាំងពី២០០៦មកម្លេះ ហើយយើងតែងតែប្រើស្រោមអនាម័យជានិច្ចដើម្បីការពារពីការមានផ្ទៃពោះ និងការឆ្លងរោគផ្សេងៗដែលអាចកើតមានជាយថាហេតុ។ ខ្ញុំដឹងពីបញ្ហាសុខភាពបន្តពូជ ហើយក៏ធ្លាប់ធ្វើអ្នកអប់រំមិត្តភក្តិនៅអង្គការ RHAC កាលពីរៀននៅវិទ្យាល័យទៀតផង។ នៅម៉ោងប្រហែល៣រសៀល យើងបានត្រលប់មកវិញ ហើយច្រៀងខារ៉ាអូខេនៅជិតផ្សារកណ្តាលរហូតដល់ម៉ោង៦ល្ងាច។"* ***[ថា អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, មុនរោងភាពយន្តគីរីរម្យ]***

យុវជនមួយរូបទៀតក៏បានរៀបរាប់អំពីការធ្វើដំណើរទៅខាងក្រៅក្រុងភ្នំពេញ និងបទពិសោធន៍នៃការរួមភេទព្រមទាំងការរួមភេទជាមួយនឹងមិត្តស្រីរបស់គេនៅពេលរសៀលថ្ងៃបុណ្យសង្សារនោះថា:

*" នៅថ្ងៃបុណ្យសង្សារថ្មីៗនេះ យើងបាននាំគ្នាទៅលេងខេត្តកំពង់ចាម ដោយចេញដំណើរនៅម៉ោង៧ព្រឹក។ ខ្ញុំបបួលនាងទៅទីនោះ ពីព្រោះវាជាកន្លែងស្រស់ស្អាត និងថ្មីសំរាប់យើងទាំងពីរ។ យើងបានចេញទៅក្រៅដូចគូស្នេហ៍ដទៃដែរ ពីព្រោះបើខ្ញុំមិននាំនាងទៅ នាងអាចនឹងគិតថាខ្ញុំមិនស្រលាញ់នាង។ ខ្ញុំបានទិញផ្កាមួយបាច់ជូននាងទុកជាអនុស្សាវរីយ៍ ហើយយើងបាន ញ៉ាំអាហារពេលល្ងាចនៅទីនោះ និងផឹកស្រាបៀរបន្តិចបន្តួច ទើបវិលត្រលប់មកទីក្រុងភ្នំពេញវិញ។ យើងបន្តទៅច្រៀងខារ៉ាអូខេប្រហែល១ម៉ោង ហើយទើបសុំនាងរួមរ័កជាមួយគ្នា។ នាងក៏ញញឹមងក់ក្បាលយល់ព្រម ទើបពួកយើងនាំគ្នាទៅផ្ទះសំណាក់ ដោយខ្ញុំបានចំនាយអស់៥ដុល្លារសំរាប់ថ្លៃជួលផ្ទះ។ វាជាការរួមភេទលើកទីមួយរបស់ខ្ញុំ ហើយខ្ញុំក៏បានប្រើស្រោមអនាម័យផងដែរ ដោយខ្លាចនាងមានផ្ទៃពោះដោយចៃដន្យ។ ឥឡូវខ្ញុំមានអារម្មណ៏ល្អខ្លាំងណាស់ ពីព្រោះខ្ញុំដឹងថានាងស្រលាញ់ខ្ញុំ។ ខ្ញុំមិនធ្លាប់ស្វែងរកសេវាផ្លូវភេទនោះទេ ពីព្រោះខ្ញុំខ្លាចឆ្លងរោគផ្សេងៗដូចជា អេដស៍ ជាដើម។ ខ្ញុំបានដឹងតាមរយៈការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ103FM PSI និង RHAC ។" [**ជេម អាយុ១៩ឆ្នាំ ភេទប្រុស ជានិស្សិត, នៅមុខវិទ្យាល័យមួយ**]*

យុវនារីម្នាក់ក៏បាននិយាយរៀបរាប់អំពីបទពិសោធន៏នៃការរួមភេទរបស់នាងថា:

*"ចាប់តាំងពីពេលនោះមក ខ្ញុំនិងសង្សារហាក់ដូចជាមានភាពញញើតចំពោះការរួមភេទ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏គាត់នៅស្រលាញ់ និងយកចិត្តទុកដាក់នឹងខ្ញុំជានិច្ច ជាពិសេសនៅថ្ងៃបុណ្យសង្សារកន្លងទៅថ្មីៗនេះបានធ្វើឱ្យខ្ញុំយល់ថា គាត់នៅតែស្រលាញ់ខ្ញុំ ហើយកាន់តែស្រលាញ់ ពីព្រោះគាត់បានរៀបចំបាច់ផ្កាយ៉ាងធំសំរាប់ជូនខ្ញុំបន្ទាប់ពីចេញពីរៀន រួចហើយនាំគ្នាទៅញ៉ាំអី។ បន្ទាប់ពីជិះដើរលេងនៅមាត់ទន្លេ យើងក៏នាំគ្នាទៅបាក់ខែងដើម្បីជួលផ្ទះសំណាក់មួយសំរាប់២ម៉ោង។ យើងបានគេងជាមួយគ្នាជាថ្មីម្តងទៀត ព្រោះបន្ទាប់ពីយកកូនចេញអស់រយៈពេលជិតបីខែមកហើយ យើងមិនធ្លាប់បានរួមភេទជាមួយគ្នានោះទេ។ ប៉ុន្តែនៅលើកនោះ យើងបានប្រើស្រោមអនាម័យដោយបារម្ភខ្លាចថានឹងមានកូនម្តងទៀត ទោះជាបីជាមានអារម្មណ៏មិនសូវសុខស្រួលក៏ដោយ។ នៅថ្ងៃបុណ្យសង្សារនេះពិតជាមានន័យណាស់សំរាប់ពួកយើងទាំងពីរ ដែលធ្វើឱ្យខ្ញុំកាន់តែយល់ពីគាត់ រួមជាមួយទង្វើ និងកាយវិការស្រលាញ់ ការយកចិត្តទុកដាក់ចំពោះខ្ញុំ ត្រូវបានស្តែងចេញមកនៅថ្ងៃ*

*នោះឯង ម្យ៉ាងទៀតនៅថ្ងៃពិសេសនោះក៏បានធ្វើឱ្យការរួមភេទរបស់យើងកាន់តែរីករាយ និងប្រៀបបីដូចជា ការរួមភេទលើកទីមួយសំរាប់ពួកយើងយ៉ាងដូច្នោះដែរ ។" **[សាន់ឌី អាយុ២៤ឆ្នាំ ភេទស្រី ជានិស្សិត និងបុគ្គលិកក្រុមហ៊ុន, សួនច្បារមាត់ទន្លេ]***

បាក់ខែងជាកន្លែងមួយដែលយុវវ័យភាគច្រើននិយមចូលចិត្តទៅដើម្បីសម្រាកលំហែកាយ សប្បាយ និងមានទំនាក់ទំនងផ្លូវភេទនៅខាងក្នុងខ្ទមបិទជិត ឬបន្ទប់ជួល ។ តាមការរៀបរាប់របស់យុវនារីបានឱ្យដឹងថាៈ

*"នៅក្នុងថ្ងៃបុណ្យសង្សារ ខ្ញុំនិងយុវវ័យដទៃទៀតចេញដើរកំសាន្តនៅខាងក្រៅ ពីព្រោះខ្ញុំគិតថាថ្ងៃនោះជាថ្ងៃសំខាន់មួយសំរាប់ពួកយើងក្នុងការបញ្ជាក់ពីសេចក្តីស្រលាញ់រវាងគ្នានឹងគ្នា ។ យើងធ្លាប់បានរួមភេទជាមួយគ្នាកាលពីឆ្នាំ២០០៥ នៅបាក់ខែង ហើយយើងតែងតែប្រើស្រោមអនាម័យជានិច្ចព្រោះយើងបានពិភាក្សាគ្នាទៅវិញទៅមកថា ប្រសិនបើយើងមិនប្រើស្រោមអនាម័យទេនោះ យើងនឹងអាចប្រឈមប្រថាននឹងការមានផ្ទៃពោះ និងឆ្លងជម្ងឺកាមរោគ ជម្ងឺអេដស៍ជាដើមបាន ។" **[ឌីន អាយុ២៤ឆ្នាំ ភេទស្រី បុគ្គលិកក្រុមហ៊ុន, សួនច្បារសម្តេចហ៊ុនសែន]***

យុវនារីម្នាក់ឈ្មោះ **វ៉ាស៊ី** ក៏បានបកស្រាយរៀបរាប់អំពីបទពិសោធន៍នៃការរួមភេទរបស់នាងជាមួយនឹងមិត្តប្រុសនាងថាៈ

*"ជាធម្មតា ខ្ញុំនិងសង្សារចូលចិត្តទៅលេងបាក់ខែង និងតែគុជរាល់ពេលទំនេរពីការរៀនសូត្រ ។ នៅថ្ងៃបុណ្យសង្សារជាថ្ងៃដ៏ពិសេសមួយ និងមានអត្ថន័យខ្លាំងណាស់សំរាប់ពួកយើងទាំងពីរនាក់ ។ ខ្ញុំចង់ដឹងថា តើគាត់នៅតែស្រលាញ់ខ្ញុំ និងឱ្យកាដូខ្ញុំដូចឆ្នាំមុនទៀតដែរឬទេ? ជាការពិត គាត់ពិតជានៅតែធ្វើដូចឆ្នាំមុន ។ ម្យ៉ាងទៀត យុវវ័យភាគច្រើននៅភ្នំពេញតែងតែចេញដើរលេងកំសាន្តជាមួយនឹងមនុស្សដែលគេស្រលាញ់ សូម្បីតែពួកយើងទាំង២ក៏ដូចគ្នាផងដែរ ហើយយើងក៏បានរួមភេទជាមួយគ្នានៅពេលនោះ ។ ខ្ញុំគិតថាវាជារឿងធម្មតា ពីព្រោះមិនដែលរួមភេទជាមួយគ្នាជិត១ឆ្នាំមកហើយ គឺចាប់តាំងពីថ្ងៃទិវាសិទ្ធិនារីឆ្នាំ២០០៧មកម្ល៉េះ ដោយសារតែយើងធ្វើអារម្មណ៍មិនបានល្អ ប៉ុន្តែយើងតែងតែប្រើស្រោមអនាម័យជានិច្ចនៅពេលយើងរួមភេទ ពីព្រោះយើងបារម្ភខ្លាចមានផ្ទៃពោះ ។" **[វ៉ាស៊ី អាយុ១៩ឆ្នាំ ភេទស្រី ជាសិស្សរៀននៅវិទ្យាល័យ, សួនច្បារមាត់ទន្លេ]***

### ៤.១.៤. ពេលល្ងាចនៅថ្ងៃបុណ្យសង្សារ

យុវវ័យភាគច្រើនចូលចិត្តចេញដើរលេងខាងក្រៅជាមួយសង្សាររបស់គេនៅពេលល្ងាច ដើម្បីចំណាយពេលជាមួយគ្នាជាជាងការរួមភេទ។ ពួកគេខ្លះត្រលប់ទៅផ្ទះវិញពីព្រលប់បន្តិច ប៉ុន្តែក៏នៅមានយុវវ័យមួយចំនួននៅយូរបន្តិចទើបត្រលប់ទៅផ្ទះវិញ។ យុវនារីម្នាក់ និងយុវជនពីរនាក់បានបន្តនៅខាងក្រៅជាមួយគូសង្សាររបស់គេនៅសួនច្បារ និងញ៉ាំអីៈ

*"នៅថ្ងៃបុណ្យសង្សារ ពួកយើងទាំងពីរនាំគ្នាដើរលេងនៅសួនច្បារមាត់ទន្លេ បន្ទាប់មកយើងនាំគ្នាទៅញ៉ាំអីជាមួយគ្នារួចទើបត្រលប់ទៅផ្ទះវិញ។ ខ្ញុំគិតថា ថ្ងៃនោះជាថ្ងៃដែលគូស្នេហ៍ទាំងអស់តែងតែងបង្ហាញពីការស្រលាញ់ចំពោះគ្នាទៅវិញទៅមក។"* ***[កា អាយុ២៣ឆ្នាំ ភេទស្រី បុគ្គលិកក្រុមហ៊ុន, សួនច្បារមាត់ទន្លេ]***

*"នៅថ្ងៃបុណ្យសង្សារ ខ្ញុំបានណាត់ជាមួយមិត្តស្រីរបស់ខ្ញុំនៅក្បែរផ្សារសូរិយានៅវេលាម៉ោង៦ល្ងាច ហើយក៏បានជូនបាច់ផ្កា១បាច់ចំនួន៥ទងតំលៃ៣ដុល្លារ រួចហើយនាំគ្នាឡើងទៅញ៉ាំអីនៅជាន់ទី៤ក្នុងផ្សារសូរិយាប្រហែលជា១ម៉ោង ទើបនាំនាងទៅដើរលេងនៅវត្តភ្នំ ដើម្បីនិយាយសាសងគ្នាដល់ម៉ោង៩យប់ ទើបនាំគ្នាទៅមុខវាំងដើម្បីមើលគេមើលឯង។"* ***[សំ អាយុ២៤ឆ្នាំ ភេទប្រុស ជាអាជីវករ, វត្តភ្នំ]***

*"នៅម៉ោងប្រហែល៣រសៀល យើងបានត្រលប់មកភ្នំពេញវិញ ហើយច្រៀងខារ៉ាអូខេនៅជិតផ្សារកណ្តាលរហូតដល់ម៉ោង៦ល្ងាច។ បន្ទាប់មកទៀតក៏នាំនាងទៅញ៉ាំបង្អែម ហើយត្រឡប់មកផ្ទះវិញព្រោះគ្រួសាររបស់នាងតឹងរឹងចំពោះនាងខ្លាំងណាស់ ដោយពេលកំណត់របស់នាងគឺមិនឱ្យហួសពីម៉ោង៧ល្ងាចឡើយ។"* ***[ថា អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, មុខរោងភាពយន្តគីរីរម្យ]***

មានយុវជនខ្លះដែលមានការងារធ្វើ ពួកគេក៏បានចំណាយពេលជាមួយនឹងសង្សារបន្ទាប់ពីចេញពីធ្វើការផងដែរ។ បុរសមួយចំនួនបានរៀបរាប់អំពីការចូលចិត្តទៅផ្សារទំនើប និងទទួលទានអាហារពេលល្ងាចជាមួយនឹងគូស្នេហ៍របស់គេ និងដើរលេងដោយជិះលំហែជាមួយគ្នានៅមាត់ទន្លេ។

*"ទោះបីជាយើងទាំងពីរជាប់រវល់ការងារក៏ដោយ ក៏យើងទាំងពីរឆ្លៀតពេលល្ងាចបន្ទាប់ពីចេញពីធ្វើការដើម្បីចេញទៅដើរលេងខាងក្រៅ ដើម្បីបញ្ជាក់ពីក្តីស្រលាញ់ខ្ញុំចំពោះនាងជាមួយនឹងផ្កាកុលាបមួយទង។ នៅថ្ងៃនោះខ្ញុំ បាននាំនាងទៅផ្សារសូរិយាដើម្បីញ៉ាំអី រួចហើយទៅអង្គុយលេងនៅមាត់*

*ទន្លេដើម្បីសាសងគ្គារហូតដល់ម៉ោង៨ ទើបត្រលប់ទៅផ្ទះវិញ ។ " **[ប្រុស អាយុ២៤ឆ្នាំ ភេទប្រុស ជាបុគ្គលិកក្រុមហ៊ុនឯកជន, ផ្សារទំនើបសូរិយា]***

*"នៅថ្ងៃនោះ ខ្ញុំជាប់រវល់ធ្វើការងាររហូតដល់ម៉ោង៦ល្ងាច ទើបអាចនាំនាងទៅផ្សារទំនើបសូរិយា ដើម្បីទិញសំលៀកបំពាក់ និងទិញផ្កាជូននាងដើម្បីបញ្ជាក់អំពីក្តីស្រលាញ់របស់ខ្ញុំ ។ បន្ទាប់មកទើបនាំគ្នាទៅជាន់ខាងលើដើម្បីញ៉ាំអី ហើយដើរលេងនៅតាមមាត់ទន្លេ ទើបត្រលប់ទៅផ្ទះនៅម៉ោង៨ ពីព្រោះគ្រួសារនាងមានការតឹងរឹងណាស់ចំពោះរូបនាង ទោះបីជាពួកគេមិនចាប់អារម្មណ៏ថ្ងៃបុណ្យសង្សារនោះក៏ដោយ ។ នៅថ្ងៃនោះ ពួកយើងទាំងពីរមិនបានរួមភេទជាមួយគ្នានោះទេ ។" **[វុធ អាយុ ២០ឆ្នាំ ភេទប្រុស ជានិស្សិត, នៅមុខវិទ្យាស្ថានមួយ]***

## ៤.១.៥. ពេលយប់នៅថ្ងៃបុណ្យសង្សារ

មានមនុស្សជាច្រើនដែលនាំគ្នាត្រលប់ទៅផ្ទះវិញ ប៉ុន្តែក៏មានខ្លះទៀតនៅរហូតដល់យប់ជ្រៅ ។ បន្ទាប់ពីដើរលេងកំសាន្តរួច គូសង្សារយុវវ័យទាំងនោះបាននាំគ្នាទៅផ្ទះសំណាក់ ឬសណ្ឋាគារដើម្បីរួមភេទ ។ តាមរយៈយុវជនមួយរូបដែលបានសើចបណ្តើរ និងរៀបរាប់បណ្តើរថាៈ

*"បន្ទាប់ពីជិះដើរលេងរហូតដល់ម៉ោង៩យប់ យើងក៏នាំគ្នាចូលផ្ទះសំណាក់ ។ ស្ទើរតែមិនគួរឱ្យជឿដែលផ្ទះសំណាក់ទាំងអស់សុទ្ធតែពេញ ។ នៅផ្ទះសំណាក់ទីបីទើបមានបន្ទប់ជួល ។ នោះជាលើកទីមួយ ហើយដែលនាងប្រាប់ថា មិនបាច់ប្រើស្រោមអនាម័យទេ ដូច្នេះខ្ញុំក៏យល់ព្រមតាមនាង ដោយនៅយប់នោះ យើងរួមភេទបានពីរដង ដោយសារតែនៅលើកទីមួយ ខ្ញុំស្រៀវស្រើបខ្លាំងពេកក៏បញ្ចេញទឹកកាមមកមិនបាន២នាទីផង ។ ប៉ុន្តែនៅលើកទី២ពិតជាពិសេសខ្លាំងណាស់ ។ " **[ណាក់ អាយុ២២ឆ្នាំ ភេទប្រុស ជានិស្សិត, តែគុជKiss ]***

យុវជនមួយរូបបានរៀបរាប់អំពីបទពិសោធន៏លើកដំបូងរបស់គេក្នុងការរួមភេទជាមួយនឹងមិត្តស្រីថាៈ

*"ថ្ងៃបុណ្យសង្សារគឺជាថ្ងៃដ៏សំខាន់មួយសំរាប់ខ្ញុំ ដោយខ្ញុំបានណាត់មិត្តភក្តិទាំងអស់ទៅញ៉ាំអីជុំគ្នានៅភោជនីយដ្ឋាន ហើយក៏បាននាំគ្នាជូនផ្កា និងសូកូឡាគ្នាទៅវិញទៅមក ។ បន្ទាប់ពីញ៉ាំអីរួច យើងក៏បានចែកផ្លូវគ្នារៀងៗខ្លួន ប៉ុន្តែខ្ញុំនិងមិត្តស្រីខ្ញុំបាននាំគ្នាទៅមជ្ឈមណ្ឌលកំសាន្ត Spark ដើម្បីរាំកំសាន្តរួចទើបបន្តទៅសណ្ឋាគារ ។ ខ្ញុំត្រូវចំណាយ១០ដុល្លារ សំរាប់ថ្លៃបន្ទប់ ហើយពេលនោះគឺជាលើកដំបូង*

*របស់ខ្ញុំនិងនាង។ យើងសំរេចចិត្តប្រើស្រោមអនាម័យដើម្បីការពាររោគផ្សេងៗ ដូចជា ជម្ងឺកាមរោគ និងអេដស៍ជាដើម ព្រមទាំងការមានផ្ទៃពោះដោយចៃដន្យ។ ខ្ញុំសប្បាយចិត្តណាស់នៅពេលដែលដឹងថានាងក៏មិនធ្លាប់មានទំនាក់ទំនងផ្លូវភេទពីមុនមកដែរ។" **[ តូនី អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, នៅជិត NAGA ]***

យុវជនរូបនេះបានចំណាយពេលនៅជាមួយនឹងសង្សារពេញមួយយប់ៈ

*" បន្ទាប់យើងបាននិយាយសាសងគ្នាដល់ម៉ោង៩យប់ ទើបនាំគ្នាទៅមុខវាំងដើម្បីមើលគេមើលឯង។ ដល់ម៉ោង១១យប់ ខ្ញុំក៏បានប្រាប់នាងថាខ្ញុំងងុយគេងណាស់គួរតែត្រលប់ទៅវិញហើយ ប៉ុន្តែខ្ញុំបានប្រាប់នាងថាខ្ញុំមិនអាចត្រលប់ទៅផ្ទះវិញបានទេ ព្រោះយប់ជ្រៅហើយ ហើយនាងក៏សួរថា តើគួរទៅគេងនៅឯណា? ខ្ញុំក៏ប្រាប់ឱ្យនាងទៅតាមខ្ញុំ ដោយខ្ញុំបានដឹកដៃនាងសំដៅទៅផ្ទះសំណាក់មួយនៅក្បែរផ្សារធំថ្មី។ មុនដំបូងយើងគេងបែរខ្នងដាក់គ្នា ប៉ុន្តែប្រហែលជាកន្លះម៉ោងក្រោយមក ខ្ញុំបានចាប់ទាញដៃនាងឱ្យបែរមុខមករកខ្ញុំហើយអោបនាង តែនាងទាញដៃខ្ញុំចេញ។ ខ្ញុំប្រាប់នាងថាខ្ញុំស្រលាញ់នាងខ្លាំងណាស់ ហើយអោបនាងម្តងទៀត ព្រមទាំងថើបកញ្ចឹងកនាងធ្វើ ឱ្យនាងរសើប ប៉ុន្តែនាងមិនថាអ្វីឡើយហើយស្ងាប។ ឃើញដូច្នេះ ខ្ញុំក៏លូកកាវស្ទាបខ្លួនប្រាណ និងសុដន់នាងរហូតធ្វើឱ្យនាងស្រៀវស្រើបយ៉ាងខ្លាំង រួចហើយខ្ញុំក៏សុំនាងរួមភេទជាមួយ។ គ្រាន់តែលឺពាក្យនេះភ្លាមនាងប្រកែកជាមួយខ្ញុំថានិយាយអីឆ្កួតៗ ប៉ុន្តែខ្ញុំនៅបន្តព្យាយាមនិយាយលួងលោម នាងបណ្តើរដោយប្រើកាយវិការដៃម៉ឹក ហើយសួរនាងថាហេតុអ្វីបានជានាងមិនព្រម? ខ្ញុំប្រាប់នាងថា ខ្ញុំស្រលាញ់នាងខ្លាំងណាស់ ហើយប្រសិនបើនាងយល់ព្រម បានន័យថា នាងពិតជាស្រលាញ់ខ្ញុំ។ ខ្ញុំក៏បានប្រាប់នាងទៀតថា ខ្ញុំមិនក្បត់ចិត្តនាងទេ ហើយបើនាងមិនព្រមទេ នាងពិតជាមិនស្រលាញ់ខ្ញុំឡើយ។ និយាយបណ្តើរដៃរបស់ខ្ញុំលូកកាវស្ទាបរាងកាយនាងបណ្តើរ ហើយបានដោះខ្សែអាវនាងចេញអស់ និងស្រាតខោចេញទៀត ចំណែកនាងក៏មិនថាអីដែរ។ ខ្ញុំគិតថា ប្រហែលជានាងយល់ព្រមហើយ ដូច្នេះខ្ញុំក៏ទ្រោបលើនាង ថើបនាង និងថើបសុដន់នាង ធ្វើឱ្យនាងមានអារម្មណ៍ស្រើលស្រាល ពីព្រោះនាងបានបញ្ចេញសំលេងថ្ងូរ។ បន្ទាប់មក ខ្ញុំបានយកប្រដាប់ដាក់បំរុងរួមភេទ ស្រាប់តែនាងសួរថា តើខ្ញុំមានប្រើស្រោមអនាម័យដែរឬទេ? ខ្ញុំប្រាប់នាងថា ខ្ញុំមិនមានទេ ហើយនាងក៏គ្រវីក្បាល និងបដិសេធ ដូច្នេះខ្ញុំក៏ចុះមកក្រោមដើម្បីរកទិញស្រោមអនាម័យ។ នៅយប់នោះខ្ញុំរួមភេទជាមួយនាងពីរដង ដោយលើកទី១នៅម៉ោង១:៣០នាទី ចំណែកលើកទី២នៅវេលាម៉ោង៣ភ្លឺ។ ក្រោយពេលរួមភេទនៅលើកទី១ហើយ ខ្ញុំឃើញមានចេញឈាមតែមិនច្រើនទេ រួចខ្ញុំក៏សួរនាងថាតើនាង ធ្លាប់មានមិត្ត*

*ប្រុសពីមុនមកដែរឬទេ? នាងឆ្លើយថានាងមិនធ្លាប់មានទេ ហើយខ្ញុំក៏សួរបន្តទៀតថា ហេតុអ្វីបានជានាងឱ្យខ្ញុំប្រើស្រោម? នាងប្រាប់ថា នាងខ្លាចមានកូន និងឆ្លងរោគពីខ្ញុំ។ បន្ទាប់ពីបានរួមភេទនៅលើកទី២រួចមក នាងស្រាប់តែយំ ហើយខ្ញុំក៏សួរនាងថាហេតុអ្វីបានជាយំ? នាងប្រាប់ថា នាងបារម្ភខ្លាចខ្ញុំបោះបង់នាងចោល។ លឺដូច្នេះ ខ្ញុំក៏ប្រាប់នាងថាខ្ញុំមិនក្បត់ចិត្តនាងទេ ពីព្រោះខ្ញុំស្រលាញ់នាង។ ព្រឹកឡើង នាងប្រាប់ខ្ញុំថា ឈឺចង្កេះ ហើយខ្ញុំក៏ប្រាប់នាងថាមិនអីទេ។ យើងទាំងពីរនាក់ក៏ចេញពីផ្ទះសំណាក់នៅម៉ោង៦កន្លះព្រឹក ប៉ុន្តែខ្ញុំមិនបានជូននាងត្រលប់ទៅផ្ទះវិញទេ ពីព្រោះ នាងខ្លាចអ៊ំស្រីនាងឃើញ ដូច្នេះយើងក៏បែកផ្លូវគ្នារៀងខ្លួន ដោយនាងជិះម៉ូតូឌុបទៅផ្ទះវិញដោយខ្លួនឯង។" **[សំ អាយុ២៤ឆ្នាំ ភេទប្រុស អាជីវករ, វត្តភ្នំ]***

យុវជនរូបនេះបានព្យាយាមប្រើពាក្យលួងលោមសង្សាររបស់ខ្លួនឱ្យរួមភេទជាមួយៈ

*"នៅថ្ងៃបុណ្យសង្សារ ខ្ញុំក៏ដឹកនាងដើរលេងជិះមើលគេមើលឯងនៅមុខវាំង ហើយទៅ Parkway ដើម្បីលេងហ្គេមប្រហែលកន្លះម៉ោង ទើបចេញមកវិញប្រហែលម៉ោង១១។ នៅពេលខ្ញុំដឹកនាំទៅផ្ទះសំណាក់នៅក្បែរសួនរាត្រីផ្លូវលេខ៦៣ នាងសួរខ្ញុំថាមកកន្លែងនេះធ្វើអី? ខ្ញុំប្រាប់ថាយប់ជ្រៅនេះហើយទៅផ្ទះមិនកើតទេ ព្រោះអត់មានសោរចូលផ្ទះ! នាងក៏សួរទៀតថា ហេតុអ្វីបានជាមិនទៅសណ្ឋាគារមានម៉ាស៊ីនត្រជាក់ស្រួល? ខ្ញុំឆ្លើយវិញថា ខ្ញុំស្គាល់ម្ចាស់ផ្ទះសំណាក់នៅទីនេះ។ ខ្ញុំនឹកក្នុងចិត្តថានាងប្រហែលជាធ្លាប់គេងជាមួយប្រុសៗច្រើនអ្នកហើយមើលទៅ! គ្រាន់តែឡើងដល់បន្ទប់ភ្លាម នាងចូលទៅបន្ទប់ទឹកភ្លាម ហើយខ្ញុំក៏ចុះមកខាងក្រោមដើម្បីទិញស្រោមអនាម័យមួយប្រអប់តូច។ នៅពេលខ្ញុំឡើងទៅលើវិញ ហើយអង្គុយរាវរកប៉ុស្តិ៍សិចមើល នាង ចេញពីបន្ទប់ទឹកមកសួរថាមើលរឿងហ្នឹងធ្វើអី? ខ្ញុំក៏តបវិញថាមើលដើម្បីបង្កើនអារម្មណ៍ និយាយដូចធ្វើពើអត់ដឹងអីសោះ! បន្ទាប់មកយើងមើលរឿងសិចជាមួយគ្នា។ នៅពេលនោះដៃខ្ញុំលូករាវលើរាងកាយនាង ហើយដោះកន្សែងចេញពីខ្លួននាងចេញ ចំណែកនាងក៏មិននិយាយអ្វីដែរ គ្រាន់តែមើលមុខខ្ញុំតែប៉ុណ្ណោះ។ ១៥ នាទីក្រោយមក យើងទាំងពីរក៏ឈានដល់ការរួមភេទដោយប្រើស្រោមអនាម័យ។ ក្នុងពេលនោះខ្ញុំលឺសំលេងថ្ងូរទាំងក្នុងទូរទស្សន៍ និងខាងក្រៅ។ នៅពេលរួមភេទលើកទី១រួចហើយ ខ្ញុំសួរនាងថាហេតុអ្វីបានជាថ្ងូរលឺៗម្លេះ? នាងឆ្លើយថា ព្រោះវាស្រួលផង ឈឺផង ព្រោះប្រដាប់ភេទរបស់ខ្ញុំធំពេក។ ប្រហែលជាពាក់កណ្តាលអាធ្រាត្រ យើងក៏រួមភេទជាលើកទី២។ ក្នុងយប់នោះ យើងរួមភេទដល់ទៅ៤ដង រហូតដល់ម៉ោង៧កន្លះព្រឹកទើបចេញពីផ្ទះសំណាក់ ដោយខ្ញុំជូននាងទៅដាក់នៅក្បែរ*

*ទូតចិន ហើយនាងប្រាប់ថានឹងទូរស័ព្ទមករកខ្ញុំនៅពេលយប់។ "* ***[ញ៉ាញ៉  អាយុ២៣ឆ្នាំ ភេទប្រុស កំពុងរកការងារធ្វើ, សួនច្បារមាត់ទន្លេ]***

ចំណែកយុវជនរូបនេះបានប្រាប់ថា បន្ទាប់ពីរូបគេ និងសង្សាររបស់គេបាត់ឡើយពីការរាំកំសាន្តនៅក្លឹបហើយ ពួកគេក៏បានគេងលក់នៅយប់នោះ ប៉ុន្តែពួកគេបានរួមភេទជាមួយគ្នានៅពេលព្រឹក:

*" យើងនាំគ្នាបន្តដើរលេងនៅមាត់ទន្លេ រួចចូលផឹកបៀររហូតដល់យប់ជ្រៅ ទើបទៅ Rock ទៀត។ នៅពេលចេញពី Rock យើងទៅគេងនៅផ្ទះសំនាក់មុំផ្សារសូរិយា ប៉ុន្តែនៅពេលនោះយើងមិនបានរួមភេទទេ ពីព្រោះអស់កំលាំងពេក។ លុះដល់ម៉ោង៩ព្រឹក ទើបយើងបានរួមរ័កជាមួយគ្នា ប៉ុន្តែខ្ញុំបានប្រើស្រោមអនាម័យជាមួយនាង ព្រោះខ្លាចឆ្លងរោគ។ មិនដូចកាលពីមុន ពេលដែលរួមភេទជាមួយនាង ខ្ញុំមិនដែលបានប្រើប្រាស់ស្រោមអនាម័យទេ។ ជាពិសេសដើម្បីការសប្បាយ និងមិនបាច់ចំណាយលុយសំរាប់យើងជាបុរស។ ខ្ញុំលឺមិត្តភក្តិខ្ញុំនិយាយថា អស់តែ១៥ដុល្លារទេបានឡើងស្ថានសួគ៌ គឺ១០ដុល្លារសំរាប់ថ្លៃផ្កា និងចិញ្ចៀន ហើយ៥ដុល្លារសំរាប់ថ្លៃផ្ទះសំណាក់។"* ***[តូ អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, សួនច្បារមាត់ទន្លេ]***

នៅថ្ងៃបុណ្យសង្សារ យុវវ័យភាគច្រើនចំណាយពេលវេលាជាមួយនឹងគូសង្សាររបស់គេ។ ពួកគេនិយាយអំពីសេចក្តីស្នេហា ដែលគេមានយ៉ាងជ្រាលជ្រៅចំពោះគូស្នេហ៍របស់គេ។ ជាលទ្ធផលវិញនោះ ចំនួនពាក់កណ្តាលនៃអ្នកផ្តល់សំភាសន៍សំរាប់ការសិក្សានេះបាននិយាយថា ពួកគេបានរួមភេទជាមួយនឹងគូសង្សាររបស់គេនៅថ្ងៃនោះ។ ភាគច្រើននៃគូសង្សារទាំងនោះបានប្រើប្រាស់ស្រោមអនាម័យ ទោះបីជាពួកគេទើបតែមានការរួមភេទជាលើកទីមួយក៏ដោយ។ យ៉ាងហោចណាស់នៅក្នុងនោះក៏មានយុវជនម្នាក់ក្នុងចំណោមអ្នកផ្តល់បទសំភាសន៍ទាំងអស់ឈ្មោះ ណាក់ បានបញ្ជាក់ថា គេមិនបានប្រើស្រោមអនាម័យនោះទេ ស្របពេលដែលថ្ងៃនោះជាលើកទីមួយដែលគេរួមភេទជាមួយសង្សារ។ ណាក់ មានទំនាក់ទំនងផ្លូវភេទ សំអាងលើ "ភាពជឿទុកចិត្ត" ដោយការសន្មត់ថា សង្សាររបស់គេជានារីបរិសុទ្ធ ជាមួយនឹងអារម្មណ៍ថា គេមិនចាំបាច់ ត្រូវការប្រើស្រោមអនាម័យទេ ជាពិសេសដោយសារតែនោះជាការរួមភេទលើកទីមួយរបស់គេ។ សេចក្តីសន្និដ្ឋាននេះ ប្រហាក់ប្រហែលទៅនឹងការសិក្សាជាសាកលផ្សេងទៀត ដែលបានលើកឡើងថា បុរសភាគច្រើនស្វែងរកដៃគូ ស្នេហាណាដែលមានភាពបរិសុទ្ធ ពីព្រោះពួកគេ "ជឿជាក់" ថា ពួកគេមិនចាំបាច់ភ័យខ្លាចការឆ្លងរោគផ្សេងៗ។ ចំពោះ

យុវជនជាទូទៅមានការពិបាកនៅក្នុងការគ្រប់គ្រងខ្លួនឯងនៅពេលឈានដល់ដំណាក់កាលនៃការរួមភេទ ដូច្នេះធ្វើឱ្យពួកគេប្រឈមមុខនឹងការប្រថុយប្រថានខ្ពស់ក្នុងការឆ្លងជម្ងឺផ្សេងៗដូចជា ជម្ងឺឆ្លងតាមភេទ និងការចម្លងមេរោគអេដស៍ ។[49]

## ៤.១.៦. ការគ្មានទំនាក់ទំនងផ្លូវភេទ និងការរួមភេទដោយប្រើស្រោមអនាម័យជាមួយដៃគូនៅថ្ងៃបុណ្យសង្សារ

ឪពុកម្តាយ និងដៃគូស្នេហាគឺជាឥទ្ធិពលដ៏ធំបំផុតមួយលើការសំរេចចិត្តរបស់យុវវ័យថា តើពួកគេត្រូវមានការរួមភេទដែររឺក៏អត់ ។ តាមរយៈសំដីរបស់យុវជនមួយចំនួនបានលើកឡើងថាៈ

*"បន្ទាប់ពីពួកយើងបានទៅដើរលេងនៅតាមមាត់ទន្លេ ពួកយើងនាំគ្នាត្រលប់ទៅផ្ទះវិញនៅម៉ោង៨ ពីព្រោះគ្រួសារនាងមានការតឹងរឹងណាស់ចំពោះរូបនាង ទោះបីជាគាត់មិនចាប់អារម្មណ៍អំពីថ្ងៃបុណ្យសង្សារក៏ដោយ ។ ហើយនៅថ្ងៃនោះ យើងក៏មិនបានរួមភេទជាមួយគ្នាដែរ ។" [**វុធ អាយុ២០ឆ្នាំ ភេទប្រុស ជានិស្សិត, នៅមុខវិទ្យាស្ថានមួយ**]*

*"បន្ទាប់មកទៀត ខ្ញុំនាំនាងទៅញ៉ាំបង្អែម ហើយក៏ត្រឡប់មកផ្ទះវិញ ព្រោះគ្រួសាររបស់នាងតឹងរឹងចំពោះនាងខ្លាំងណាស់ ដោយពេលកំណត់របស់នាងគឺមិនឱ្យហួសពីម៉ោង៧ល្ងាចឡើយ ។ គ្រួសារនាងមិនបានដឹងពីទំនាក់ទំនងពួកយើងឡើយ ហើយម្យ៉ាងទៀត ពួកគាត់ក៏មិនបានចាប់អារម្មណ៍នឹងថ្ងៃបុណ្យសង្សារនោះឡើយ ។" [**ថា អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, នៅមុខរោងភាពយន្តគីរីរម្យ**]*

*"រហូតដល់ម៉ោង៨ទើបយើងត្រលប់ទៅផ្ទះ ។ បើនិយាយតាមការពិតទៅ ខ្ញុំមិនដែលរួមភេទជាមួយនឹងមិត្តស្រីខ្ញុំឡើយ ពីព្រោះខ្ញុំមិនហ៊ាន ដោយបារម្ភខ្លាចក្រែងថា នាងនឹងឈប់ស្រលាញ់ខ្ញុំ ។" [**ប្រុស អាយុ២៤ឆ្នាំ ភេទប្រុស ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយ, ផ្សារទំនើបសូរិយា**]*

ការកើនឡើងចំពោះការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជក្នុងចំណោមយុវវ័យតាមរយៈការសិក្សា ការចែកខិត្តប័ណ្ណចែកចាយ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ អាចធ្វើឱ្យមានការផ្លាស់ប្តូរលើឥរិយាបថរបស់គេពីការរួមភេទ និងអាចការពារពួកគេពីការមានផ្ទៃពោះដោយចៃដន្យ ព្រមទាំងការឆ្លងជម្ងឺ និងមេរោគផ្សេងៗដូចជាមេរោគអេដស៍ ជម្ងឺអេដស៍ និងជម្ងឺឆ្លងតាមភេទនានា។ ជាឧទាហរណ៍ យុវនារីម្នាក់បានលើកឡើងអំពីការពារពីការរួមភេទជាមួយនឹងមិត្តប្រុសរបស់នាងថាៈ

[49] Longfield, K., et al. (2002). *Op cit.*, pp. 10-11

*" នៅថ្ងៃបុណ្យសង្សារ ពួកយើងទាំងពីរនាំគ្នាដើរលេងនៅសួនច្បារមាត់ទន្លេ បន្ទាប់មកយើងនាំគ្នាទៅញ៉ាំអី រួចទើបត្រលប់ទៅផ្ទះវិញ ។ ខ្ញុំគិតថា ថ្ងៃនោះជាថ្ងៃដែលគូស្នេហ៍ទាំងអស់តែងតែងបង្ហាញពីការស្រលាញ់ចំពោះគ្នាទៅវិញទៅមក ។ ពួកយើងមិនដែលគិតដល់បញ្ហារួមភេទនោះទេ ពីព្រោះយើងទាំងពីរសុទ្ធតែបានរៀនយល់ដឹងពីបញ្ហាសុខភាពបន្តពូជ ដូច្នេះសង្សាររបស់ខ្ញុំគាត់ក៏មិនដែលគិតចង់រួមភេទជាមួយខ្ញុំនោះទេ ដោយសារតែគាត់បានរៀនយល់ដឹងពីបញ្ហាជាច្រើនតាមអង្គការនានាមានដូចជា អង្គការ SMD និង YCC ជាដើម ។ "* ***[កា អាយុ២៣ឆ្នាំ ភេទស្រី ជាបុគ្គលិកធ្វើការងារ, សួនច្បារមាត់ទន្លេ]***

កញ្ញាអាលី ក៏បានរៀបរាប់ប្រាប់អំពីការសោកស្ដាយនៃបទពិសោធន៍ដែលនាងមានជាមួយអតីតមិត្តប្រុស ។ ប៉ុន្តែឥរិយាបថរបស់នាងបានផ្លាស់ប្ដូរវិញចាប់តាំងពីនាងទទួលបានព័ត៌មានស្ដីពីបញ្ហាសុខភាពផ្លូវភេទ :

*"នៅថ្ងៃបុណ្យសង្សារកន្លងទៅនេះ ពួកយើងមិនបានធ្វើអ្វីឱ្យជ្រុលជ្រួសខុសប្រពៃណីនោះឡើយ នោះដោយសារតែយើងមានការគិតដូចគ្នា ហើយពួកយើងសុទ្ធតែរៀនបានខ្ពង់ខ្ពស់ល្មមនឹងអាចដឹងថាអ្វីដែលជារឿងត្រឹមត្រូវ អ្វីដែលគួរប្រព្រឹត្ត ឬមិនគួរប្រព្រឹត្ត ខុសស្រឡះពីអតីតកាល ដែលខ្ញុំរិះតែនឹងធ្លាក់ខ្លួនដកមិនរួចទៅហើយ ។ ពួកយើងនៅសុទ្ធតែនៅក្មេង ហើយមានឋានៈត្រឹមតែជាគូសង្សារបែបអាស៊ី មិនមែនដូចជាគូសង្សារអឺរ៉ុបនោះឡើយ ហើយក៏មិនមែនទាន់ក្លាយជាប្ដីប្រពន្ធនឹងគ្នានៅឡើយដែរ ។ តួបផ្សំជាមួយគ្នានេះ យើងក៏បានទទួលការណែនាំ និងចំណេះដឹងពីបញ្ហាទាក់ទងទៅនឹងសុខភាពផ្លូវភេទពីបណ្ដាអង្គការនានា តាមរយៈការផ្សព្វផ្សាយតាមបណ្ដាញស្ថានីយ៍ទូរទស្សន៍ ប៉ុស្ដិ៍វិទ្យុ ។ ទាំងនេះធ្វើឱ្យយើងអាចបែងចែកបាននូវអ្វីដែលគួរ និងមិនគួរហើយ ។ ម្យ៉ាងទៀត ខ្ញុំពិតជាស្រលាញ់ និងគោរពប្រពៃណីខ្មែរយើងផងដែរ ដោយនៅក្នុងថ្ងៃនោះពួកយើងក៏បានពិភាក្សាគ្នាថានឹងមិនប្រឡូកនឹងការរួមភេទមុនពេលរៀបការទេ ទោះបីជាយើងទាំងពីរស្រលាញ់គ្នាខ្លាំងយ៉ាងណាឬស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ។"* ***[អាលី អាយុ២៣ឆ្នាំ ភេទស្រី ជានិស្សិត, ផ្ទះជួលរបស់មិត្តភក្តិនៅម៉ុំទួលទំពូង]***

នៅពេលរសៀល ថា ជេម សាន់ឌី ឌីន និងរ៉ាស៊ី ចំណែកឯនៅពេលល្ងាចវិញ តូនី សំ ញ៉ាញ់ និងតួ បានចែករំលែកបទពិសោធន៍នៃការរួមភេទជាមួយនឹងគូសង្សាររបស់ពួកគេ ហើយបានប្រើប្រាស់ស្រោមអនាម័យនៅថ្ងៃនោះផងដែរ ។ ពួកគេយល់ដឹងច្បាស់អំពីសារសំខាន់នៃការប្រើប្រាស់ស្រោមអនាម័យ ស្របពេលដែលពួកគេបានទទួលព័ត៌មានទាំងនោះតាមរយៈប្រព័ន្ធផ្សព្វផ្សាយ មិត្តអប់រំមិត្ត និងការសិក្សាលើបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ។ ពួកគេខ្លះបានផ្លាស់

ប្តូរឥរិយាបថរបស់ពួកគេដូចជា **តួ** ដែលបានលើកឡើងថាៈ *"យើងទើបតែមានការរួមភេទជាមួយគ្នា ប៉ុន្តែយើងបានប្រើប្រាស់ស្រោមអនាម័យ ពីព្រោះខ្ញុំខ្លាចមានឆ្លងមេរោគ និងជម្ងឺផ្សេងៗ។ វាខុសស្រលះពីអតីតកាល ដែលខ្ញុំរួមភេទជាមួយនឹងនាងដោយមិនប្រើស្រោមអនាម័យ"*

**រ៉ាស៊ី** អាចសូមឱ្យសង្សាររបស់នាងប្រើប្រាស់ស្រោមអនាម័យបាន ចំណែកឯសង្សាររបស់ **សំ** វិញក៏អាចបញ្ចុះបញ្ចូល **សំ** ឱ្យប្រើប្រាស់ស្រោមអនាម័យបានផងដែរ ដោយសារតែនាងបារម្ភខ្លាចមានផ្ទៃពោះ។ នៅទីបំផុត **សំ** ក៏សុខចិត្តធ្វើតាមនាង។

បន្ថែមពីលើនេះទៀត **សាន់ឌី** បានចែករំលែកបទពិសោធន៍នៃការរួមភេទរបស់នាង ហើយបាននិយាយថា នាងបានផ្លាស់ប្តូរឥរិយាបថដោយការប្រើប្រាស់ស្រោមអនាម័យនៅថ្ងៃបុណ្យសង្សារ។ នាងមានអារម្មណ៍ថាមិនសុខស្រួលក្រោយពេលនាងរំលូតកូនក្នុងផ្ទៃរួចមក ហើយទង្វើរបស់នាងត្រូវបានធ្វើឡើងដោយការស្រលាញ់ជឿទុកចិត្តចំពោះមិត្តប្រុសរបស់នាង ដែលនាងធ្វើការបញ្ជាក់តាមរយៈការមិនប្រើស្រោមអនាម័យ។ ហើយនាងក៏ប្រឈមមុខខ្លាំងនឹងការឆ្លងរោគផ្សេងៗដូចជា HIV/AIDS/STIs ពីព្រោះនាងជាសង្សារទីពីររបស់មិត្តប្រុសរបស់នាងដែលគេបាននិយាយប្រាប់នាងក្រោយពេលរួមភេទរួចហើយក៏បានប្រាប់នាងផងដែរថា គេក៏ធ្លាប់រួមភេទជាមួយនឹងសង្សារចាស់របស់គេដូចគ្នា។ បន្ទាប់ពីពេលនោះមកទើបនាងបានដឹងថា តាមពិតទៅមិត្តប្រុសរបស់នាងកុហកនាង។ មនោសញ្ចេតនាស្នេហាបានធ្វើឱ្យយុវវ័យ "ខ្វាក់ភ្នែក" ដោយបាត់បង់ការពិចារណា ហើយប្រថុយប្រថាននឹងការឆ្លងមេរោគ STIs/HIV បាន ហើយសុទ្ធចិត្តទទួលយកអតីតកាលរបស់គូសង្សាររបស់ខ្លួន ដោយភ័យខ្លាចទំនាក់ទំនងរបស់គេត្រូវប្រេះឆា។[៥០]

## ៤.១.៧. ទស្សនៈវិស័យរបស់យុវវ័យអំពីឥរិយាបថឪពុកម្តាយចំពោះថ្ងៃបុណ្យសង្សារ

អ្នកចូលរួមផ្តល់ការសំភាសន៍ភាគច្រើននិយាយថា ថ្ងៃបុណ្យសង្សារជាថ្ងៃពិសេសសំរាប់យុវវ័យ។ ចំនែកឯឪពុកម្តាយវិញ មិនសូវដឹងច្បាស់អំពីថ្ងៃបុណ្យនោះទេ ហើយរឹតតែមិនពេញចិត្តចំពោះទង្វើដែលយុវវ័យធ្វើនៅថ្ងៃបុណ្យនោះទៅទៀតៈ

> *"ខ្ញុំយល់ឃើញថាថ្ងៃបុណ្យសង្សារគឺជាថ្ងៃដែលត្រូវបានបង្កើតសំរាប់មនុស្សជាទីស្រលាញ់ មានដូចជាប៉ាម៉ាក់ បងប្អូន យាយតា មិត្តភក្តិ និងគូសង្សារ ប៉ុន្តែសំរាប់ប៉ាម៉ាក់ និងយាយតា គាត់មិនសូវមានពេលឯណាមករវល់រឿងថ្ងៃនោះទេ ពីព្រោះគាត់គិតថាវាគ្មានប្រយោជន៍។ ប្រហែលជាមានតែ*

[50] Longfield, K., et al. (2002), *Op. cit.*, p. 17

*យុវវ័យតែប៉ុណ្ណោះ ដែលចាប់អារម្មណ៍។" [**អាលី អាយុ២៣ឆ្នាំ ភេទស្រី ជានិស្សិត, ផ្ទះជួលមិត្តភក្តិនៅម្តុំទួលទំពូង**]*

*"ថ្ងៃបុណ្យសង្សារជាថ្ងៃដែលយុវវ័យគ្រប់គ្នារីករាយបំផុត មានតែចាស់ៗទេដែលគាត់មិនពេញចិត្តជាពិសេសគឺប៉ាម៉ាក់ខ្ញុំតែម្តង ព្រោះគាត់តែងនិយាយថា ថ្ងៃនោះជាថ្ងៃដែលធ្វើឱ្យក្មេងៗជ្រួលច្របល់ជោរតាមគ្នា។" [**សាន់ឌី អាយុ២៤ឆ្នាំ ភេទស្រី ជានិស្សិតនិងបុគ្គលិកក្រុមហ៊ុន, សួនច្បារមាត់ទន្លេ**]*

*"ថ្ងៃបុណ្យសង្សារមិនមែនជាថ្ងៃបុណ្យជាតិរបស់ខ្មែរយើងផង ដូច្នេះមិនសូវមាននរណាខ្វល់ពីរឿងនេះទេ។ ខ្ញុំគិតថាវាក៏សប្បាយម្យ៉ាងដែរ ដោយយើងអាចបញ្ជាក់ពីក្តីស្រលាញ់របស់យើងទៅមនុស្សដែលយើងស្រលាញ់។" [**ណាក់ អាយុ២២ឆ្នាំ ភេទស្រី ជានិស្សិត, ហាងតែគុជ KISS** ]*

*"ឪពុកម្តាយខ្ញុំមិនបានដឹងអំពីសកម្មភាពរបស់ខ្ញុំនៅថ្ងៃបុណ្យសង្សារឡើយ ពីព្រោះខ្ញុំមកពីតាមខេត្តដើម្បីរៀនបន្តនៅភ្នំពេញ។ ខ្ញុំគិតថាវាមិនសូវជាអស្ចារ្យអ្វីនោះទេ មិនថាមានបុណ្យអ្វីគឺពួកខ្ញុំចូលរួមទាំងអស់សំខាន់នោះគឺឱ្យតែសប្បាយ។" [**តូ អាយុ២១ឆ្នាំ ភេទប្រុស ជានិស្សិត, សួនច្បារមាត់ទន្លេ**]*

ការទំនាក់ទំនងរវាងឪពុកម្តាយ និងកូនៗអំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជនៅមានកំរិតនៅឡើយ ជាពិសេសនៅពេលដែលពួកគេពេញវ័យហើយ។ តាមរយៈការសិក្សាបែបគុណភាពវិស័យរបស់ RHIYA បានបង្ហាញថា ឧបសគ្គនៃការធ្វើទំនាក់ទំនងគ្នារវាងឪពុកម្តាយ និងកូនលើបញ្ហានេះគឺៈ ឪពុកម្តាយភាគច្រើនពុំមានការយល់ដឹងច្រើនអំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ហើយពួកគាត់តែងតែគេចវេះមិនលើកឡើងពីបញ្ហានេះ ដោយសំអាងថាពួកគាត់ពុំមានពេលវេលាគ្រប់គ្រាន់ និងបើនិយាយទៅលើសង្គមប្រពៃណីខ្មែរវិញ ការលើកឡើងអំពីបញ្ហាផ្លូវភេទមិនត្រូវបានអនុញ្ញាតិឱ្យលើកមកនិយាយឡើយ។[៥១] កត្តាទាំងនេះហើយដែលនាំឱ្យឪពុកម្តាយភាគច្រើនមិនបានយកចិត្តទុកដាក់ទៅលើការណែនាំដាស់តឿនកូនៗ និងផ្តល់នូវការណែនាំដ៏ប្រសើរដល់ពួកគេ។ ក្នុងការសិក្សានេះ ឪពុកម្តាយហាក់មិនសូវដឹងអំពីអ្វីដែលកូនៗរបស់គាត់បានប្រព្រឹត្តនោះទេ ហើយមិនបានទូន្មានកូនអំពីថ្ងៃបុណ្យសង្សារនេះផងដែរ។ មានតែអ្នកចូលរួមផ្តល់ការសំភាសន៏តែពីរនាក់ប៉ុណ្ណោះ ដែលបានទទួលការរំលឹកដាស់តឿនអំពីមេរោគអេដស៏ និងទំនៀមទំលាប់ប្រពៃណីខ្មែរ ពីឪពុកម្តាយរបស់ពួកគេនៅថ្ងៃបុណ្យសង្សារៈ

[51] Vuthy, B. (2006). *Op cit.*, p. 51

*"ចំណែកឪពុកខ្ញុំវិញក៏បានដឹងថា ខ្ញុំដើរលេងផងដែរនៅថ្ងៃបុណ្យសង្សារនោះ ប៉ុន្តែគាត់គ្រាន់តែផ្តាំថា ដើរលេងត្រូវចេះការពារខ្លួន ប្រយ័ត្នកើតអេដស៍! ហើយខ្ញុំក៏ឆ្លើយប្រាប់គាត់ដែរថា ខ្ញុំចេះដើរ ខ្ញុំចេះប្រយ័ត្នហើយប៉ាកុំភ័យ! "* ***[ញ៉ាញ៉ូ អាយុ២៣ឆ្នាំ ភេទប្រុស កំពុងរកការងារធ្វើ, សួនច្បារមាត់ទន្លេ]***

*"ឪពុកម្តាយរបស់ខ្ញុំវិញគិតថាក្មេងៗឥឡូវដើរទាន់សម័យណាស់ តាមគ្នាទៅវិញទៅមក ប៉ុន្តែគាត់បានប្រាប់ថា ពេលសប្បាយកុំភ្លេចខ្លួនឱ្យសោះថា ខ្លួនជានារីខ្មែរ ។"* ***[ឌីន អាយុ២៨ឆ្នាំ ភេទស្រី បុគ្គលិកធ្វើការងារ, សួនច្បារហ៊ុនសែន]***

## V. ការពិភាក្សា

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការរីកចម្រើននៃសង្គមសេដ្ឋកិច្ចកម្ពុជា និងទំនាក់ទំនងសេដ្ឋកិច្ចពិភពលោកបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើវប្បធម៌ខ្មែរ និងឥរិយាបថរបស់ប្រជាជន។ ជាពិសេសយុវវ័យភាគច្រើន ដែលងាយនឹងទទួលយកនូវអ្វីដែលថ្មី ឬពិធីបុណ្យ ឬការប្រារព្ធផ្សេងៗពីមជ្ឈដ្ឋានខាងក្រៅ។ ថ្ងៃបុណ្យសង្សារមានដើមកំណើតរបស់ប្រទេសលោកខាងលិចដែលកាន់សាសនាគ្រឹស្ត ចំណែកឯគូសង្សាររបស់ខ្មែរបែរជាគ្រាន់តែដឹងថា ពួកគេរៀនតាមប្រទេសនៅអាស៊ីផ្សេងទៀត មានដូចជា ហុងកុង កូរ៉េខាងត្បូង និងប្រទេសថៃ តាមរយៈភាពយន្ត ទស្សនាវដ្តី និងព័ត៌មាន ស្របពេលដែលអ្នកខ្លះវិញនិយាយថាពួកគេគ្រាន់តែធ្វើតាមយុវវ័យដូចគ្នាផ្សេងទៀតតែប៉ុណ្ណោះ។ រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ថ្ងៃបុណ្យសង្សារបានក្លាយទៅជាបុណ្យដ៏ពេញនិយមសំរាប់យុវវ័យទូទៅ ហើយធ្វើឱ្យពួកគេប្រព្រឹត្តនូវសកម្មភាពផ្សេងៗ រួមទាំងការមានទំនាក់ទំនងផ្លូវភេទទៀតផង ដោយអ្នកខ្លះទៀតបានឆ្លៀតឱកាសដើម្បីសាកល្បងក្នុងការរួមភេទផងទៀត។ តាមការលើកឡើងរបស់យុវនារីវ័យក្មេងម្នាក់នៅក្នុងការសិក្សារបស់ RHIYA បានឱ្យដឹងថា: *"យុវវ័យភាគច្រើនគ្រាន់តែចង់ដឹង និងចង់ប្រឡូកក្នុងការរួមភេទតែប៉ុណ្ណោះ។ ក្នុងនាមយើងដែលមានវ័យស្របាលនឹងពួកគេ យើងមិនអាចការពារពួកគេបានទេ ពីព្រោះពួកគេបានទទួលយកឥទ្ធិពលពីអឺរ៉ុបទៅហើយ ។ "* [៥២] ទោះបីជាយ៉ាងណាក៏ដោយក៏ការសិក្សាអំពីការផ្លាស់ប្តូរនៃឥរិយាបថ របស់គូសង្សារ យុវវ័យ ថ្ងៃបុណ្យសង្សារនេះចូលរួមគាំទ្រការព្យាយាមប្រឹងប្រែងរបស់កម្មវិធីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជនៅក្នុងទីក្រុងភ្នំពេញ ដែលបានធ្វើឱ្យយុវវ័យឋានៈមធ្យមភាគច្រើនផ្លាស់ប្តូរឥរិយាបទពួកគេ ដោយបែរមកប្រើប្រាស់ស្រោមអនាម័យនៅពេលមានការរួមភេទជាមួយនឹងគូសង្សាររបស់ពួកគេ។តាមរយៈការសិក្សាជាលើកទី២ របស់គម្រោង ប្រព្រឹត្តដោយសុវត្ថិភាព បានលើកឡើងអំពីការកើនឡើងនៃចំនួនអ្នកប្រើប្រាស់ស្រោមអនាម័យគួរឱ្យកត់ សំគាល់បើផ្អែកតាមរបាយការណ៏របស់មិត្តស្រាវជ្រាវពីមិត្ត។ យុវវ័យមួយចំនួនបានផ្លាស់ប្តូរឥរិយាបថរបស់ពួកគេជាមួយនឹងគូសង្សាររបស់គេ ដោយទីមួយ ពួកគេភ័យខ្លាចការឆ្លងមេរោគផ្សេងៗដូចជា HIV/AIDS និងជម្ងឺផ្សេងៗទៀត ចំនែកទីពីរវិញ គឺដើម្បីការពារពីការមានផ្ទៃពោះដោយចៃដន្យ។[៥៣] ចំពោះឪពុកម្តាយនៅក្នុងការសិក្សានេះភាគ

52 Vuthy, B. (2006). *Op cit.*, p. 51
53 Hayden, R. (2006)., *Op cit.*, p. 38.

ច្រើន មិនបង្កើតឱ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងកូន ឬពួកគាត់មិនបាន យកចិត្តទុកដាក់អំពីអ្វីដែលកូនៗបានប្រព្រឹត្តនៅថ្ងៃបុណ្យសង្សារ ជាជាងការផ្តល់ដំបូន្មានដាស់តឿនកូនៗ។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញពីនិន្នាការ និងទស្សនវិស័យរបស់ឪពុកម្តាយក្នុងសម័យកាលទំនើបចំពោះការមានទំនាក់ទំនងផ្លូវភេទរបស់យុវវ័យ។ បុរសរៀបការម្នាក់ដែលរស់នៅក្នុងទីក្រុងភ្នំពេញជឿជាក់ថា តាមរយៈបណ្តុះបណ្តាលឱ្យយល់ដឹងអំពីសុខភាព ផ្លូវភេទ និងសុខភាពបន្តពូជ នឹងធ្វើឱ្យយុវវ័យដឹងពីវិធីបង្ការ និងការពារខ្លួនៈ *"បច្ចុប្បន្ននេះ យុវវ័យមានសេរីភាពច្រើនក្នុងការជ្រើសរើសដៃគូជីវិតរបស់ពួកគេ ហើយឪពុកម្តាយភាគច្រើនក៏បានអនុញ្ញាតិឱ្យកូនៗចេញទៅខាងក្រៅក្នុងសង្គម និងមានការណាត់ជួប ចំណែកឯក្មេងស្រីអាចនឹងមានទំនាក់ទំនងផ្លូវភេទជាមួយនឹងគូសង្សាររបស់នាងទៀតផង នៅក្នុងពេលពួកគេធ្វើការណាត់ជួបនោះ។"*[៥៤] បុរសរៀបការម្នាក់ទៀតបានបញ្ជាក់ប្រាប់ថាៈ *"ឪពុកម្តាយគ្រប់រូបនឹងមិនអនុញ្ញាតិឱ្យកូនស្រីរបស់ខ្លួនមានការណាត់ជួបនៅមុនពេលរៀបការនោះទេ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យនេះបើនិយាយអំពីសិទ្ធិស្មើវិញ វាមិនត្រឹមត្រូវឡើយ។ ស្ត្រីក៏ត្រូវការមានរួមភេទដូចគ្នា... ។"*[៥៥]

ម្យ៉ាងវិញទៀត ក៏នៅមានសំណួរលើកឡើងថាតើប្រវត្តិនៃថ្ងៃបុណ្យសង្សាររបស់ប្រទេសលោកខាងលិចដែលកាន់សាសនាគ្រីស្តនោះអាចមានឥទ្ធិពលមកលើយុវវ័យកម្ពុជាក្នុងការមានទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ និងប៉ះពាល់ទៅដល់វប្បធម៌ខ្មែរដែលកាន់សាសនាព្រះពុទ្ធបានយ៉ាងដូចម្តេចទៅ? ជាការពិតវិញនោះ មានអ្នកកាន់សាសនាគ្រីស្តជាច្រើននាក់ដែលមិនទទួលយកការរួមភេទមុនពេលរៀបការ។ ដូចដែលស្ត្រីបច្ចឹមប្រទេសដែលជាអ្នកកាន់សាសនាគ្រីស្តម្នាក់បានលើកឡើងថាៈ *"លើកលែងក្នុងមជ្ឈដ្ឋានអ្នកកាន់សាសនា ដែលនៅមានមនុស្សមួយចំនួនរង់ចាំដល់ពេលរៀបការដោយរក្សាភាពបរិសុទ្ធរបស់ខ្លួនជានិច្ច ហើយក្រោយពេលរៀបការ ពួកគេក៏នៅតែរក្សាភក្តីភាពចំពោះគូស្វាមីភរិយារបស់គេដដែល។ សំរាប់ប្រវត្តិនៃគ្រីស្តសាសនារបស់ខ្ញុំវិញ តម្រូវឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រី"*[៥៦] បន្ថែមពីលើនេះទៀត សំរាប់វប្បធម៌របស់បរទេសវិញ ក៏នៅមានកត្តាជាច្រើនទៀត ដែលអាចនាំឱ្យយុវវ័យឈានទៅរកការរួមភេទនៅថ្ងៃបុណ្យសង្សារ។ ផ្អែកតាមវិទ្យាសាស្ត្រ ទស្សនវិស័យលើផ្នែក"ជីវសាស្ត្រ" បុរសនិងស្ត្រីមានតម្រូវការក្នុងការរួមភេទដូចគ្នា ដែលនោះជាផ្នែកមួយនៃធម្មជាតិរបស់មនុស្ស។[៥៧] នៅមាន"ឱកាស"មួយសំរាប់យុវជន និងយុវនារីដើម្បីចេញដើរកំសាន្តជាមួយគ្នានៅថ្ងៃបុណ្យ និងឱកាសឈប់សំរាកមួយចំនួន។[៥៨] ការលូតលាស់ផ្នែក"សេដ្ឋកិច្ច" "ភាវូបនីយកម្ម" និងសំលៀកបំពាក់សិចស៊ីក៏បង្កើតឱ្យមាន"ភាពទំនើបទាន់សម័យ"ចំពោះយុវវ័យ និងធ្វើឱ្យពួកគេឈានទៅរកការណាត់ជួប ហើយឈានទៅដល់ការមានទំនាក់ទំនងផ្លូវភេទ។ បន្ថែមលើសពីនេះ ក៏នៅមកពី"បរិយាកាស"ក្នុងសង្គមផ្សេងៗដូចជា ហាងម៉ាស្សា ក្លឹបរាត្រី មជ្ឈមណ្ឌលកំសាន្ត និងខ្ទមតូចៗនៅតាមមាត់ទឹកក្នុងទីកន្លែងកំសាន្តផ្សេងៗនៅតាមជាយក្រុងភ្នំពេញ ដែលជា

---

54 Vuthy, B. (2006). *Op. cit.*, p. 47.
55 *Ibid.*
56 Soprach, T. (2008). *Op cit.*, p. 7.
57 *Ibid.*, p. 1.
58 Wallquist, L, *Op. cit.*, p. 10.

មូលហេតុចំបងក្នុងសង្គមយុវវ័យ ។[៥៩] តាមរយៈរូបភាព និង"វីដេអូអាសអាភាស"ផ្សេងៗក៏ជាហេតុផលធ្វើឱ្យមានទំនាក់ទំនងផ្លូវភេទមុនពេលរៀបការផងដែរ ជាមួយនឹងគ្នានោះក៏បង្កើតអោយមានករណីអំពើហឹង្សា និងរំលោភសេពសន្ថវៈទៀតផង ។[៦០] ដើម្បីជាសេចក្ដីបញ្ជាក់ក្នុងចំណុចនេះ កញ្ញា**អាលី** ក៏បានចែករំលែកអំពីបទពិសោធន៍របស់នាងជាមួយនឹងអតីតមិត្តប្រុសនាង ដែលបានបង្ខំឱ្យនាងមើលរឿងអាសអាភាសនៅក្នុងកំព្យូទ័រដោយបានរៀបរាប់ថា:

> *"នៅថ្ងៃមួយ ខ្ញុំបានទៅផ្ទះគាត់ដើម្បីខ្ចីឌីសកម្មវិធី Window ដើម្បីអនុវត្តមេរៀននៅសាលា ។ ពេលនោះ អ៊ំស្រីរបស់គាត់មិននៅនោះទេ គឺមានតែខ្ញុំនិងគាត់តែប៉ុណ្ណោះ ។ នៅពេលគាត់ចូលទៅយកឌីសនៅក្នុងបន្ទប់ ខ្ញុំក៏និយាយឱ្យគាត់ថា ប្រយ័ត្នច្រឡំឌីសផ្សេង ហើយស្រាប់តែគាត់អូសដៃខ្ញុំទៅអង្គុយមុខកុំព្យូទ័រ ហើយយកឌីសរឿងសិចមកចាក់ឱ្យខ្ញុំមើលតែម្ដង ។ ពេលនោះខ្ញុំភ័យតិចៗដែរ ព្រោះមិនធ្លាប់មើលរឿងនេះពីមុនមកទេ ឈុតខ្លះគួរឱ្យខ្ពើម គួរឱ្យញញើត ឈុតខ្លះខ្ញុំមិនហ៊ានមើលទេព្រោះវាអាក្រក់ខ្លាំងពេក ។ ពុំមានអ្វីកើតឡើងរវាងខ្ញុំនិងគាត់នោះទេ ហើយខ្ញុំក៏បានតាំងចិត្តរួចរាល់ហើយថា មិនថ្វីទេបើគ្រាន់តែមើល សំខាន់គឺនៅលើការតាំងចិត្តតែប៉ុណ្ណោះ ។ គាត់ប្រាប់ថាបុរសគ្រប់គ្នាសុទ្ធមានឌីសប្រភេទនេះជារឿងធម្មតា ។ [**អាលី ភេទស្រី អាយុ ២៣ឆ្នាំ ជានិស្សិត, ផ្ទះជួលមិត្តភក្តិនៅទួលទំពូង**]*

កត្តាមួយទៀត សំរាប់កម្មវិធីសិក្សាសាលាក្នុងឆ្នាំ២00២-២00៣ MoEYS បានធ្វើការវាយតំលៃជាផ្លូវការថា មានតែនិស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ១ក្នុងចំណោម៩តែប៉ុណ្ណោះដែលមានការងារធ្វើត្រូវតាមជំនាញ ។[៦១] យុវវ័យមួយចំនួនទទួលរងភាព"តានតឹង"ខ្លាំងនៅពេលពួកគេមិនអាចរកការងារបានធ្វើ ហើយពួកគេបានគិតខ្វល់ខ្វាយពីអនាគតរបស់ពួកគេនៅពេលពួកគេកំពុងសិក្សានៅឡើយ ដែលងាយនឹងធ្វើឱ្យពួកគេមានការរួមភេទ ដើម្បីកាត់បន្ថយភាព"តានតឹង"នៅក្នុងខ្លួន ។[៦២]

## VI. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

លទ្ធផលរួមអំពីថ្ងៃបុណ្យសង្សារទាំងនេះបង្ហាញឱ្យឃើញថា យុវវ័យទាំងអស់ពុំទាន់យល់ច្បាស់អំពីដើមកំណើតពិតប្រាកដនៃថ្ងៃបុណ្យសង្សារនៅឡើយទេ ប៉ុន្តែពួកគេគ្រាន់តែដឹងថា ថ្ងៃនោះមានឥទ្ធិពលមកពីវប្បធម៌បរទេស តាម

---

[59] Soprach, T. (2008). *Op. cit.*, pp. 16-22.
[60] Fordlham, G. (2005). *"WISE" BEFORE THEIR TIME: Young People, Gender-based Violence and Pornography in Kandal Stung District*. Phnom Penh: World Vision. pp. 94-95.
[61] Mysliwiec, E. (2005). *Youth, Volunteering and Social Capital in Cambodia: Results of a Feasibility Study Conducted for a Cambodian Youth Service Program*. Youth Star. p. 25. Phnom Penh. Retrieved November 14, 2007 from http://www.youthstarcambodia.org/documents/Feas%20Study.pdf
[62] Soprach, T. (2008). *Op. cit.*, p. 36.

រយៈប្រព័ន្ធផ្សព្វផ្សាយនានា។ ពួកគេនាំគ្នាធ្វើតាមការនិយមតៗគ្នា ហើយថ្ងៃបុណ្យសង្សារនោះកាន់តែទទួលបានការពេញនិយមពីយុវវ័យពីមួយឆ្នាំទៅមួយឆ្នាំ ហើយរយៈពេលប៉ុន្មានឆ្នាំក្រោយៗមកនេះ ថ្ងៃបុណ្យសង្សារកាន់តែមានឥទ្ធិពលខ្លាំងទៅលើយុវវ័យភាគច្រើនដែលជាកូនអ្នកធូរធារក្នុងទីក្រុង។ លទ្ធផលបានបង្ហាញឱ្យឃើញថា មានចំនួនដល់ទៅជាងពាក់កណ្ដាលនៃអ្នកផ្ដល់បទសំភាសន៍នៅក្នុងការសិក្សានេះសុទ្ធតែរីករាយនឹងការមានទំនាក់ទំនងផ្លូវភេទនៅក្នុងថ្ងៃនោះ ហើយយ៉ាងហោចណាស់មានមួយចំនួនបានបាត់បង់ភាពបរិសុទ្ធ។ ជាងនេះទៅទៀត មានគូសង្សារមួយគូ ដែលមិនបានប្រើប្រាស់ស្រោមអនាម័យ ដោយគេជឿជាក់ថា នារីជាដៃគូនៅបរិសុទ្ធ។ ក្នុងករណីមួយទៀត **សាន់ឌី** ក៏បានចែករំលែកអំពីការផ្លាស់ប្ដូរនៃការរួមភេទរបស់នាង ដោយងាកមករកការប្រើប្រាស់ស្រោមអនាម័យវិញនៅថ្ងៃបុណ្យសង្សារ បន្ទាប់ពីនាងយកកូនចេញពីក្នុងផ្ទៃកាលពីបីកន្លងមក។ ករណីផ្សេងមួយទៀត មានយុវជនម្នាក់ដែលបានបង្ខំមិត្តស្រីរបស់ខ្លួនឱ្យមើលវីដេអូអាសអាភាសក្នុងផ្ទះសំណាក់។

ក្នុងការសិក្សានេះក៏បានបញ្ជាក់ឱ្យឃើញថា យុវវ័យភាគច្រើនមានបំណងចង់បង្កើនការយល់ដឹងរបស់គេលើបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ប៉ុន្តែហាក់មានពិបាកនៅក្នុងការផ្លាស់ប្ដូរឥរិយាបថរបស់ពួកគេ ដោយសារបញ្ហានៃភាពជឿទុកចិត្តរវាងគូស្នេហ៍។ ការសិក្សានេះបញ្ជាក់យ៉ាងច្បាស់ថា មានយុវវ័យក្នុងចំនួនជាច្រើនដែលមានការរួមភេទនៅក្នុងថ្ងៃបុណ្យសង្សារ។ បើតាមសំដីរបស់ **ណាក់** បានឱ្យដឹងថា ផ្ទះសំណាក់ជាច្រើនពេញនៅក្នុងថ្ងៃនោះ ហើយគេអាចរកបន្ទប់ជួលបាននៅផ្ទះសំណាក់ទីបី។ លើសពីនេះទៀត នៅពេលរសៀល និងពេលយប់ ជាពេលដែលពេញនិយមសំរាប់យុវវ័យទូទៅមានការរួមភេទនៅថ្ងៃបុណ្យសង្សារ។ បើទោះបីជាមានការដាក់បំរាម កំណត់ម៉ោងរបស់ឪពុកម្ដាយទៅលើពួកគេយ៉ាងណាក៏ដោយ បើផ្អែកទៅតាមការនិយាយរៀបរាប់របស់អ្នកផ្ដល់បទសំភាសន៍ ដែលជាទូទៅបណ្ដាលមកពីការខ្វះភាពយល់ដឹងច្បាស់អំពីព្រឹត្តិការណ៍ទាំងឡាយដែលលកើតមានចំពោះកូនៗ ក្នុងនោះមានដូចជាការមានទំនាក់ទំនងផ្លូវភេទ ការប្រថុយប្រថានទៅនឹងការឆ្លងជម្ងឺផ្សេងៗមាន HIV/AIDS/STIs ការមានផ្ទៃពោះដោយចៃដន្យ និងការរំលោភសេពសន្ថវៈជាដើម។ មានតែអ្នកផ្ដល់ការសំភាសន៍ពីរនាក់ប៉ុណ្ណោះដែលបានបញ្ជាក់ប្រាប់ថា ឪពុកម្ដាយរបស់គេបានដាស់តឿនអំពីទំនាក់ទំនងផ្លូវភេទ។

**- គោលដៅបន្ថែមសំរាប់ការសិក្សាស្រាវជ្រាវបន្ត**

- ត្រូវការធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតលើការរងឥទ្ធិពលពីវប្បធម៌លោកខាងលិចលើវប្បធម៌ខ្មែរ។
- ត្រូវការការសិក្សាបែបគុណភាពវិស័យនៅថ្ងៃបុណ្យសង្សារខាងមុខនេះក្នុងចំណោមយុវវ័យដែលជាកូនអ្នកមានធូរធារដែលប្រឈមមុខនឹងការមានទំនាក់ទំនងផ្លូវភេទដោយគ្មានសុវត្ថិភាព។
- ត្រូវការការស្ទាបស្ទង់ជាទូទៅបន្ថែមទៀតលើឥរិយាបថនៃបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ព្រមទាំងជំនឿជាក់របស់យុវវ័យ។

- **ការរៀបចំកម្មវិធី**
  - បង្កើតឱកាសផ្សេងៗសំរាប់បង្កើនការយល់ដឹងលើបញ្ហាជុំវិញថ្ងៃបុណ្យសង្សារ និងបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ដូចជា ការរួមភេទប្រកបដោយសុវត្ថិភាពជាដើម។
  - កម្មវិធី SRH/HIV សំរាប់យុវវ័យគួរតែត្រូវបង្កើតឡើងនៅមុន និងក្នុងថ្ងៃបុណ្យសង្សារ យោលទៅតាមលទ្ធផលនៃការសិក្សានេះ។

- **ប្រព័ន្ធផ្សព្វផ្សាយ**
  - ផ្តល់ព័តិមានអំពីលទ្ធផលនៃការសិក្សានេះឱ្យបានមុន និងនៅថ្ងៃបុណ្យសង្សារ។

- **អជ្ញាធរក្នុងតំបន់ និងភ្នាក់ងារសមត្ថកិច្ច**
  - ពង្រឹងសន្តិសុខនៅក្នុងថ្ងៃបុណ្យសង្សារនៅតាមតំបន់ផ្សេងៗដែលមានបញ្ជាក់នៅក្នុងការសិក្សានេះ។
  - ត្រួតពិនិត្យទៅលើភាពយន្តវីដេអូអាសអាភាសនៅតាមផ្ទះសំណាក់។

- **ឪពុកម្តាយ និងគ្រូបង្រៀន**
  - ផ្តល់ការណែនាំទូន្មានអំពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ព្រមទាំងការឆ្លងមេរោគផ្សេងៗដូចជា HIV/AIDS ដល់កូនៗ និងសិស្ស។ យ៉ាងហោចណាស់ ក៏និយាយប្រាប់ដល់កូនៗថា: "កុំនាំជម្ងឺអេដស៍ចូលផ្ទះ!" "ប្រយ័ត្នមានផ្ទៃពោះ!" "កុំទុកចិត្តសង្សាររបស់កូនពេក!" នៅមុន និងនៅថ្ងៃបុណ្យសង្សារ។
  - ព្យាយាមបង្កើតឱ្យមានទំនាក់ទំនងបើកចំហជាមួយនឹងកូនៗ ដោយការពិភាក្សាលើបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជឱ្យបានប្រចាំ។
  - យកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នចំពោះអ្វីដែលកូនៗ និងសិស្សប្រព្រឹត្តនៅក្នុងថ្ងៃនោះ។

- **យុវវ័យ**
  - ត្រូវបង្កើនការយល់ដឹងពីបញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ក៏ដូចជាការឆ្លងមេរោគ HIV និងប្រើប្រាស់ស្រោមអនាម័យប្រសិនបើអ្នកសំរេចចិត្តមានការរួមភេទ។
  - ដឹងពីវិធីបង្ការនិងការពារខ្លួន ក៏ដូចជាជីវិតអ្នក។
  - ត្រូវដឹងថា អ្នកមានសិទ្ធិក្នុងការជ្រើសរើសថាគួរមានការរួមភេទ ឬក៏អត់។

# VII. ឯកសារយោង


Ann. (2008, Feb. 11). One fifth of teenagers will have sex on Saint Valentine's Day in Bang Kok. *Nation*, Retrieved February 12, 2008 from http://www.asiaone.com/News/Education/Story/A1Story20080211-49118.html

Baker, L.T. (1994). *Doing Social Research*. California State University, San Marcos: McGraw-Hill, Inc. p. 237

Bearup, L.S. (2003). *Paupers and Princelings: Youth Attitudes Toward Gangs, Violence, Rape, Drugs, and Theft*. Phnom Penh: GAD/C.

Cambodian Midwives' Association. (1999). Cited by Gender Watch No. 4 (2001). *My wedding day … the day my fiancée died*. Phnom Penh: GAD/C. p. 2

Chansy, C. (2008, Feb. 15). Panel Tells Youths To Use Valentine's Day Caution. *Cambodia Daily*, p. 20.

ក្រិត្យក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា (ឆ្នាំ១៩៨៩) *ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ មាត្រាទី៥ ជំពូក២* ត្រូវបានដកស្រង់ចេញពីសៀវភៅកម្រង ឯកសារច្បាប់ បោះពុម្ពលើកទី ៣ (ឆ្នាំ២០០១) នៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ ទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ធ្វើនៅភ្នំពេញ។

Decree of State Councils of Cambodian State (1989). *Marital Law, Article 5, Chapter 2.* Cited by 3rd edition Legal Document Braid. (2001), United Nations Cambodia Office of the High Commissioner for Human Rights. Phnom Penh.

Doyle, K. and Samean, Y. (2003, April 19-20). Youth of Today: Gang Rape Has Become the Sport of the Young Generation. *Cambodia Daily*, p. 1.

Fordham, G. (2003). *Adolescent Reproductive Health in Cambodia: Status Policies, Programmes and Issues*. Phnom Penh: POLICY Project. Retrived December 23, 2008 from http://www.policyproject.com/pubs/countryreports/ARH_Cambodia.pdf

Fordlham, G. (2005). *"WISE" BEFORE THEIR TIME: Young People, Gender-based Violence and Pornography in Kandal Stung District.* Phnom Penh: World Vision.

Fox., C. (2008, Feb. 15). CAMBODIAN CUPID: Flower vendors took to the streets to sell roses on Valentine's Day in Phnom Penh on Thurday. *Cambodia Daily*, p. 1.

Grant, L. (2004). *From Cotton to Precious Gems: The Use and Abuse of Commercial Sex Workers in The Context of the Police, Law, and Society in Cambodia.* Phnom Penh: Playing Safe Project, CARE International in Cambodia, WAC, EU/UNFPA.

Hayden, R. (2006). *Young Men Like Us: Experiences and Changes in Sex, Relationships and Reproductive Health among Young, Urban Cambodian Men*. Phnom Penh: Peer Ethnographic Research on Urban Male Sexual Behaviour. Playing Safe Project, CARE Cambodia, KYA, EU/UNFPA.

Hoefinger, H. (2008). *Self-Harming Among the Broken-Hearted in Cambodia.* Unpublished manuscript. Goldsmiths, University of London, UK. Correspondence: h.hoefinger@gold.ac.uk

Jejeebhoy, J.S. and Bott, S. (2003). *South & East Asia: Non-consensual sexual experiences of young people: A review of the evidence from developing countries*, No.16. New Delhi: Population Council.

Kranhong. (2008, February 15). This Valentine's Day There Were Not A Group of Students Who Sold Flower To Support Orphanages. *Reak Smey Kampchea*, p. 2b.

Longfield, K., Klein,M. and Berman, J. (2002). *Working Paper No. 51: Criteria for trust and how trust affects sexual decision-making among youth*, Washington, DC: PSI Research Division. Retrieved December 24, 2008 from http://www.psi.org/research/wp/WP51.pdf

Mysliwiec, E. (2005). *Youth, Volunteering and Social Capital in Cambodia: Results of a Feasibility Study Conducted for a Cambodian Youth Service Program*. Youth Star. p. 25. Phnom Penh. Retrieved November 14, 2007 from http://www.youthstarcambodia.org/documents/Feas%20Study.pdf

រដ្ឋសភាជាតិ (ឆ្នាំ ១៩៩៧) *ច្បាប់ស្តីពីការរំលូត មាត្រាទី៨ ជំពូក២* ត្រូវបានដកស្រង់ចេញពី សៀវភៅកម្រង ឯកសារច្បាប់ បោះពុម្ពលើកទី ៣ (ឆ្នាំ២០០១) នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ធ្វើនៅភ្នំពេញ។

National Assembly. (1997). *Abortion Law, Article 8, Chapter 2*. Cited by 3rd edition Legal Document Braid. (2001), United Nations Cambodia Office of the High Commissioner for Human Rights. Phnom Penh.

NCHADS. (2003). *Behavioral Sentinel Survey (BSS) V:SEXUAL BEHAVIOR AMONG URBAN SENTINEL GROUPS, CAMBODIA 2001*. Phnom Penh: MOH. Retrieved February 12, 2008 from http://www.nchads.org/Publication/BSS/BSS2001.PDF

NCHADS. (2007, June 28). *Press release: Government announces official HIV prevalence rate*. Retrieved November 2, 2007 from http://www.nchads.org/pressrelease/28-06-07%20en.pdf

NCHADS. (2008). *2005 Cambodian STI Prevalence Survey: Integrated Biological and Behavioral Survey*. Phnom Penh: MoH.Retrieved February 12, 2008 from http://www.nchads.org/Publication/SSS/SSS%202005.pdf

National Institute of Public Health and National Institute of Statistics. (2006). *Cambodia Demographic and Health Survey (CDHS) 2005*. Phnom Penh: MOH&MOP

National Institute of Statistics. (2004). *Cambodian Inter-censual Population Survey 2004,* General Report, Phnom Penh: MOP.

Ponter A.B., Ponter M.E., Neth Barom and Hean Sokhom. (2006). 10th Socio-cultural Research Training Workshop on Issues in Socio-cultural Research on 02-31 March 2006. Phnom Penh: The Research and Development Unit of The RUPP and HBF.

Ramage, I. (2004). *Cambodia Baseline Survey*. Phnom Penh: RHIYA Project, EU/UNFPA.

Research Evaluation Committee Members. (2006). *Research Proposal.* Phnom Phnom Penh: Royal University of Phnom Penh and Heinrich Boll Foundation.

Sedgh, G., Henshaw, S., Singh, S., Ahman, E. and Shah, I. (2007, October 13). Induced Abortion: Estimated Rates and Trends Worldwide. *Lancet*, Vol. 370, p. 1338.

Smith, R. (2007). *Let's Go for a Walk: Sexual Decision-Making among Clients of Female Entertainment Service Workers in Phnom Penh*. Phnom Penh: PSI & FHI

Soprach, T. (2004). *GANG RAPE: The Perspective of Moto-Taxi Drivers across Cambodia.* Phnom Penh: Playing Safe Project, CARE Cambodia, EU/UNFPA.

Soprach, T. (2008). *The Impact of Premarital Sex Among Young People in Cambodia*. Phnom Penh: University of Cambodia.

Sovannara, K. (2008, February 17-23). Phnom Penh: Cambodian Youth Gathering at Flower Stores to Buy Flowers on Valentine's Day. *Cambodia Weekly*, p. 1.

Stern, A. (2008, November 3). Study Links Teen Pregnancy To Sexy TV Shows in US. *Reuters*. Retrieved December 10, 2008 from http://www.reuters.com/article/newsOne/idUSTRE4A20HL20081103

Sunran, K. (2004). *Cambodia National: Youth Risk (11-18 years) Behaviour Survey*. Phnom Penh: MoEYS, UNICEF & UNESCO.

Tarr, C.M. (1996a). *Contextualizing the Sexual Culture (s) of Young Cambodians.* Phnom Penh: University of Fine Arts.

Tarr, C.M. (1996b). *People in Cambodia don't talk about sex, they simply do it: A study of the Social and Contextual Factors Affecting Risk-Related Sexual Behavior among Young Cambodians*. Phnom Penh: University of Fine Arts.

Tarr, C.M. (1996c). *Young People and HIV in Cambodia – Meaning, Context and Sexual Cultures.* Phnom Penh: University of Phnom Penh.

Tarr, C.M. (1996d). *Study of Contextual Factor Affecting Risk-Related to sexual Behavior among Young Cambodia.* Phnom Penh: University of Phnom Penh.

Vuthy, B. (2006). *RHIYA Cambodia Endline Qualitative Survey*. Phnom Penh: EU/UNFPA.

Wallquist, L. (2002). *Youth in Cambodia: Organizations, Activities and Policies.* Phnom Penh: Forum Syd.

WHO. (2004). *Unsafe abortion: Global and Regional Estimated of the Incidence of Unsafe Abortion and Associated Mortality in 2000*. Geneva. Cited by MoH. (2006). National Strategic for Reproductive and Sexual Health in Cambodia (2006-2010). Phnom Penh, Cambodia. Retrieved November 2, 2007 from http://cambodia.unfpa.org/docs/SRSH_Final.pdf

Wilkinson, D.J., and Fletcher, G. (2002). *Sweetheart Relationship in Cambodia: Love, Sex & Condoms in the time of HIV,* Phnom Penh: PSI.

Wilkinson, D.J., Bearup, L.S. and Soprach, T. (2005). Paper: *Youth Gang Rape in Phnom Penh.* SEX WITHOUT CONSENT: Young People in Developing countries. Edited by Jejeebhoy, J. S., Shah, I. and Thapa. London/New York: Zed Book. pp. 158-168.

World Bank. (2007). *Cambodian Sharing Growth: Equity and Development Report 2007.* Phnom Penh.

**Internets:**

Retrieved February 12, 2008 from http://www.pictureframes.co.uk/pages/saint_valentine.htm

Retrieved February 12, 2008 from http://www.history.com/content/valentine/history-of-valentine-s-day

# សេចក្តីបញ្ជាក់បន្ថែម

**សេចក្តីបន្ថែមទី១: ការសុំការយល់ព្រម និងការសន្ទនាជាមួយសំនួរបែបពាក់កណ្តាលរចនាសម្ព័ន្ធ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ .........................................ស្ម័គ្រចិត្តធ្វើការស្រាវជ្រាវអោយបេក្ខជនឈ្មោះ **តុង សុប្រាជ្ញ** សំរាប់ការសិក្សាបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកសុខភាពសាធារណៈ នៃសាកលវិទ្យាល័យ កម្ពុជា។ ការសិក្សានេះគឺជាការសិក្សាដ៏តូចមួយបែបគុណភាពវិស័យអំពីទំនាក់ទំនងសេចក្តីស្នេហា ក្នុងចំណោមយុវវ័យនៅទីក្រុងភ្នំពេញនៅថ្ងៃបុណ្យសង្សារទី១៤ខែកុម្ភៈឆ្នាំ២០០៨។ ការសិក្សានេះត្រូវបានរៀបចំឡើង ដើម្បីបញ្ជាក់បន្ថែមលើការស្រាវជ្រាវរបស់គាត់មួយអំពីទំនាក់ទំនងសេចក្តីស្នេហា និងការរួមភេទក្នុងចំណោមយុវវ័យ និងផលប៉ះពាល់។ ការសន្ទនានេះត្រូវបានប្រព្រឹត្តទៅក្នុងមួយសប្តាហ៍ បន្ទាប់ពីថ្ងៃបុណ្យសង្សារកន្លងផុតទៅថ្មីៗនេះ ដើម្បីអោយអ្នករំលឹកឡើងវិញនូវអ្វីដែលអ្នកបានធ្វើនៅពេលនោះ។

តាងនាមអោយបេក្ខជន ខ្ញុំបាទ/នាងខ្ញុំ សូមថ្លែងអំណរគុណអ្នកទុកជាមុន ក៏ដូចជាពេលវេលារបស់អ្នកដែលបានផ្តល់ការសន្ទនាដ៏មានសារសំខាន់នេះ។ រាល់ការសន្ទនាទាំងនេះនឹងត្រូវបានរក្សាជាការសំងាត់។

ឈ្មោះអ្នកផ្តល់ការសំភាសន៏(ឈ្មោះស្រលាញ់ក្រៅពីឈ្មោះផ្ទាល់ខ្លួន).......................................................

ភេទ....................... អាយុ ................មុខរបរ.........................................................................

ទីកន្លែង.........................................................កាលបរិច្ឆេទ...............................ពេលវេលា.........................

.ទីកន្លែងដែលបានណាត់ជួបមុនពេលសំភាសន៏នៅថ្ងៃបុណ្យសង្សារដែលគូសង្សារនៅជាមួយគ្នា....................................
...................................................................................................។

**សំនួរទី១:** តើអ្នកអាចរៀបរាប់អំពីសេចក្តីស្រលាញ់របស់អ្នកជាមួយសង្សាររបស់អ្នកបានដែរឬទេ? តើចាប់ផ្តើមតាំងពីពេលណាមក? តើអ្វីទៅដែលធ្វើអោយអ្នកធ្លាក់ក្នុងអន្លង់ស្នេហ៍? តើមានអត្តសញ្ញាណ ឬក៏មានឥទ្ធិពលអ្វី ដែលធ្វើឱ្យអ្នកដឹងថា អ្នកស្រលាញ់គ្នា?

**សំនួរទី២:** ជាទូទៅអ្នកច្រើនតែនាំគ្នាទៅលេងទីណាខ្លះ? ហេតុអ្វី?

**សំនួរទី៣:** មានឥទ្ធិពលអ្វីដែលធ្វើអោយអ្នក ក៏ដូចជាយុវវ័យដ៏ទៃទៀតចេញដើរកំសាន្តជាមួយគូសង្សាររបស់អ្នក? តើអ្នកអាចរៀបរាប់នូវអ្វីដែលអ្នកបានប្រព្រឹត្តនៅថ្ងៃបុណ្យសង្សារកន្លងផុតទៅថ្មីៗនេះបានដែរឬទេ?

**សំនួរទី៤:** តាមយោបល់របស់អ្នក តើមានឥទ្ធិពលអ្វីដែលធ្វើអោយអ្នកក៏ដូចជាជាយុវវ័យដ៏ទៃទៀតគិតថា ថ្ងៃបុណ្យសង្សារជាថ្ងៃសំខាន់? តើឪពុកម្តាយរបស់អ្នកយល់ឃើញយ៉ាងដូចម្តេចដែរ?

## សេចក្តីបន្ថែមទី២: ការសិក្សាវិភាគលើករណីនីមួយៗ

### ករណីទី១: តូច អាយុ២៣ឆ្នាំ ភេទប្រុស ជាបុគ្គលិកកាស៊ីណូ, ក្លឹប Casa

សេចក្តីស្នេហារវាងខ្ញុំនិងសង្សារខ្ញុំចាប់ផ្តើមតាំងពីថ្ងៃបុណ្យភ្ជុំបិណ្ឌខែតុលាឆ្នាំ២០០៧មកម្ល៉េះ ដោយពួកយើងបានស្គាល់គ្នាតាមរយៈមិត្តភក្តិស្រីខ្ញុំម្នាក់។ យើងទាំងពីរចាប់ផ្តើមឡើងដោយការសម្លឹងមើលគ្នាទៅវិញទៅមក ដោយនាងស្លៀកសំលៀកបំពាក់ឡូយឆាយ ហើយបញ្ចេញកាយវិការដើម្បីឱ្យខ្ញុំចាប់អារម្មណ៍នឹងនាង។ យើងក៏ចាប់ផ្តើមនិយាយសាសងគ្នា ហើយនាងក៏បានបបួលខ្ញុំទៅមើលកុន។ បន្ទាប់មកយើងទាំងពីរក៏ចាប់ផ្តើមយល់ពីអារម្មណ៍គ្នាទៅវិញទៅមក។ ហើយ សង្សារទីបីរបស់ខ្ញុំបច្ចុប្បន្នមានអាយុ១៧ឆ្នាំ។

ជាទូទៅ យើងទាំងពីរតែងតែនាំគ្នាទៅជជែកគ្នាលេងនៅតែហាងគុជក្រោយវាំង ដែលយុវវ័យភាគច្រើនគេនិយមចូលចិត្តទៅ។ នៅថ្ងៃធម្មតា ពួកយើងនាំគ្នាទៅផ្ទះសំណាក់តែម្តង ចាប់ពីម៉ោង១រសៀលដល់ម៉ោង៦ល្ងាច ដោយចំនាយអស់៤ដុល្លារ នៅម្តុំស្រែអំបិលផ្លូវត្រសក់ផ្អែម។ បន្ទាប់ពីចាកចេញពីផ្ទះសំណាក់ យើងនាំគ្នាទៅញ៉ាំអី ហើយបន្តទៅក្លឹបរហូតដល់ម៉ោង១១យប់ ទើបត្រលប់ទៅផ្ទះ ដោយប្រាប់ម្តាយឪពុកថាទៅជប់លៀងខួបកំណើតមិត្តភក្តិ។ ក្លឹបកំសាន្តដែលយើងតែងតែនាំគ្នាទៅនោះមាន ក្លឹបតន្ត្រីខ្មៅ Gold Club មជ្ឈមណ្ឌលកំសាន្ត Rock និង Spark ជាដើម ហើយនៅថ្ងៃចុងសប្តាហ៍ពេលរសៀលវិញ ពួកយើងទាំងពីរតែងតែទៅ Casa Club និង Spark។ យើងចូលចិត្តទៅកំសាន្តនៅទីជិតៗជាជាងទៅកន្លែងឆ្ងាយ ដោយសារទីមួយអាកាសធាតុក្តៅពេកអស់កំលាំងទៀត ចំណែកទីពីរវិញ យើងត្រូវចំណាយអស់សាំងច្រើន ហើយម្យ៉ាងទៀត ទោះជាទៅទីណាក៏ដូចតែគ្នា គ្មានអ្វីប្លែក។

ក្នុងរយៈពេល៥ម៉ោងនៅក្នុងផ្ទះសំណាក់ យើងរួមភេទបានពី៣ទៅ៤ដង ហើយនៅពេលរួមភេទជាមួយនាងនៅលើកទីមួយ ខ្ញុំមិនបានប្រើប្រាស់ស្រោមអនាម័យនោះទេ ពីព្រោះយើងមានអារម្មណ៍ស្រើបស្រាលខ្លាំងដូចគ្នា ដូច្នេះយើងមិនបានគិតខ្វល់ពីអ្វីទាំងអស់ ដោយម្យ៉ាងខ្ញុំគិតថា នាងនៅក្មេង និងនៅក្រមុំ ដូចនេះខ្ញុំមិនចាំបាច់ខ្លាចឆ្លងជម្ងឺអ្វីនោះទេ។ ប៉ុន្តែ នៅពេលខ្ញុំចាប់ផ្តើមបញ្ចូលប្រដាប់ភេទខ្ញុំទៅក្នុងទ្វារមាសនាង នាងព្យាយាមគ្បៀតហើយថ្ងូរឈឺតិចៗ ដោយយកដៃទប់ខ្ញុំ ហាក់ដូចជានាងនៅបរិសុទ្ធអញ្ចឹង។ តាមពិតទៅនៅពេលខ្ញុំបញ្ចូលប្រដាប់ភេទរួចហើយ ធ្វើឱ្យខ្ញុំមានអារម្មណ៍ថាដូចគ្នាពេលដែលខ្ញុំរួមភេទជាមួយសង្សារចាស់របស់ខ្ញុំដែលមិនមែនជានារីព្រហ្មចារីយ៏។ កាលពីមុន នៅពេលខ្ញុំរួមភេទ ខ្ញុំតែងតែប្រើវិធីដកប្រដាប់ភេទចេញនៅពេលជិតចេញទឹកកាម ពីព្រោះខ្ញុំខ្លាចនាងមានផ្ទៃពោះ។ ប៉ុន្តែនៅពេលក្រោយៗមកទៀត នាងសូមឱ្យខ្ញុំប្រើស្រោមអនាម័យ ហើយខ្ញុំក៏បានយល់ព្រម ពីព្រោះវាក៏ជាការពិបាកផងដែរ ប្រសិនបើពេលណាមួយមានការភ្លាំងភ្លាត់ ហើយនាងមានកូន និងត្រូវយកចេញនោះ។ ខ្ញុំនិងនាងយល់ដឹងពីវិធីនៃការប្រើប្រាស់ស្រោម

អនាម័យ តាមរយៈទស្សនាវដ្តី និងការផ្សព្វផ្សាយនានាតាមទូរទស្សន៍។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនសូវខ្វល់បារម្ភអំពីការឆ្លងរោគនោះទេ ដោយខ្ញុំគិតថានាងនៅក្មេង ស្អាតបាត និងជាកូនអ្នកមានធូរធារ។ តែអ្វីដែលធ្វើឱ្យខ្ញុំមិនអស់ចិត្តនោះគឺរាល់លើក ដែលយើងមានទំនាក់ទំនងភេទសម្ព័ន្ធជាមួយគ្នា នាងមិនដែលចេញឈាមទាល់តែសោះ។ ខ្ញុំមានការសង្ស័យថា នាងមិនមែនជានារីបរិសុទ្ធ ដូច្នេះខ្ញុំក៏ព្យាយាមជជីកសួរនាងថា តើនាងធ្លាប់មានមិត្តប្រុសពីមុនមកដែរឬទេ ប៉ុន្តែនាងព្យាយាមគេចវេះមិនព្រមប្រាប់។ នៅថ្ងៃមួយនាងក៏យំហើយប្រាប់ខ្ញុំថា នាងពិតជាធ្លាប់មានសង្សារពីមុនមកមែន ដែលគេនោះជាកូនអ្នកមានម្នាក់ ហើយនាងក៏ធ្លាប់បានរួមភេទជាមួយសង្សារចាស់របស់នាងផងដែរ។ ប៉ុន្តែប៉ុន្មានខែក្រោយមកគេក៏ចាកចេញពីនាងទៅ។ នៅពេលនោះ ខ្ញុំគិតថាការស្រលាញ់មនុស្សម្នាក់មិនមែនត្រឹមតែគិតទៅលើភាពបរិសុទ្ធនោះទេ។ រំពេចនោះ ធ្វើឱ្យខ្ញុំក៏នឹកឃើញដល់សង្សារទីមួយរបស់ខ្ញុំដែលមានអាយុទើបតែ១៤ឆ្នាំ។ យើងទាំងពីរនាក់ស្គាល់គ្នានៅពេលរៀនភាសាអង់គ្លេសជាមួយគ្នា ហើយនាងក៏រស់នៅជាមួយអ៊ំស្រីរបស់គេក៏នៅក្បែរផ្ទះរបស់ខ្ញុំដែរ ប៉ុន្តែគ្មាននរណាម្នាក់ដឹងពីទំនាក់ទំនងរបស់យើងទាំងពីរនោះទេ។ នៅលើកដំបូងដែលខ្ញុំរួមភេទជាមួយនឹងនាង នាងក៏ធ្វើកាយវិការដូចគ្នានឹងសង្សារបច្ចុប្បន្នរបស់ខ្ញុំផងដែរគឺនាងមិនមែនជាក្មេងស្រីបរិសុទ្ធដូចគ្នា។ នៅពេលនោះ ខ្ញុំក៏មិនប្រើប្រាស់ស្រោមអនាម័យ ហើយក៏បានប្រើវិធីដកប្រដាប់ភេទចេញមុនពេលចេញទឹកកាមដូចគ្នាផងដែរ ព្រោះខ្ញុំគិតថានាងនៅក្មេងហើយស្អាត។ ប៉ុន្តែពេលក្រោយៗមកទៀត ខ្ញុំក៏ប្រើស្រោមអនាម័យនៅពេលរួមភេទ ដោយសារខ្ញុំបារម្ភខ្លាចនាងមានផ្ទៃពោះ និងនាំឱ្យមានបញ្ហាលំបាកស្មុគស្មាញច្រើន។ តាមការពិតទៅ នាងក៏ធ្លាប់មានមិត្តប្រុសម្តងរួចហើយដែរ ហើយនាងតែងតែខឹងពេលខ្ញុំសួរនាង។ ក្នុងកំឡុងពេលនោះ ខ្ញុំក៏តែងតែឧបត្ថម្ភដល់ការសិក្សារបស់នាងផងដែរ។ ប៉ុន្តែជាអកុសលយើងក៏បែកគ្នា ក្រោយពេលស្រលាញ់គ្នាបានបួនខែ។ ថ្មីៗនេះ ខ្ញុំបានលឺថា នាងរត់ចេញពីផ្ទះទៅតាមប្រុសផ្សេងបាត់ទៅហើយ។

នៅថ្ងៃបុណ្យសេចក្តីស្រលាញ់ ដែលគេតែងតែនិយមហៅថាថ្ងៃបុណ្យសង្សារនោះ ខ្ញុំបានឱ្យប្រាក់សង្សារបច្ចុប្បន្នរបស់ខ្ញុំចំនួន១៥ដុល្លារទិញអាវថ្មីដែលនាងស្រលាញ់ ដើម្បីពាក់នៅពេលព្រឹកថ្ងៃបុណ្យសង្សារនោះ។ យើងទាំងពីរនាក់យល់ឃើញថាថ្ងៃបុណ្យសង្សារជាថ្ងៃបុណ្យដ៏ពិសេសមួយ និងធ្វើឱ្យយើងមានអារម្មណ៍ថារីករាយខ្លាំង។ យើងគ្រាន់តែធ្វើតាមយុវវ័យផ្សេងទៀត ហើយម្យ៉ាងទៀតសម័យនេះជាសម័យអ៊ិនធឺរណេតទៅហើយ។ នៅថ្ងៃនោះ នាងបានមកយកខ្ញុំនៅម៉ោង១រសៀល ដើម្បីជិះម៉ូតូដើរលេងបន្តិច ហើយនាំគ្នាទៅរាំនៅCASA Club រហូតដល់ម៉ោង៤រសៀល ទើបបន្តទៅញ៉ាំអីនៅម៉ង់ដូ ជិត Hong Kong Center រួចទើបបន្តទៅញ៉ាំបៀរនៅ Mak Khnow រាត្រី ជិតផ្សារដើមថ្កូវ។ បន្ទាប់មកយើងក៏បែកគ្នាទៅផ្ទះរៀង២ខ្លួន។ នៅថ្ងៃនោះ យើងមិនបានរួមភេទជាមួយគ្នានោះទេ ពីព្រោះយើងចង់ចំណាយពេលដើរលេងឱ្យសប្បាយចិត្តជាង។

ចំពោះទំនាក់ទំនងស្នេហារវាងយើងទាំងពីរនាក់នេះគឺមានការដឹងលឺពីម្តាយឪពុករបស់ខ្ញុំ ប៉ុន្តែសំរាប់ខាងម្តាយឪពុករបស់នាងវិញនៅមិនទាន់ជ្រាបពីរឿងនេះនៅឡើយទេ ដោយសារតែពួកគាត់កាចពេក។ ចំណែកបងប្អូន របស់នាងវិញបានដឹងលឺរឿងនេះហើយ ហើយនៅប៉ុន្មានថ្ងៃខាងមុខនេះ ឪពុកម្តាយរបស់នាងក៏នឹងទទួលជ្រាបពីទំនាក់ទំនងរបស់យើងផងដែរ ដោយខ្ញុំនឹងទៅបង្ហាញខ្លួននៅចំពោះមុខពួកគាត់។

ខ្ញុំសូមនិយាយបកស្រាយអំពីបទពិសោធន៍នៃការរួមភេទដែលខ្ញុំធ្លាប់មានជាបន្តទៀត។ មុននឹងខ្ញុំរួមភេទជាមួយសង្សារទាំងអស់របស់ខ្ញុំ ខ្ញុំក៏ធ្លាប់បានរួមភេទជាមួយនឹងនារីរកស៊ីផ្លូវភេទផងដែរ ដែលកាលណោះខ្ញុំមានអាយុ១៣ឆ្នាំកំពុងរៀននៅបឋមសិក្សា។ ពេលនោះមិត្តភក្តិខ្ញុំធានាថាជាអ្នកចេញលុយអោយ ដោយបបួលទៅរកនារីរកស៊ីផ្លូវភេទជនជាតិយួននៅម៉ុស្ទីងមានជ័យ ហើយនារីនោះបានឱ្យខ្ញុំពាក់ស្រោមអនាម័យ។ នៅពេលដើរលេងដាច់យប់ម្តង១ មិត្តភក្តិរបស់ខ្ញុំដែលមានគ្នាពីបីទៅបួននាក់តែងតែយកនារីរកស៊ីផ្លូវភេទម្នាក់ទៅរួមភេទបូកជាមួយ។ ប៉ុន្តែពួកយើងប្រើស្រោមអនាម័យហើយក្នុងមួយយប់ពួកយើងរួមភេទម្នាក់ពីរដង ដោយនារីនោះក៏បានយល់ព្រមផងដែរ។ ហេតុផលទីមួយ គឺដោយសារយើងទាំងអស់គ្នាមានលុយតែ១០ដុល្លារម្នាក់ ហើយយើងត្រូវចំណាយ១៥ដុល្លារឱ្យទៅនារីរកស៊ីផ្លូវភេទនោះ ចំណែក៦ដុល្លារទៀត យើងត្រូវចំណាយទៅលើថ្លៃជួលបន្ទប់ ហើយលុយនៅសល់សំរាប់ចំណាយទៅលើការផឹកស៊ី។ ចំណែកហេតុផលទីពីរវិញ យើងចង់បង្ហាញដល់មិត្តភក្តិដែលមិនមានបទពិសោធន៍។

ខ្ញុំឈប់ចូលរួមក្នុងការរួមភេទជាក្រុមបែបនេះប្រហែលជាកន្លះឆ្នាំមកហើយ។ កាលពីមុន ដោយសារតែសង្សារចាស់ខ្ញុំផ្តល់ពេលវេលាឱ្យតិចតួចពេក គឺប្រហែលជាត្រឹមតែ១ម៉ោងទៅ២ម៉ោងប៉ុណ្ណោះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមានសង្សារថ្មីរបស់ខ្ញុំនេះធ្វើឱ្យខ្ញុំធុញទ្រាន់នឹងការរួមភេទសម្ព័ន្ធជាក្រុមហើយ បើទោះបីជាមិត្តភក្តិរបស់ខ្ញុំបបួលក៏ខ្ញុំមិនទៅដែរ ព្រោះខ្ញុំមានសង្សារដ៏ល្អម្នាក់នេះ។

សង្សារទីមួយរបស់ខ្ញុំជាគ្រូបង្រៀនភាសាអង់គ្លេសម្នាក់ និងមានអាយុដំណាលគ្នាជាមួយនឹងខ្ញុំ។ យើងចាប់ផ្តើមស្រលាញ់គ្នាតាំងពីឆ្នាំ២០០៤ ហើយមានទំនាក់ទំនងជាមួយគ្នាបានត្រឹមតែកន្លះឆ្នាំតែប៉ុណ្ណោះ។ ប៉ុន្តែនាង ពិតជានារីបរិសុទ្ធពីព្រោះនៅពេលយើងរួមភេទ នាងមានចេញឈាមនៅលើឥដ្ឋ ហើយស្រែកថាឈឺខ្លាំងណាស់ ចំណែកឯខ្ញុំវិញក៏ឈឺដូចគ្នាដែរ។ យើងមិនអាចរកស្រោមអនាម័យទាន់នោះទេ ដោយសារតែពួកយើងនៅលើផ្ទះ ហើយតណ្ហាចូលរៀង១ខ្លួនដូច្នេះពួកយើងក៏មិនបានគិតខ្វល់ពីអ្វីទាំងអស់។ ក្រោយ១មកទៀត យើងតែងតែប្រើស្រោមអនាម័យជាប្រចាំ ដោយបារម្ភខ្លាចមានផ្ទៃពោះ។ ប៉ុន្មានខែក្រោយមក ម្តាយឪពុកនាងបានមកយកនាង ត្រលប់ទៅខេត្តវិញ ហើយនាងក៏បានទូរស័ព្ទមកប្រាប់ខ្ញុំថា ឪពុកម្តាយនាងបង្ខំនាងឱ្យរៀបការ ដូច្នេះពួកយើងក៏បាន បែកគ្នាត្រឹមនេះទៅ។

## ករណីទី២: សាន់ឌី អាយុ២៤ឆ្នាំ ភេទស្រី ជានិស្សិត និងជាបុគ្គលិកក្រុមហ៊ុន, ស្ទួនច្បារអំពៅ

ខ្ញុំមានសង្សារគួរឱ្យស្រលាញ់ម្នាក់ បានស្គាល់គ្នាអស់រយៈពេលជិត៤ឆ្នាំមកហើយ បើគិតមកដល់បច្ចុប្បន្ននេះ។ យើងជាមិត្តរួមថ្នាក់នឹងគ្នា ហើយបានស្រលាញ់គ្នាក្នុងពេលចុះទស្សនកិច្ចសិក្សារបស់សាលាកាលពីថ្ងៃទី០៨មិនា២០០៥មកម្ល៉េះ។ ដំបូងឡើយ ខ្ញុំមិនទាន់ចាប់ចិត្តលើគាត់នៅឡើយទេ គ្រាន់តែរាប់អានជាមិត្តភក្តិធម្មតាតែប៉ុណ្ណោះ ម្យ៉ាងទៀត គាត់ជាសិស្សពូកែក្នុងថ្នាក់ និងមិនសូវនិយាយស្តីច្រើនទៀត។ ប៉ុន្តែនៅពេលមានកម្មវិធីនេះ ទើបធ្វើឱ្យខ្ញុំមានឱកាសសង្កេតមើលគាត់ ចំណែកឯគាត់ក៏មានឱកាសបង្ហាញនូវទឹកចិត្តស្រលាញ់ កាយវិការយកចិត្តទុកដាក់ខុសពីពេលដែលយើងរៀននៅក្នុងថ្នាក់។ ស្របពេលនោះ គាត់បានសារភាពប្រាប់ខ្ញុំថា គាត់បានលួចស្រលាញ់ខ្ញុំជាយូរមកហើយ តែពុំមានឱកាសនិយាយ។ គាត់បានសុំលេខទូរស័ព្ទខ្ញុំ ហើយតែងតែទូរស័ព្ទមកជជែកលេងជាមួយខ្ញុំជានិច្ច។ ចាប់តាំងពីបញ្ចប់ដំណើរកំសាន្តនោះរួចមក ពួកយើងក៏ចាប់ផ្តើមស្រលាញ់គ្នា ព្យាយាមសិក្សាពីគ្នាទៅវិញទៅមក។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងកាន់តែស្និទ្ធស្នាលនឹងគ្នា គាត់តែងតែបារម្ភពីខ្ញុំ មិនថាពីសុខភាព ការញ៉ាំចំណីអាហារ ឬការសិក្សាឡើយ។ គាត់សង្ហាណាស់ ហើយស្រស់ស្អាតក្នុងកែវភ្នែកខ្ញុំជានិច្ច។ គាត់កាន់តែធ្វើឱ្យខ្ញុំស្រលាញ់គាត់កាន់តែខ្លាំងឡើងថែមទៀត ពេលខ្លះគាត់ធ្វើឱ្យខ្ញុំខឹង ឬប្រច័ណ្ឌនឹងគាត់ ពេលខ្លះធ្វើជាង៉ក់ងរក៏មានដែរ តែអ្វីដែលធ្វើឱ្យខ្ញុំរភើប និងភ្ញាក់ផ្អើលបំផុតនោះ គឺគាត់តែងតែរៀបចំកម្មវិធីពិសេសសំរាប់ថ្ងៃខួបកំនើតខ្ញុំជារៀងរាល់ឆ្នាំ ដោយមិនឱ្យដឹងខ្ញុំដឹងមុនឡើយ។ ខ្ញុំគិតថាខ្ញុំជ្រើសរើសគាត់ពិតជាមិនខុសទេ ព្រោះគាត់មិនត្រឹមតែសង្ហា រៀនពូកែ មានការងារធ្វើត្រឹមត្រូវទេ ថែមទាំងស្រលាញ់ និងយកចិត្តទុកដាក់រូបខ្ញុំជាពិសេស។

យើងតែងតែនាំគ្នាដើរកំសាន្តនៅថ្ងៃចុងសប្តាហ៍ជាញឹកញាប់ ដើម្បីបង្កើនភាពស្និទ្ធស្នាល និងបង្កើតអនុស្សាវរីយ៍សំរាប់សេចក្តីស្រលាញ់របស់យើងទាំងពីរ។ ជាធម្មតា យើងតែងតែនាំគ្នាទៅលេងផ្ទះទឹកនៅកៀនស្វាយ ព្រោះនៅទីនោះស្ងាត់ល្អ ត្រជាក់ស្រួល។ ខ្ញុំដឹងថាមនុស្សពីរនាក់ដែលស្រលាញ់គ្នា កាលណានៅកន្លែងស្ងាត់ខ្ញុំតែពីរនាក់ រឿងអ្វីក៏អាចកើតឡើងបានដែរ តែខ្ញុំមិនបារម្ភពីបញ្ហាអ្វីទាំងអស់ ពីព្រោះខ្ញុំដឹងថា គាត់គ្មានគំនិតអាក្រក់មកលើខ្ញុំទេ។ តែវាមិនខុសពីពាក្យដែលគេថា ស្រលាញ់អ្វីៗក៏ហ៊ានលះបង់ដែរ។ កាលណោះ បន្ទាប់ពីញ៉ាំអាហារថ្ងៃត្រង់រួច ពួកយើងបានជជែកគ្នាលេងពីនេះពីនោះ ហើយការអោបថើបនៃបនិត្យតែងតែកើតមានឡើងជាធម្មតាសំរាប់គូសង្សារដូចយើងទាំងពីរ តែពេលនោះគាត់អោបខ្ញុំ យ៉ាងណែនខុសពីធម្មតា ហើយប្រាប់ថាស្រលាញ់ខ្ញុំខ្លាំងណាស់។ ខ្ញុំមើលទៅអ្វីៗហាក់ដូចជាខុសពីធម្មតា ខ្ញុំក៏ផ្អាកការអោបថើបនោះ។ គាត់ក៏សុំខ្ញុំត្រង់ៗតែម្តងថា គាត់ចង់គេងជាមួយខ្ញុំ ព្រោះគាត់ស្រលាញ់ខ្ញុំខ្លាំងណាស់រហូតមិនអាចទប់អារម្មណ៍បាន។ ខ្ញុំបានប្រកែកមិនព្រម ហើយក៏មានអារម្មណ៍ភ័យបន្តិច ខឹងបន្តិច ព្រោះខ្ញុំក៏ធ្លាប់ទទួលបានការផ្សព្វផ្សាយពីអង្គការអប់រំពីសុខភាព និងព័ត៌មានមួយចំនួនតាមវិទ្យុ ទូរទស្សន៍ ទាក់ទងទៅនឹងផលវិបាកនៃការរួមភេទមុនរៀបការ និងការប្រឈមមុខនឹងបញ្ហាមួយចំនួនដូចជា ជម្ងឺឆ្លង ឬអាចមានកូនជាដើម។ ប៉ុន្តែពេលនោះ គាត់អង្វរខ្ញុំផង

ថើបខ្ញុំផង ធ្វើឱ្យអារម្មណ៍ខ្ញុំច្របូកច្របល់ខ្លាំងណាស់ មិនដឹងជាត្រូវគិតយ៉ាងម៉េច ម្យ៉ាងភ័យផង បារម្ភផងនូវគ្រប់បញ្ហាដែលអាចកើតមានឡើង អារម្មណ៍អាណិតគាត់ផង,,,, ពិតជាពិបាកណាស់។ នៅទីបំផុតខ្ញុំក៏ព្រមតាមសំណូមពររបស់គាត់ដែលការពិតទៅ នោះ ខ្ញុំមិនចង់ធ្វើដូច្នេះទេ។ ខ្ញុំគិតថា នេះជាពេលវេលាដែលខ្ញុំគួរតែផ្តល់សំរាប់មនុស្សជាទីស្រលាញ់ ហើយខ្ញុំក៏មិនចង់ឱ្យ ទំនាក់ទំនងរបស់យើងមានភាពរកាំរកូសឡើយ ហើយរឹតតែមិនចង់បាត់បង់រូបគាត់។ ពេលនោះក៏មិនមានឧបសគ្គអ្វីរារាំងដល់ដំនើរការរួមភេទរបស់ពួកយើងដែរ ព្រោះផ្ទះលំហែនៅកៀនស្វាយនោះមានបន្ទប់គេងក្នុងនោះតែម្តង។ ខ្ញុំនៅរារែកចិត្តដែរ តែដោយសារចិត្តស្រលាញ់ និងអាណិត ម្យ៉ាងទៀតក៏ចង់សាកល្បងចង់ដឹង ទើបលែងខ្វល់ពីអ្វីទាំងអស់។ នៅពេលនោះ ខ្ញុំក៏បានសុំឱ្យគាត់ប្រើស្រោមអនាម័យ ដោយនេះមិនមែនមានន័យថា ខ្ញុំមិនទុកចិត្តគាត់នោះទេ ខ្ញុំគ្រាន់តែខ្លាចមានផ្ទៃពោះ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា កុំបារម្ភ ហើយនេះក៏ជាលើកទីមួយសំរាប់គាត់ផងដែរ។ ខ្ញុំជឿគាត់ ហើយក៏យល់ព្រមតាមគាត់ទៅ។ តាមការពិត គាត់កុហកខ្ញុំ ពីព្រោះក្រោយមកខ្ញុំបានដឹងថា គាត់ធ្លាប់មានសង្សារម្តងរួចហើយ និងធ្លាប់បានគេងជាមួយគ្នាទៀតផង ប៉ុន្តែពួកគេបានបែកគ្នាហើយ ដោយសារសង្សារចាស់របស់គាត់ទៅរៀននៅបរទេស។

ខ្ញុំគិតថា ថ្ងៃនោះជាថ្ងៃពិសេសសំរាប់ខ្ញុំនិងគាត់ ទោះបីជាដំនើរការនៃការរួមភេទមិនសូវរលូតក៏ដោយ ព្រោះនៅពេលនោះ ខ្ញុំមានអារម្មណ៍ឈឺខ្លាំង ហើយមានហូរឈាមទៀត។ ខ្ញុំក៏បានឱ្យគាត់បញ្ឈប់ការរួមភេទបន្តទៀត ព្រោះខ្ញុំទ្រាំនឹងការឈឺចាប់នេះមិនបាន ប៉ុន្តែគាត់ថាមិនអីទេ យូរទៅលែងអីហើយ គាត់ប្រាប់ឱ្យខ្ញុំទ្រាំសិនទៅ ហើយគាត់និយាយទៀតថា ការរួមរ័កនៅលើកដំបូងតែងតែមានការពិបាកបន្តិចហើយ ប៉ុន្តែយូរទៅនឹងទំលាប់បាន។ ថ្វីត្បិតពេលខ្លះ ខ្ញុំមានអារម្មណ៍ថាសុខស្រួល ប៉ុន្តែពេលខ្លះខ្ញុំមានអារម្មណ៍ឈឺខ្លាំងទ្រាំសឹងតែពុំបាន ដូចជាកំពុងអារសាច់ខ្លួនឯងយ៉ាងដូច្នេះដែរ។ ទោះបីជាយ៉ាងណា ខ្ញុំព្យាយាមសម្របតាមមនុស្សដែលខ្ញុំស្រលាញ់។ ក្រោយពីថ្ងៃនោះមក ខ្ញុំត្រូវគេងសំរាកនៅផ្ទះមិនទៅរៀនបីថ្ងៃ ដោយសារតែអស់កំលាំង និងនៅឈឺខ្លាំង។ នៅពេលនោះ ខ្ញុំបារម្ភខ្លាចម៉ាក់ និងបងស្រីដឹងណាស់ ចំណែកឯសង្សារខ្ញុំក៏ព្រួយបារម្ភពីខ្ញុំណាស់ដែរ។ ក្រោយមកពួកយើងតែងតែទៅរួមភេទជាមួយគ្នានៅកន្លែងចាស់នោះ និងមិនដែលប្រើប្រាស់ស្រោមអនាម័យដែរ ហើយក៏មិនបារម្ភពីបញ្ហាអ្វីទាំងអស់ ដោយសារតែពួកយើងទុកចិត្តគ្នាទៅវិញទៅមក។ មិនយូរប៉ុន្មាន ខ្ញុំបានបើកក្រុមហ៊ុនទេសចរណ៍មួយ ដោយមានហ៊ុនជាមួយនឹងបងស្រី និងមិត្តភក្តិរបស់ខ្ញុំ ហើយខ្ញុំក៏បានជួលផ្ទះមួយល្វែងសំរាប់ក្រុមហ៊ុននោះ។ បងស្រី និងមិត្តភក្តិមិនសូវមានពេលមកក្រុមហ៊ុនប៉ុន្មានទេ មានតែខ្ញុំទេដែលតែងតែជាអ្នកមើលការខុសត្រូវជំនួស។ នោះជាឱកាសល្អសំរាប់ខ្ញុំ និងសង្សារដើម្បីសាងអនុស្សាវរីយ៍ជាមួយគ្នាទៀត ព្រោះទំនេរពីការរៀននិងធ្វើការ គាត់មកជួយមើលការងារនៅក្រុមហ៊ុនរបស់ខ្ញុំដែរ។ យើងតែងតែញុំាអាហារថ្ងៃត្រង់ជាមួយគ្នា ហើយបន្ទាប់មកក៏បានរួមភេទជាមួយគ្នាជាញឹកញាប់នៅបន្ទប់ខាងលើក្នុងក្រុមហ៊ុន។ ដូច្នេះយើងក៏លែងទៅកៀនស្វាយទៀតដែរ។ ខ្ញុំទទួលអារម្មណ៍ថាមានសេចក្តីសុខខ្លាំងណាស់នៅពេលគេងជាមួយគ្នាម្តងៗ ទោះបីជាមិនប្រើស្រោមអនាម័យក៏ពួកយើងមិនបារម្ភអ្វីទាំងអស់ ដោយសារតែភាគច្រើន ពេលជិតចេញទឹកកាម គាត់តែងតែដកប្រដាប់ភេទចេញមកក្រៅ

ប៉ុន្តែពេលខ្លះក៏គាត់ទុកនៅយូរដែរទើបដកចេញ ដោយប្រាប់ថាបើឆាប់ដកពេក គាត់អស់មានអារម្មណ៍សុខស្រួលហើយ។ ថ្ងៃខ្លះ ពេលពួកយើងចេញពីរៀន គាត់នាំខ្ញុំទៅអង្គុយលេងនៅកន្លែងងងឹតស្ងាត់ៗនៅវាលមេន ដើម្បីអង្គុយសាសងគ្នា និងនែបនិត្យគ្នា ហើយរាងកាយខ្ញុំត្រូវគាត់លូកស្ទាបសព្វទីកន្លែងរហូតដល់យើងមានអារម្មណ៍ថាស្ទើរទ្រាំលែងបានរៀងៗខ្លួន ទើបគាត់ឌុបខ្ញុំមកក្រុមហ៊ុនដើម្បីជំនួសវេនមិត្តភក្តិ ដើម្បីធ្វើការបន្ត។ តែតាមពិតទៅ ពេលនោះពួកយើងនាំគ្នាបិទទ្វារហើយរួមរ័កជាមួយគ្នាយ៉ាងរីករាយ។ ពេលខ្លះ ខ្ញុំមានអារម្មណ៍ថាខ្លួនឯងបានធ្វើខុស ប៉ុន្តែវាពិតជាធ្វើឱ្យខ្ញុំរីករាយ និងមានសេចក្តីសុខបំផុតសំរាប់ជីវិតបែបនេះ។ ពិតជាមិនខុសមែន ការភ្លើតភ្លើននោះបានធ្វើឱ្យខ្ញុំភ្លាត់ភ្លាំងរហូតដល់មានផ្ទៃពោះ។ ខ្ញុំពិតជាបារម្ភខ្លាំងណាស់ ចំនែកឯគាត់ក៏កាន់តែបារម្ភចំពោះខ្ញុំទៅទៀត មិនដឹងជាធ្វើយ៉ាងម៉េចគាត់ក៏សំរេចថាឱ្យខ្ញុំយកកូនចេញ។ ដោយសារតែឪពុកម្តាយទាំងសងខាងសុទ្ធតែមិនដឹង ម្យ៉ាងទៀតពួកយើងសុទ្ធតែនៅរៀន និងត្រូវការពេលវេលាដើម្បីរកប្រាក់សិននោះ ខ្ញុំក៏សំរេចចិត្តយកកូនចេញដែលវាមានអាយុប្រហែលជាជិតបីខែ។ ដោយសារតែខ្មាស់គេ និងខ្លាចគេដឹង ខ្ញុំក៏មិនបានទៅគ្លីនិកទេ គឺធ្វើតាមមិត្តម្នាក់ឱ្យខ្ញុំទៅទិញថ្នាំចិនដាំផឹកដើម្បីឱ្យកូននោះធ្លាក់មក។ ឯមិត្តម្នាក់ទៀតបានឃាត់មិនឱ្យខ្ញុំផឹក ព្រោះខ្លាចប៉ះពាល់សុខភាព ហើយឱ្យខ្ញុំទៅកន្លែងដែលមានសុវត្ថិភាពវិញ។ ខ្ញុំមានៈមិនព្រមទៅជាដាច់ខាត ហើយសូមអង្វរឱ្យមិត្តខ្ញុំជួយ។ ពីដំបូង គេខឹងមិននិយាយរកខ្ញុំទេ តែក្រោយមកប្រហែលជាគេអាណិតខ្ញុំ ទើបគេព្រមជួយដាំថ្នាំឱ្យខ្ញុំ ចំនែកឯខ្ញុំវិញប្រាប់ម៉ាក់ថា នាំភ្ញៀវដើរកំសាន្តតាមខេត្ត៥ថ្ងៃ ដែលតាមការពិតនោះខ្ញុំមកគេងផឹកថ្នាំទំលាក់កូនចេញនៅឯក្រុមហ៊ុនទៅវិញទេ។ ចំនែកឯសង្សារខ្ញុំវិញ គាត់អាណិតខ្ញុំខ្លាំងណាស់នៅពេលឃើញខ្ញុំផឹកថ្នាំចិននោះទៅមានឈាមធ្លាក់ច្រើនយ៉ាងដូច្នេះ។ បីថ្ងៃក្រោយមក ខ្ញុំក៏ធ្វើតេស្តពិនិត្យទឹកនោមម្តងទៀតឃើញថានៅមិនទាន់រលូត បើទោះបីជាធ្លាក់ឈាមមកច្រើនយ៉ាងណាក៏ដោយ។ មិត្តភក្តិរបស់ខ្ញុំបារម្ភកាន់តែខ្លាំង ហើយក៏អង្វរសូមឱ្យខ្ញុំទៅរកកន្លែងមួយនៅម្តុំផ្សារកណ្តាល ដែលគេស្គាល់តាមរយៈបងស្រីម្នាក់ជួលផ្ទះរបស់គេ។ ទីបំផុត ខ្ញុំក៏សំរេចចិត្តទៅជាមួយនឹងសង្សារខ្ញុំ ព្រោះខ្លាចប៉ះពាល់សុខភាព។ នៅពេលគេពិនិត្យហើយ គេទារខ្ញុំ៥០ដុល្លារសំរាប់ការយកកូនចេញ ដោយសារតែកូនក្នុងផ្ទៃធំហើយ ម្យ៉ាងខ្ញុំធ្លាប់ផឹកថ្នាំទៀត ដូច្នេះគេមិនចង់យកចេញទេ ប៉ុន្តែដោយសារសង្សារខ្ញុំអង្វរខ្លាំង ទើបគេយល់ព្រម។ នៅទីនោះ គេមានឧបករណ៍ទំនើបៗណាស់ ព្រមទាំងមានអនាម័យទៀតផង។ នៅពេលគេបូមយកកូនចេញខ្ញុំមានអារម្មណ៍ថាឈឺតិចៗតែប៉ុណ្ណោះ ព្រោះគេចាក់ថ្នាំស្ពឹក។ ចាប់តាំងពីពេលនោះមក ខ្ញុំនិងសង្សារហាក់ដូចជាមានការញញើត ចំពោះការរួមភេទ។ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់នៅស្រលាញ់ និងយកចិត្តទុកដាក់នឹងខ្ញុំជានិច្ច ជាពិសេសនៅថ្ងៃបុណ្យសង្សារកន្លងទៅថ្មីៗនេះ បានធ្វើឱ្យខ្ញុំយល់ថាគាត់នៅតែស្រលាញ់ខ្ញុំ ហើយកាន់តែស្រលាញ់ ព្រោះគាត់បានរៀបចំបាច់ផ្កាយ៉ាងធំសំរាប់ជូនខ្ញុំបន្ទាប់ពីចេញពីរៀន រួចហើយនាំគ្នាទៅញុំាអី។ បន្ទាប់ពីជិះដើរលេងនៅមាត់ទន្លេ យើងនាំគ្នាទៅបាក់ខែង ដើម្បីជួលផ្ទះសំណាក់មួយសំរាប់២ម៉ោង។ យើងបានគេងជាមួយគ្នាជាថ្មីម្តងទៀត ព្រោះបន្ទាប់ពីយកកូនចេញអស់រយៈពេលជិតបីខែហើយ យើងមិនដែលធ្លាប់បានរួមភេទជាមួយគ្នានោះទេ។ ប៉ុន្តែនៅលើកនោះ យើងបានប្រើស្រោមអនាម័យ ដោយបារម្ភថានឹងមានកូនម្តងទៀត ទោះជាបីជាមានអារម្មណ៍មិនសូវសុខស្រួលក៏ដោយ។ នៅថ្ងៃបុណ្យសង្សារនេះពិតជាមានន័យណាស់សំរាប់ពួកយើងទាំងពីរ ដែលធ្វើឱ្យខ្ញុំកាន់តែយល់ពីគាត់ រួមជាមួយទង្វើ និង

កាយវិការស្រលាញ់យកចិត្តទុកដាក់ចំពោះខ្ញុំត្រូវបានស្តែងចេញមកនៅថ្ងៃនោះឯង ម្យ៉ាងទៀត នៅថ្ងៃពិសេសនោះក៏បានធ្វើឱ្យការរួមភេទរបស់យើងកាន់តែរីករាយ និងប្រៀបបីដូចជាការរួមភេទលើកទីមួយសំរាប់ពួកយើងយ៉ាងដូច្នោះដែរ។

ថ្ងៃនោះជាថ្ងៃដែលយុវវ័យគ្រប់គ្នារីករាយបំផុត មានតែចាស់ៗទេដែលមិនពេញចិត្ត ជាពិសេសប៉ាម៉ាក់ខ្ញុំតែម្តង ព្រោះគាត់តែងនិយាយថា ថ្ងៃនោះជាថ្ងៃដែលធ្វើឱ្យក្មេងៗជ្រួលច្របល់ជោរតាមគ្នា។ នេះក៏ជាហេតុផលគួបផ្សំមួយដែលធ្វើឱ្យខ្ញុំលាក់បាំងរឿងដែលកើតឡើងរវាងខ្ញុំនិងសង្សារខ្ញុំផងដែរ ពីព្រោះខ្លាចគាត់ស្តីបន្ទោស និងបំបែកបំបាក់ឈប់ឱ្យយើងទាក់ទងគ្នាទៀត។ ខ្ញុំពិតជាខ្លាចបាត់បង់រូបគាត់ណាស់ តែខ្ញុំក៏មិនខ្វល់រឿងថ្ងៃមុនយ៉ាងណាដែរ បើគាត់ដឹងពេលណាគឺពេលនោះទៅ!

## ករណីទី៣: ណារ៉ា អាយុ២២ឆ្នាំ ភេទប្រុស ជានិស្សិត, នៅតែគុជ Kiss

ខ្ញុំនិងសង្សារខ្ញុំស្រលាញ់គ្នាខ្លាំងណាស់ យើងតែងតែដើរលេងជាមួយគ្នាសឹងតែរាល់ថ្ងៃ។ ទំនាក់ទំនងរបស់យើងចាប់ផ្តើមតាំងពីពេលខ្ញុំស្គាល់នាងដំបូងនៅពេលមិត្តភក្តិស្រីខ្ញុំណែនាំឱ្យស្គាល់។ នាងពិតជាស្អាត ហើយខ្ញុំបានព្យាយាមតាមស្រលាញ់នាង និងធ្វើអ្វីៗជាច្រើនទៅលើនាង ដូចជាទិញកាដូឱ្យនាង ហើយនៅទីបំផុត នាងបានព្រមទៅដើរលេងជាមួយខ្ញុំ ដោយបានណាត់ជួបគ្នានៅតែគុជមួយដើម្បីញ៉ាំអី រួចបន្តជិះដើរលេងមាត់ទន្លេរហូតដល់ម៉ោង៧ល្ងាច ទើបជូននាងត្រលប់ទៅផ្ទះវិញ។ កាលនោះ ខ្ញុំពុំបានធ្វើអ្វីទៅលើនាងនោះទេ ព្រោះខ្ញុំស្រលាញ់នាងខ្លាំង ហើយខ្លាចនាងខឹង។ ក្រោយៗមកយើងតែងតែដើរលេងជារៀងរាល់ល្ងាច ដែលធ្វើឱ្យយើងកាន់តែយល់ចិត្តគ្នាច្បាស់ ហើយខ្ញុំក៏ដឹងថា នាងស្រលាញ់ខ្ញុំគួរសមដែរ។ ខ្ញុំក៏ព្យាយាមលួងលោមដើម្បីឱ្យនាងយល់ព្រមធ្វើតាមខ្ញុំ ហើយយើងតែងនាំគ្នាទៅលេងនៅបាក់ខែង គៀនស្វាយជារៀង រាល់ថ្ងៃសៅរ៍។ នៅថ្ងៃមួយនោះ ក្រោយពេលញ៉ាំអីឆ្អែតហើយ យើងក៏អង្គុយលេងក្នុងខ្ទមដែលមានអ្វីបិទបាំងជិត ខ្ញុំក៏ចាប់ផ្តើមស្ទាបអង្អែលនាង។ មុនដំបូងនាងអៀនខ្លាំងណាស់ តែយូរបន្តិចក្រោយមក នាងក៏បណ្តោយខ្ញុំធ្វើអ្វីស្រេចតែចិត្តខ្ញុំ ហើយខ្ញុំក៏សុំនាងរួមភេទតែម្តង ប៉ុន្តែនាងមិនឆ្លើយអ្វីទាំងអស់។ ខ្ញុំគិតស្មានថានាងខឹងនឹងខ្ញុំ ហើយក៏បញ្ឈប់ត្រឹមហ្នឹង និងត្រលប់មកផ្ទះវិញ។ រៀងរាល់ល្ងាច ខ្ញុំនិងសង្សារតែងតែដើរលេងជាមួយគ្នាជានិច្ច ដោយជួនកាលនាំគ្នាទៅញ៉ាំអី ឬទៅមើលកុន និងពេលខ្លះទៅម្តុំសួនច្បារមាត់ទន្លេ ដែលភាគច្រើនគេនាំគូស្នេហ៍ទៅអង្គុយលេង ហើយខ្ញុំតែងតែថើបនិងប៉ះពាល់នាងគ្រប់ពេល ជាពិសេសនៅក្នុងរោងកុន។ នៅទីបំផុត ខ្ញុំក៏បានខ្លួននាង ដោយខ្ញុំចាំមិនភ្លេចទេនៅល្ងាចថ្ងៃសៅរ៍មួយនៅពេលគ្រួសារនាងជាប់រវល់ទៅចូលរួមពិធីរៀបការក្មួយនៅខេត្ត តែនាងនិងបងស្រីរបស់នាងមិនបានទៅទេ ដូច្នេះនៅល្ងាចនោះ ខ្ញុំបាននាំនាងទៅត្រើយម្ខាងដើម្បីញ៉ាំបាញ់ឆៃវ។ ខ្ញុំក៏បានធ្វើអ្វីដូចដែលខ្ញុំធ្វើរាល់ដង។ ខ្ញុំយកដៃទៅស្ទាបដោះនាង ហើយថើបនាងធ្វើឱ្យនាងបញ្ចេញកាយវិការតបមកខ្ញុំវិញ ហើយពេលនោះយើងក៏ឯកភាពគ្នាចូលផ្ទះសំណាក់នៅក្បែរផ្សារថ្មីក្នុងតំលៃ៥ដុល្លារ។ ប៉ុន្តែមុននឹងចូលផ្ទះសំណាក់ នាងឱ្យខ្ញុំទិញម៉ាស់ឱ្យនាងមួយពាក់ដើម្បីកុំឱ្យគេស្គាល់នាង និងដឹងដល់ឪពុកម្តាយរបស់នាង។ នៅយប់នោះ នាងសូមឱ្យប្រើស្រោមអនាម័យមុនពេលរួមភេទជាមួយនាង ពីព្រោះនាងខ្លាចមានផ្ទៃពោះ ហើយខ្ញុំក៏ចង់ប្រើផងដែរ ពីព្រោះតែខ្ញុំមិនដឹងថា ខ្លួនខ្ញុំមានជម្ងឺដែរឬអត់ ដោយសារតែមុននឹងស្គាល់នាង ខ្ញុំធ្លាប់រួមភេទជាមួយនឹងនារីជាច្រើនមកហើយ។ លើកដំបូង ខ្ញុំធ្លាប់បានរួមភេទជាមួយនឹងស្ត្រីរកស៊ីផ្លូវភេទ កាលខ្ញុំមានអាយុប្រហែល១៩-២០ឆ្នាំ ប៉ុន្តែខ្ញុំតែងតែប្រើស្រោមអនាម័យជាប់ជានិច្ច ដោយខ្ញុំបានដឹងពីការអប់រំតាមរយៈទូរទស្សន៍ ទស្សនាវដ្តី និងពីចាស់ៗ។ ប៉ុន្តែកាលពី១ឆ្នាំមុន ខ្ញុំបានចូលរួមពិធីរៀបការបងស្រីរបស់មិត្តភក្តិខ្ញុំ ហើយក៏បន្តផឹកខាងក្រៅជាមួយមិត្តភក្តិ។ ពេលនោះ ពួកយើងបានជួលនារីរកស៊ីផ្លូវភេទម្នាក់នៅម្តុំសួនច្បារវិមានឯករាជ្យនៅក្នុងតំលៃ១៥ដុល្លារ ដើម្បីមករួមភេទទាំងអស់គ្នាដោយមានគ្នា៤នាក់។ នៅពេលនោះ ខ្ញុំស្រវឹងខ្លាំងណាស់ ដូច្នេះមិនបានដឹងថាបានប្រើស្រោមឬក៏អត់នោះទេ ហើយខ្ញុំក៏បានសួរទៅមិត្តភក្តិខ្ញុំដែរថាបានប្រើស្រោមអនាម័យដែរឬទេ? អ្នកខ្លះថាអត់។

មកដល់ពេលនេះ ខ្ញុំនិងនាងខ្ញុំស្រលាញ់គ្នាអស់រយៈពេល២ឆ្នាំមកហើយ ហើយឥឡូវក៏មិនសូវដើរលេងកន្លែងពីមុនៗតទៅទៀតដែរ តែរួមភេទញឹកញាប់ដែរ។ នាងក៏ពេញចិត្តនឹងខ្ញុំណាស់ដែរ ពីព្រោះឱ្យតែខ្ញុំបបួលនាងម្តងណា នាងតែងតែយល់ព្រមភ្លាម ហើយពួកយើងតែងតែប្រើស្រោមអនាម័យជានិច្ច ព្រោះយើងយល់ថា ភាពស្រណុកសុខស្រួលមិនសំខាន់ទៅលើស្រោមអនាម័យនោះទេ អ្វីដែលសំខាន់នោះគឺឱ្យតែយើងចេះយល់ចិត្តគ្នា ហើយពិសេសអាចការពារពីការមានផ្ទៃពោះបានទៀតផង។ វាពិតជាពិបាកណាស់បើវាកើតឡើងមែននោះ ពីព្រោះយើងសុទ្ធតែនៅរៀនដូចគ្នា។

នៅថ្ងៃបុណ្យសង្សារ យើងបាននាំគ្នាដើរលេង ហើយយើងមានគំរោងទុកមុនទៀតផង ដោយខ្ញុំនិងនាងបាននាំគ្នាទៅទិញអាវពណ៌ក្រហមម្នាក់មួយសំរាប់ពាក់នៅក្នុងថ្ងៃនោះ ហើយយើងក៏បានដើរលេងជាមួយគ្នាពេញមួយថ្ងៃតែម្តង ដោយនៅពេលព្រឹកខ្ញុំបាននាំនាងទៅញ៉ាំអី និងចូលមើលកុននៅផ្សារទំនើបសូរិយា បន្ទាប់មកក៏ជូននាងត្រលប់ទៅផ្ទះវិញ រួចទើបទៅទទួលនាងម្តងទៀតនៅម៉ោង១រសៀលដើម្បីដើរលេងបន្ត។ នៅមុនពេលទៅទទួលនាង ខ្ញុំបានទិញផ្កាកុលាបមួយបាច់តំលៃ១២ដុល្លារឱ្យនាង។ នាងពិតជាសប្បាយចិត្តខ្លាំងណាស់នៅពេលនាងទទួលយកផ្កាពីខ្ញុំ។ ខ្ញុំមើលទៅគូស្នេហ៍ដទៃៗទៀតក៏ដូចជាខ្ញុំដែរ។ ខ្ញុំនិងនាងបាននាំគ្នាទៅតែគុជមួយដើម្បីញ៉ាំអីរហូតដល់ម៉ោង៦ល្ងាច ទើបចេញទៅជិះបន្តដល់ម៉ោង៩យប់ ទើបនាំនាងចូលផ្ទះសំណាក់។ ស្ទើរតែមិនគួរឱ្យជឿដែលផ្ទះសំណាក់ទាំងអស់សុទ្ធតែពេញ។ នៅផ្ទះសំណាក់ទីបីទើបមានបន្ទប់ជួល។ នោះជាលើកទីមួយហើយដែលនាងប្រាប់ថា មិនបាច់ប្រើស្រោមអនាម័យទេ ដូច្នេះខ្ញុំក៏យល់ព្រមតាមនាង ដោយនៅយប់នោះ យើងរួមភេទបានពីរដង ដោយសារតែនៅលើកទីមួយ ខ្ញុំស្រេវស្រើបខ្លាំងពេកក៏បញ្ចេញទឹកកាមមក មិនបាន២នាទីផង។ ប៉ុន្តែនៅលើកទី២ ពិតជាពិសេសខ្លាំងណាស់។

ក្រៅពីសង្សារខ្ញុំបច្ចុប្បន្ននេះ ខ្ញុំក៏ធ្លាប់មានសង្សារជាច្រើនពីមុនមកដែរ ប៉ុន្តែខ្ញុំមិនដែលរួមភេទជាមួយពួកគេទេ ដោយសារកាលណោះខ្ញុំនៅក្មេងពេក ហើយខ្លាចទៀតផង។ សំរាប់សង្សាររបស់ខ្ញុំបច្ចុប្បន្ននេះវិញ ខ្ញុំមិនដឹងថានាងធ្លាប់មានសង្សារប៉ុន្មាននាក់មកហើយនោះទេ គ្រាន់តែនាងធ្លាប់ប្រាប់ថានាងធ្លាប់មានសង្សារ។ ខ្ញុំចង់បាននារីបរិសុទ្ធ ប៉ុន្តែខ្ញុំសង្កេតឃើញថា នៅពេលយើងរួមភេទជាមួយគ្នានៅលើកដំបូងនាងមានចេញឈាម ដូច្នេះនាងប្រហែលជានៅបរិសុទ្ធហើយ។ ភាពបរិសុទ្ធ របស់នាងមិនសំខាន់សំរាប់ខ្ញុំឡើយ អ្វីដែលសំខាន់នោះគឺចង់ឱ្យនាងស្រលាញ់ខ្ញុំដោយចិត្តស្មោះ។

ចំពោះទស្សនៈរបស់ខ្ញុំ បានជាខ្ញុំនិងយុវវ័យដទៃទៀតចូលរួមប្រារព្ធថ្ងៃបុណ្យសង្សារនេះក៏ព្រោះតែមានការចំលងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងពីសង្គមមួយទៅសង្គមមួយទៀត ជាពិសេសតាមរយៈទូរទស្សន៍ ភាពយន្ត កាសែត។ ខ្ញុំគិតថាវាក៏សប្បាយម្យ៉ាងដែរ ដោយយើងអាចបញ្ជាក់ពីក្តីស្រលាញ់របស់យើងទៅមនុស្សដែលយើងស្រលាញ់។ ឪពុកម្តាយពួកយើងមិនបានដឹងពីទំនាក់ទំនងរបស់យើងតាំងពីរនោះទេ។ ខ្ញុំគិតថា ខ្ញុំប្រហែលជាស្រលាញ់នាងពិតប្រាកដមែនហើយ ពីព្រោះតាំងពីស្គាល់នាងមក ខ្ញុំមិនដែលរកក្រៅនោះទេ ហើយខ្ញុំក៏មានគំរោងចង់រៀបការជាមួយនាងផងដែរ ប៉ុន្តែបានត្រឹមតែគិតសិនប៉ុណ្ណោះ ព្រោះយើងទាំងពីររៀនមិនទាន់ចប់។

**ករណីទី៤: មេត្រី អាយុ២២ឆ្នាំ ភេទប្រុស ជានិស្សិត និងបុគ្គលិកក្រុមហ៊ុន, ពេលភាពយន្តស៊ីឈោម៉ាសូរិយា**

សង្សារខ្ញុំមានអាយុ២១ឆ្នាំ ហើយយើងធ្លាប់រៀនជាមួយគ្នា។ យើងស្រលាញ់គ្នាតាំងពីឆ្នាំ២០០៧ ដោយផ្ដើមចេញពីការណែនាំគ្នាទៅវិញទៅមក ហើយខ្ញុំស្រលាញ់នាងតាំងពីបានជួបនាងលើកដំបូងម្ល៉េះ។ ខ្ញុំព្យាយាមនិយាយជាមួយនាងរួមជាមួយនឹងការចំអែចំអន់លេងពីមិត្តភក្តិ ធ្វើឱ្យយើងចាប់ផ្ដើមយល់ចិត្តគ្នា ប៉ុន្តែខ្ញុំតែងតែបញ្ចេញកាយវិការផ្សេងៗដើម្បីឱ្យនាងបានដឹង ដូចជាសួរលេខទូរស័ព្ទ ថ្ងៃខួបកំណើតនាង ហើយទិញកាដូឱ្យនាងនៅថ្ងៃពិសេសអ្វីមួយ។ ខ្ញុំមិនដែលឱ្យប្រាក់នាងនោះទេ ព្រោះខ្ញុំខ្លាចនាងគិតថា ខ្ញុំមើលងាយនាង។ នៅពេលនាងទទួលយកកាដូពីខ្ញុំ ធ្វើឱ្យខ្ញុំហ៊ានសារភាពប្រាប់នាងថា ខ្ញុំស្រលាញ់នាង។ នាងយល់ព្រមធ្វើជាសង្សារខ្ញុំ ប៉ុន្តែហាមប្រាប់គេ ព្រោះខ្លាចគេសើចចំអក។

មុនដំបូង យើងតែងតែដើរលេងជាក្រុមជាមួយមិត្តភក្តិ ដូចជាទៅព្រែកលាបជាដើម ប៉ុន្តែក្រោយៗមក ខ្ញុំមានអារម្មណ៍ថាធុញទ្រាន់ ទើបបបួលនាងដើរលេងតែពីរនាក់ តែពួកយើងមិនចូលចិត្តទៅណាឆ្ងាយទេ ពីព្រោះក្ដៅ និងហុយផ្សែង ហុយដី។ ដូច្នេះពួកយើងតែងតែជិះម៉ូតូដើរលេង ដូចជាទៅផ្សារ និងទៅតែគុជនៅមុំស៊ីសុវត្ថិ ដែលយុវវ័យផ្សេងទៀតចូលចិត្តទៅ ព្រោះតែនៅទីនោះមិនសូវថ្លៃ។ រាល់ពេលល្ងាច ខ្ញុំតែងតែនាំនាងជិះដើរលេងមាត់ទន្លេ និងអង្គុយលេងនៅតូបលក់ពោត។ ពួកយើងតែងតែឃើញគូសង្សារផ្សេងៗធ្វើអ្វីៗជាមួយគ្នា ហើយចំពោះពួកយើងវិញក៏មិនខុសគ្នាដែរ នៅពេលណាមានឱកាស និងស្ងាត់ល្អ ខ្ញុំតែងតែថើបនាង និងបបោសអង្អែលនាង ប៉ុន្តែពួកយើងមិនដែលគេងជាមួយគ្នាទេ ពីព្រោះនៅរាល់ពេលខ្ញុំសុំនាងរួមភេទជាមួយ នាងតែងតែបដិសេធជានិច្ច ដោយលើកហេតុផលថានាងជានារីខ្មែរ ហើយម្យ៉ាងទៀត ឪពុកនាងកាចណាស់។ ទោះបីជាខ្ញុំព្យាយាមយ៉ាងណាក៏គ្មានបានការដែរ មានម្ដងនោះយើងសឹងតែនឹងបែកគ្នាទៅហើយ ដោយសារតែបញ្ហានេះ។ ខ្ញុំគិតយូរៗទៅក៏ល្អម្យ៉ាងដែរ ដែលនារីដែលខ្ញុំស្រលាញ់ជានារីល្អយ៉ាងដូចនេះ ហើយពួកយើងរឹតតែស្រលាញ់គ្នាជាងមុនទៅទៀត។ ចំពោះបញ្ហាសិច នៅពេលដែលខ្ញុំមានចំណង់ត្រូវការ ខ្ញុំតែងតែទៅរកស្ត្រីរកស៊ីផ្លូវភេទ ជាមួយមិត្តភក្តិខ្ញុំជាញឹកញាប់ ហើយតែងតែប្រើស្រោមអនាម័យជានិច្ច ពីព្រោះពួកយើងខ្លាចឆ្លងរោគផ្សេងៗ ដោយសារពួកយើងបានដឹងពីមិត្តភក្តិ ទូរទស្សន៍ ទស្សនាវដ្ដី ជាដើម។

ខ្ញុំចាប់ផ្ដើមមានទំនាក់ទំនងផ្លូវភេទតាំងពីរៀននៅវិទ្យាល័យ គឺនៅពេលខ្ញុំមានសង្សារចាស់ម្នាក់តែងតែឈ្លោះគ្នាជានិច្ច ដោយសារតែពួកយើងនៅក្មេងពេក មិនដឹងខុសត្រូវ ដូច្នេះក៏បែកគ្នាទៅ ដោយនាងទៅមានសង្សារថ្មី ធ្វើឱ្យខ្ញុំឈឺចិត្តខ្លាំង ហើយនាំមិត្តភក្តិទៅផឹកស៊ីដល់ស្រវឹង រួចទៅរកស្ត្រីរកស៊ីផ្លូវភេទតែម្ដង។ ខ្ញុំមិនធ្លាប់យកនារីរកស៊ីផ្លូវភេទទៅរួមភេទបូកនោះទេ ព្រោះខ្ញុំខ្ពើម ខ្លាចឆ្លងរោគ និងអាណិតពួកនាង។ ប៉ុន្តែចំពោះមិត្តភក្តិខ្ញុំវិញ ពួកវាតែងតែធ្វើយ៉ាងដូច្នេះជាញឹកញាប់ ដោយពួកវាប្រាប់ថាចំណាយលុយតិច ហើយបានច្រើនដង។ ខ្ញុំចាំបានថា មានម្ដងកាលពីឆ្នាំមុនមានការប្រគុំតន្ត្រី

Best of the Best នៅស្តាតអូឡាំពិក ក្រោយពីពួកវាស្រវឹងក៏នាំស្រីទៅបូក ប៉ុន្តែខ្ញុំមិនដឹងថា ពួកវាប្រើស្រោមអនាម័យឬក៏អត់ នោះទេ ដោយសារកាលណោះ ខ្ញុំនាំសង្សារខ្ញុំទៅដើរលេងកន្លែងផ្សេង ចំណែកពួកវាសុទ្ធតែអត់មានសង្សារ ។

ខ្ញុំធ្លាប់មានសង្សារ៤នាក់មកហើយ រួមទាំងសង្សារថ្មីនេះទៀតគឺ៥នាក់ ។ ក្នុងចំនោមសង្សារទាំង៥នាក់នេះ មានម្នាក់ដែលខ្ញុំធ្លាប់រួមភេទជាមួយនៅក្នុងថ្ងៃបុណ្យសិទ្ធនារីឆ្នាំ២០០២ នៅពេលខ្ញុំរៀននៅវិទ្យាល័យនៅឡើយ ។ មិត្តភក្តិទាំងអស់នាំគ្នាទៅកំពង់សោម ប៉ុន្តែខ្ញុំនិងសង្សារចាស់ខ្ញុំនៅភ្នំពេញ ហើយនាំគ្នាទៅរាំលេងនៅ CASA ហើយផឹកស្រវឹង និងរាំរហូតដល់ម៉ោង៥កន្លះល្ងាច ហើយដើរលេងជាច្រើនកន្លែងទៀត ទើបនាំគ្នាទៅផ្ទះសំនាក់ ។ នាងមានអាយុ១៦ឆ្នាំ រៀនថ្នាក់ទី៩ ហើយនាងជាយុវនារីបរិសុទ្ធ១០០ភាគរយ ពីព្រោះនៅពេលខ្ញុំពុំអាចដាក់ប្រដាប់ភេទឱ្យបានជ្រៅនោះទេនៅយប់នោះ ពីព្រោះនាងឈឺខ្លាំងណាស់ និងមានឈាមទៀត ។ ក្រោយមក ឪពុកម្តាយនាងដឹងក៏ឈប់ឱ្យនាងរៀននៅទីនោះ ហើយពួកយើងក៏លែងបានជួបគ្នាទៀតដែរ ។ ខ្ញុំមិនបានប្រើស្រោមអនាម័យនោះទេនៅពេលនោះ ហើយក៏មិនបានគិតដល់ផងដែរ ។

ចំពោះសង្សាររបស់ខ្ញុំបច្ចុប្បន្នវិញ នាងប្រាប់ថានេះជាលើកទីមួយហើយដែលនាងមានសង្សារ ព្រោះពីមុនមកឪពុកម្តាយរបស់នាងតឹងរ៉ឹងណាស់ចំពោះនាង ប៉ុន្តែឥឡូវនាងធំដឹងក្តីច្រើនហើយ ដូច្នេះពួកគាត់មិនសូវជាតឹងរ៉ឹងដូចមុន ។ នៅថ្ងៃបុណ្យសង្សារ ខ្ញុំនិងនាងបាននាំគ្នាទៅមើលកុននៅផ្សារទំនើបសូរិយា និងទៅញ៉ាំ Pizza ហើយខ្ញុំបានទិញកាបូបមួយឱ្យនាង ចំណែកនាងបានទិញអាវឱ្យខ្ញុំមួយវិញ ចំពោះផ្កា ខ្ញុំបានជូននាងតាំងពីព្រឹក ។ នៅថ្ងៃនោះ ខ្ញុំពិតជាចង់គេងជាមួយនាងខ្លាំងណាស់ មិនថាតែពេលនោះទេ រាល់ពេលដែលខ្ញុំនៅជាមួយនាង ខ្ញុំតែងតែមានចំណង់ជានិច្ច ប៉ុន្តែនាងបង្ហាញកាយវិការមកវិញថា ដាច់ខាតគឺទេ ទោះបីជាខ្ញុំព្យាយាមប៉ះនាងពីខាងក្រៅយ៉ាងណាក៏ដោយ ទោះបីជានៅក្នុងបន្ទប់ខារ៉ាអូខេដែលជិតងងឹត ងាយស្រួល មិនភ័យខ្លាចគេឃើញគេលឺក៏ដោយ ។

ខ្ញុំបានចូលរួមនៅក្នុងថ្ងៃបុណ្យសង្សារ ដោយសារខ្ញុំគិតថាជាថ្ងៃសប្បាយរីករាយមួយ និងពោរពេញដោយភាពរ៉ូមែនទិកដូចជាពួកបរទេស ។ ជាទូទៅ ឪពុកម្តាយ និងមិត្តភក្តិខ្លះមិនបានយល់ពីអត្ថន័យនៃថ្ងៃនោះឱ្យបានពិតប្រាកដនោះទេ ។ ហើយយើងបានដឹងពីភាពយន្តបរទេស ដូចជាភាពយន្តកូរ៉េ ចិន និងតាមរយៈទស្សនាវដ្តី ។ យុវវ័យខ្លះទៀតនិយាយថាមកពីមានការជ្រៀតចូលពីវប្បធម៌បរទេស និងបច្ចេកទេសទំនើបៗ ជាពិសេសអ៊ីនធឺរណេត និងភាពសប្បាយនៅក្នុងសង្គមតៗគ្នា ។ ឪពុកម្តាយបានដឹងនូវរាល់សកម្មភាពទាំងអស់របស់ខ្ញុំ ហើយគាត់តែងតែប្រាប់ថា ឱ្យធ្វើអ្វីដែលសង្គមមិនស្អប់ខ្ពើម ប៉ុន្តែចំពោះសង្សារខ្ញុំវិញ ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ព្រោះនាងមិនដែលប្រាប់ ។

**ករណីទី៥: រ៉ាស៊ី អាយុ១៩ឆ្នាំ ភេទស្រី ជានិស្សិតវិទ្យាល័យ, នៅសួនច្បារមាត់ទន្លេ**

នៅពេលខ្ញុំរៀននៅថ្នាក់ទី៦នៅសាលាបឋមសិក្សាឆ្នាំ២០០៣ ខ្ញុំបានជួបនឹងសង្សាររបស់ខ្ញុំតាមរយៈមិត្តភក្តិខ្ញុំម្នាក់ដែលរៀនជាមួយគ្នា។ គាត់ជាមនុស្សល្អ ចរិតល្អ សុភាពរាបសា មាននិស្ស័យល្អ មិនប្រកាន់ខ្លួនថាជាកូនអ្នកមាន ជាពិសេសគាត់ក៏ដឹងថា គ្រួសារខ្ញុំជាអ្នកក្រ ហើយគាត់នៅតែស្រលាញ់ខ្ញុំទៀត។ អ្វីដែលធ្វើឱ្យខ្ញុំស្រលាញ់គាត់កាន់តែខ្លាំងនោះគឺនៅពេលខ្ញុំ និងគ្រួសារខ្ញុំត្រូវការប្រាក់ ខ្ញុំតែងតែជួយទំនុកបំរុងខ្ញុំជានិច្ច។

ជាធម្មតា ខ្ញុំនិងសង្សារចូលចិត្តទៅលេងបាក់ខែង និងតែគុជជារៀងរាល់ពេលទំនេរពីការរៀនសូត្រ។ នៅថ្ងៃបុណ្យសង្សារជាថ្ងៃដ៏ពិសេសមួយ និងមានអត្ថន័យខ្លាំងណាស់ សំរាប់ពួកយើងទាំងពីរនាក់។ ខ្ញុំចង់ដឹងថា តើគាត់នៅតែស្រលាញ់ខ្ញុំ និងឱ្យកាដូខ្ញុំដូចឆ្នាំមុនទៀតដែរឬទេ? ជាការពិត គាត់ពិតជានៅតែធ្វើដូចឆ្នាំមុន។ ម្យ៉ាងទៀត យុវវ័យភាគច្រើននៅ ភ្នំពេញតែងតែចេញដើរលេងកំសាន្តជាមួយនឹងមនុស្សដែលគេស្រលាញ់ សូម្បីតែពួកយើងទាំង២ក៏ដូចគ្នាផងដែរ ហើយយើងក៏បានរួមភេទជាមួយគ្នានៅពេលនោះ។ ខ្ញុំគិតថាវាជារឿងធម្មតា ពីព្រោះមិនដែលរួមភេទជាមួយគ្នាជិតមួយឆ្នាំមកហើយ គឺចាប់តាំងពីថ្ងៃទិវាសិទ្ធិនារីឆ្នាំ២០០៧មកម្ល៉េះ ដោយសារតែយើងធ្វើអារម្មណ៍មិនបានល្អ ប៉ុន្តែយើងតែងតែប្រើស្រោមអនាម័យជានិច្ចនៅពេលយើងរួមភេទ ពីព្រោះយើងបារម្ភខ្លាចមានផ្ទៃពោះ។

តាមយោបល់ខ្ញុំ នៅថ្ងៃនោះយុវវ័យភាគច្រើនធ្វើតាមគ្នាទៅវិញទៅមក និងតាមការហូរចូលពីវប្បធម៌បរទេស មានដូចជា ភាពយន្ត ទស្សនាវដ្តី កាសែត សំលៀកបំពាក់ជាដើម ដែលទាំងអស់នេះហើយធ្វើឱ្យយុវវ័យពាក់ព័ន្ធដល់ការរួមភេទដោយមិនបានគិតពីអ្វីទាំងអស់ ព្រមទាំងធ្វើឱ្យមានការផ្លាស់ប្តូរដល់ការប្រព្រឹត្តរបស់គេទៀតផង។ សំរាប់ឪពុកម្តាយខ្ញុំ គាត់មិនបានដឹងថា ខ្ញុំធ្លាប់រួមភេទនោះទេ គ្រាន់តែដឹងថាខ្ញុំមានសង្សារប៉ុណ្ណោះ ប្រសិនបើគាត់ដឹងវិញ ខ្ញុំមិនហ៊ានប្រឈមមុខជាមួយគាត់ទេ។

## ករណីទី៦: ប្រុស អាយុ២៤ឆ្នាំ ភេទប្រុស ជាបុគ្គលិកក្រុមហ៊ុនឯកជន, នៅផ្សារធំថ្មីបសូរិយា

ខ្ញុំបានជួបមិត្តស្រីខ្ញុំដោយចៃដន្យនៅសាលាឬស្សីកែវកាលពីឆ្នាំមុន។ នាងអាយុ២១ឆ្នាំ មានសម្បុរស សក់ខ្មៅវែងរលោង និងជាពិសេសមានរាងកាយស្រឡូនសិចស៊ី។ ចំណុចទាំងនេះហើយដែលធ្វើឱ្យខ្ញុំចាប់ចិត្តស្រលាញ់នាង ហើយសេចក្តីស្នេហារបស់ពួកយើងទាំងពីរគឺកើតឡើងដោយការឃើញភ្លាមស្រលាញ់ភ្លែត ហើយនេះជាស្នេហាដំបូងរបស់ខ្ញុំ។ គ្រប់ពេលដែលនាងទៅសាលារៀន ខ្ញុំតែងតែដើរតាមពីក្រោយនាងយ៉ាងជិតបង្កើយ ហើយព្យាយាមបង្ហាញថា ខ្ញុំលង់ស្នេហ៍លើរូបនាង។ ក្រោយមក ខ្ញុំបានសុំលេខទូរស័ព្ទនាង ហើយតែងតែទាក់ទងនិយាយទូរស័ព្ទជាមួយនាងជានិច្ច។ ប៉ុន្មានខែក្រោយមក យើងទាំងពីរចាប់ផ្តើមណាត់គ្នាចេញទៅក្រៅជាមួយគ្នា ដោយភាគច្រើនតែងតែនាំគ្នាទៅមាត់ទន្លេ និងនៅសួនច្បារហ៊ុនសែន ដែលជាទីកន្លែងគូស្នេហ៍ភាគច្រើននាំគ្នាទៅ។ ជារឿយៗពួកយើងចេញដើរលេងតែនៅថ្ងៃចុងសប្តាហ៍ ដោយសារយើងត្រូវធ្វើការពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ។

នៅថ្ងៃបុណ្យសង្សារនាពេលថ្មីៗនេះ ពួកយើងទាំងពីរក៏មិនខុសអ្វីពីគូស្នេហ៍ដទៃទៀតដែរ។ ទោះបីជាយើងទាំងពីរជាប់រវល់ការងារក៏ដោយក៏យើងឆ្លៀតពេលល្ងាចបន្ទាប់ពីចេញពីធ្វើការ ដើម្បីនាំនាងចេញទៅក្រៅ ដើម្បីបញ្ជាក់ពីក្តីស្រលាញ់ខ្ញុំចំពោះនាងផងដែរជាមួយនឹងផ្កាកុលាបមួយទង។ នៅថ្ងៃនោះខ្ញុំ បាននាំនាងទៅផ្សារសូរិយាដើម្បីញ៉ាំអី រួចហើយទៅអង្គុយលេងនៅមាត់ទន្លេ ដើម្បីសាសងគ្នារហូតដល់ម៉ោង៨ ទើបត្រលប់ទៅផ្ទះវិញ។

សំរាប់ឪពុកម្តាយរបស់យើងវិញ គាត់មិនបានចាប់អារម្មណ៍ទៅលើរឿងបែបនេះឡើយ ពីព្រោះគាត់រវល់ជាមួយការងាររកស៊ីរបស់គាត់។ បើនិយាយតាមការពិតទៅ ខ្ញុំមិនដែលរួមភេទជាមួយនឹងមិត្តស្រីខ្ញុំឡើយ ពីព្រោះខ្ញុំមិនហ៊ានដោយបារម្ភខ្លាចក្រែងថា នាងនឹងឈប់ស្រលាញ់ខ្ញុំ។

ប៉ុន្តែខ្ញុំធ្លាប់ស្វែងរកសេវាផ្លូវភេទដើម្បីបំពេញតំរូវការរបស់ខ្ញុំ ដោយគ្រាន់តែចំនាយ៦ដុល្លារសំរាប់ផ្ទះសំនាក់ និង១០ដុល្លារសំរាប់ស្ត្រីរកស៊ីផ្លូវភេទ។ ខ្ញុំក៏ធ្លាប់ចូលរួមការរួមរ័កបូកផងដែរ ពីព្រោះកាលណោះខ្ញុំនៅជាសិស្សវិទ្យាល័យ ហើយពុំមានប្រាក់គ្រប់គ្រាន់ ប៉ុន្តែហេតុតែចង់ដឹងចង់ឃើញ ជាពិសេសដោយមានសម្ពាធពីមិត្តភក្តិ។ ទោះជាយ៉ាងណាក៏ពេលនោះ ខ្ញុំបានប្រើស្រោមអនាម័យដើម្បីការពារមេរោគផ្សេងៗ។ ខ្ញុំធ្លាប់ទទួលបានព័ត៌មានពីសុខភាពផ្លូវភេទតាមរយៈអង្គការ រ៉ាក់ និងតាមរយៈខិត្តប័ណ្ណផ្សេងៗពីគម្រោង Play Safe និង TASK។

## ករណីទី៧: ទុធ អាយុ២០ឆ្នាំ ភេទប្រុស ជានិស្សិត, នៅមុខវិទ្យាស្ថានមួយ

ទំនាក់ទំនងខ្ញុំនិងមិត្តស្រីរបស់ខ្ញុំគឺមានភាពស្និទ្ធស្នាល និងការយល់ចិត្តគ្នាទៅវិញទៅមក។ ខ្ញុំចាប់ផ្តើមស្រលាញ់នាងតាំងតែពីឆ្នាំ១៩៩៦។ ឥឡូវនេះនាងមានអាយុ១៦ឆ្នាំហើយ និងរស់នៅទីក្រុងភ្នំពេញ។ ខ្ញុំដឹងថា ខ្ញុំស្រលាញ់នាងព្រោះខ្ញុំតែងតែមានការបារម្ភពីនាង ប្រច័ណ្ឌនៅពេលនាងនិយាយជាមួយនឹងបុរសដទៃ ហើយនាងក៏ស្រលាញ់ខ្ញុំវិញដែរ។ ខ្ញុំតែងតែទិញកាដូជូននាង មានដូចជា សំលៀកបំពាក់ ផ្កា តុក្កតាខ្លាឃ្មុំ និងទូរស័ព្ទដៃជាដើម នៅពេលមានពិធីបុណ្យម្តងៗ ដូចជាបុណ្យសិទ្ធនារី គ្រីស្តម៉ាស់ ខួបកំណើតនាង និងជាពិសេសថ្ងៃបុណ្យសង្សារតែម្តង។

នៅពេលទំនេរ ពួកយើងចូលចិត្តទៅបាក់ខែងញុាំពោត ពីព្រោះវាជាកន្លែងពេញនិយមសំរាប់គូស្នេហ៍គ្រប់រូប។ បន្ទាប់មក យើងនាំគ្នាទៅច្រៀងខារ៉ាអូខេនៅម្តុំផ្សារកណ្តាល រួចទើបបន្តទៅ U2 ហើយក៏សំរេចចិត្តទៅផ្ទះសំណាក់ ដើម្បីរួមភេទជាមួយនាង។ ខ្ញុំតែងតែប្រើស្រោមអនាម័យជានិច្ច ដើម្បីការពារនាងពីការមានផ្ទៃពោះ និងការឆ្លងជម្ងឺផ្សេងៗ។ ក្រៅពីនាង ខ្ញុំក៏ធ្លាប់រួមភេទជាមួយនារីនៅតាមផ្ទះបនផងដែរ ដោយសារកាលណោះខ្ញុំនៅក្មេង និងមានចំណង់ផ្លូវភេទខ្លាំង។ ខ្ញុំចាប់ផ្តើមមានទំនាក់ទំនងផ្លូវភេទតាំងពីខ្ញុំមានអាយុ១៤ឆ្នាំមកម្ល៉េះ។

ជាពិសេសនៅថ្ងៃបុណ្យសង្សារ គូស្នេហ៍គ្រប់រូបមានចិត្តសប្បាយរីករាយមែនទែន ពីព្រោះវាជាថ្ងៃពិសេសមួយដែលគូស្នេហ៍គ្រប់រូបបង្ហាញក្តីស្រលាញ់ចំពោះគ្នាទៅវិញទៅមក។ នៅថ្ងៃនោះ ខ្ញុំបានប្រាប់មិត្តស្រីខ្ញុំថា ខ្ញុំស្រលាញ់នាងគ្មានថ្ងៃប្រែប្រួលឡើយ ប៉ុន្តែនៅថ្ងៃនោះផងដែរ ខ្ញុំជាប់រវល់ធ្វើការងាររហូតដល់ម៉ោង៦ល្ងាច ទើបអាចនាំនាងទៅផ្សារទំនើបសូរិយាទិញសំលៀកបំពាក់ និងផ្កាជូននាង ដើម្បីបញ្ជាក់អំពីក្តីស្រលាញ់របស់ខ្ញុំ។ បន្ទាប់មកទើបយើងនាំគ្នាទៅជាន់ខាងលើដើម្បីញុាំអី ហើយដើរលេងនៅតាមមាត់ទន្លេ ទើបត្រលប់ទៅផ្ទះនៅម៉ោង៨ ពីព្រោះគ្រួសារនាងមានការតឹងរឹងណាស់ចំពោះរូបនាង ហើយនៅថ្ងៃនោះ យើងក៏មិនបានរួមភេទជាមួយគ្នាដែរ។

ខ្ញុំមិនធ្លាប់ចូលរួមការរួមភេទបែបបូកនោះទេ ពីព្រោះខ្ញុំស្អប់អំពើបែបនេះណាស់ ហើយខ្ញុំក៏ធ្លាប់ទទួលព័ត៌មានមួយចំនួនស្តីអំពីបញ្ហាសុខភាពបន្តពូជពីអង្គការមិត្តជួយមិត្ត RHAC និង មណ្ឌលសុខភាពនានា។